សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royal de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **គួន គីមឡុង**
លោក **ពៅ រស្មី**
ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី **២៩** (អាហារូបករណ៍)

ណែនាំដោយ
លោកគ្រូ **កង ស៊ីផាន់ណារ៉ា**


ឆ្នាំចូលសិក្សា **២០២០**
ឆ្នាំសរសេរសារណា **២០២៤**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **គួន គីមឡុង** និងខ្ញុំបាទ **ពៅ រស្មី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៩ ក្នុងឆ្នាំសិក្សា២០២៣-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំសូមសម្តែងនូវសេចក្តីកតញ្ញូ និងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះគុណូបការៈរបស់លោកអ្នកមានគុណដ៏ធំធេងមិនអាចកាត់ថ្លៃបានចំពោះ៖

- លោកឪពុក **ដុំ គឿន** អ្នកម្តាយ **មាស នឿន**
- លោកឪពុក **ពៅ សាន** អ្នកម្តាយ **សម្បត្តិ សុផានី**

លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ដំបូន្មានល្អៗ ការលើកទឹកចិត្ត និងជួយឧបត្ថម្ភដល់ការសិក្សារៀនសូត្រចាប់តាំងពីថ្នាក់មត្តេយ្យ រហូតមកដល់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង សាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយ លោក លោកស្រី មន្ត្រីរាជការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់នូវចំណេះដឹង ការអប់រំ សីលធម៌ និងជួយសម្រួលការងារផ្សេងៗ ដល់យើងខ្ញុំ ក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ។

ពិសេសបំផុតនោះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះលោកគ្រូសាស្ត្រាចារ្យ **ភន ស៊ីផាន់ណារ៉ា** ដែលជាសាស្ត្រាចារ្យណែនាំ និងដឹកនាំការសរសេរសារណារបស់យើងខ្ញុំ ដោយលោកបានខិតខំប្រឹងប្រែងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់នូវដំបូន្មាន គំនិត ចំណេះដឹង យោបល់ ការលើកទឹកចិត្ត និងការបង្ហាញផ្លូវដល់យើងខ្ញុំ ចាប់តាំងពីថ្ងៃដែលពួកយើងខ្ញុំផ្តើមសរសេររហូត ដល់ទទួលបានស្នាដៃមួយនេះជាស្ថាពរដែលគុណធម៌ទាំងនេះ គឺពិតជាមានតម្លៃវិសេសវិសាលឥតកាត់ថ្លៃបានចំពោះយើងខ្ញុំជានិស្សិតស្ថិតក្រោមការណែនាំរបស់លោកគ្រូសាស្ត្រាចារ្យ។

ជាចុងក្រោយ យើងខ្ញុំសូមសម្តែងនូវអំណរអរគុណដល់ប្រធានថ្នាក់ មិត្តល្អ និងសិស្សច្បងទាំងអស់ដែលបានរួមចំណែកក្នុងការជួយសម្របសម្រួលផ្សេងៗ ការផ្តល់នូវកម្លាំងចិត្ត ជាពិសេសនោះ គឺភាពជឿជាក់មកលើរូបយើងខ្ញុំដែលសកម្មភាពទាំងនោះគឺជាចំណែកយ៉ាងធំធេង ក្នុងដំណើរការសរសេរសារណាមួយនេះរហូតបានបញ្ចប់ជាស្ថាពរ និងប្រកបដោយលទ្ធផលជាវិជ្ជមាន។ ជាកិច្ចចុងបញ្ចប់ យើងខ្ញុំសូមលំឱនកាយលើកដៃសំពះ ប្រណមបួងសួងជូនដល់ មាតាបិតា ញាតិមិត្ត ព្រមទាំងថ្នាក់ដឹកនាំ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង សាស្ត្រាចារ្យ សាស្ត្រាចារ្យរង លោក លោកស្រី មន្ត្រីរាជការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅក្នុងប្រទេសកម្ពុជា ចំណងញាតិរបស់គ្រួសារត្រូវបានបង្កើតឡើងតាមរយៈអាពាហ៍ពិពាហ៍ការធ្វើបែបនេះ ជាការគោរពតាមបទប្បញ្ញត្តិផង និងគោរពតាមទំនៀមទម្លាប់ប្រពៃណីផងដែរ។ ចំណងអាពាហ៍ពិពាហ៍មានសារៈសំខាន់ណាស់ ការអនុវត្តតាមដំណាក់កាលនីមួយៗជាច្រើនទើបបង្កើតបានជាអាពាហ៍ពិពាហ៍ មួយដែលមានភាពស្របច្បាប់។ ជាមួយគ្នានេះ ប្រជាពលរដ្ឋខ្មែរមួយចំនួនតែងតែយល់ច្រឡំថាការរៀបអាពាហ៍ពិពាហ៍តាមរបៀបប្រពៃណីជារឿងស្របច្បាប់ ប៉ុន្តែក្នុងច្បាប់វិញ តម្រូវឱ្យគោរពតាមលក្ខខណ្ឌច្បាប់ ទើបត្រូវទទួលបានអានុភាពនៃអាពាហ៍ពិពាហ៍មួយ ដែលច្បាប់ទទួលស្គាល់ និងផ្តល់អត្ថប្រយោជន៍ជាច្រើនសម្រាប់សហព័ទ្ធនោះ។

យើងខ្ញុំទាំងពីរនាក់បានសង្កេតមើលឃើញទិដ្ឋភាពជាក់ស្តែងដែលមាននៅក្នុងការអនុវត្តតាមតុលាការមួយចំនួន នាពេលបច្ចុប្បន្នមានអាពាហ៍ពិពាហ៍ជាច្រើនត្រូវបានប្រឈមនឹងបញ្ហាផ្លូវច្បាប់ នាដំណាក់កាលនៃការលែងលះ ដោយសារតែការមិនគោរពតាមច្បាប់ និងការធ្វេសប្រហែសអំពីសិទ្ធិរបស់ខ្លួនដែលទទួលស្គាល់ដោយច្បាប់ និងត្រូវបានការពារដោយច្បាប់។ ដើម្បីចែករំលែកនូវលក្ខខណ្ឌ បែបបទ និងនីតិវិធីផ្សេងៗដែលទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ឱ្យប្រជាពលរដ្ឋខ្មែរមួយចំនួនមានការយល់ដឹងអំពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ជាពិសេសនោះ នីតិវិធីនៃការបង្កើតអាពាហ៍ពិពាហ៍ លក្ខខណ្ឌ ការហាមឃាត់ និងអានុភាពនៃអាពាហ៍ពិពាហ៍ផងដែរ។ មូលហេតុដោយសារ ប្រជាពលរដ្ឋខ្មែរមួយចំនួនពុំសូវមានការយល់ដឹងទូលំទូលាយអំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍មួយដែលមានភាពស្របច្បាប់របស់ប្រទេសកម្ពុជាឡើយ។ ហេតុដូច្នេះ ទើបយើងខ្ញុំទាំងពីរនាក់បានជ្រើសរើសប្រធានបទសារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ **អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា**។ យើងខ្ញុំទាំងពីរនាក់មានក្តីសង្ឃឹមយ៉ាងមុតមាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ នឹងអាចជួយសម្រួលដល់ប្រជាពលរដ្ឋខ្មែរដែលមានគម្រោងនឹងរៀបអាពាហ៍ពិពាហ៍ឱ្យមានការយល់ដឹងអំពីលក្ខខណ្ឌ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍នោះ ដើម្បីទទួលបានការការពារអំពីសិទ្ធិ និងករណីយកិច្ចរបស់ភាគីប្តីប្រពន្ធនោះ។

យ៉ាងណាមិញ ការស្រាវជ្រាវប្រធានបទមួយនេះ អាចនឹងមានចំណុចខ្វះខាត ទាំងពាក្យពេជ្រ ទាំងអត្ថន័យ និងខ្លឹមសារផងដែរ។ អាស្រ័យហេតុនេះ សូម លោកសាស្ត្រាចារ្យ លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់ មេត្តា ខន្តី អភ័យទោសដល់ការស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរនាក់ផង។ យើងខ្ញុំទាំងពីរនាក់មានភាពរីករាយក្នុងការទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់មហាជនទាំងអស់។

# មាតិកា

**សេចក្តីផ្តើម** ........ ១
១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

**ជំពូកទី១**

**សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍**

**១.១. និយមន័យ** ........ ៦
១.១.១. តាមន័យអក្សរសាស្ត្រ ........ ៦
១.១.២. តាមន័យទំនៀមទម្លាប់ ........ ៦
១.១.៣. តាមន័យច្បាប់ ........ ៦
**១.២. ប្រវត្តិនៃការកកើតអាពាហ៍ពិពាហ៍** ........ ៧
១.២.១. ប្រវត្តិសាស្ត្រ ........ ៧
១.២.២. រឿងព្រេងនិទាន ........ ៨
១.២.៣. ប្រវត្តិពិធីផ្សេងៗនៃពិធីរៀបអាពាហ៍ពិពាហ៍ ........ ៩
**១.៣. ការវិវត្តន៍នៃរបបគតិយុត្តអាពាហ៍ពិពាហ៍** ........ ១២
១.៣.១. របបគតិយុត្តពីឆ្នាំ (១៩២០ - ១៩៧៥) ........ ១៣
១.៣.២. សម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) ........ ១៤
១.៣.៣. របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩ - ១៩៨៩) ........ ១៥
១.៣.៤. របបគតិយុត្តសម័យរដ្ឋកម្ពុជា (១៩៨៩ - ២០១១) ........ ១៥

១.៣.៥. សម័យព្រះរាជាណាចក្រកម្ពុជា (២០១១ - បច្ចុប្បន្ន)........................................ ១៦

## ជំពូកទី២
## របបគតិយុត្តនៃអាពាហ៍ពិពាហ៍បច្ចុប្បន្ន

**២.១. ទំនាក់ទំនងគតិយុត្តមុនរៀបអាពាហ៍ពិពាហ៍ (កំជាប់ពាក្យ)** ........................ ១៩
២.១.១. និយមន័យកំជាប់ពាក្យ ........................................................ ១៩
២.១.២. ការសងជំនួនដោយកំជាប់បានរលាយ ........................................ ១៩
២.១.៣. ការទទួលខុសត្រូវការបដិសេធមិនត្រឹមត្រូវ ................................ ១៩
២.១.៤. អំឡុងពេលដាក់ពាក្យបណ្ដឹង ................................................ ២០
**២.២. លក្ខខណ្ឌនៃបង្កើតអាពាហ៍ពិពាហ៍** ............................................ ២០
២.២.១. គោលការណ៍ស្ម័គ្រចិត្ត......................................................... ២០
២.២.២. ភេទរបស់ភាគី ................................................................. ២១
២.២.៣. អាយុរបស់ភាគី.................................................................. ២២
២.២.៤. ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន...................................... ២៣
២.២.៤.១. អនីតិជន និងនីតិជន ........................................................ ២៤
២.២.៤.២. ជនដែលទទួលបានអត្តាធីនភាព............................................ ២៤
២.២.៥. ជននៅក្រោមអាណាព្យាបាលទូទៅ.......................................... ២៤
២.២.៦. ជននៅក្រោមហិតូបត្ថម្ភ ...................................................... ២៦
**២.៣. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍**.......................................... ២៧
២.៣.១. ការហាមឃាត់មិនឱ្យទ្វេពន្ធភាព ............................................ ២៧
២.៣.២. អំឡុងពេលហាមឃាត់បង្កើតអាពាហ៍ពិពាហ៍ថ្មី ............................ ២៨
២.៣.៣. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត............ ២៩
២.៣.៤. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ .................. ២៩
២.៣.៥. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ក្រោយកាត់កាលស្មុំកូន......... ៣០
**២.៤. នីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍** ........................................ ៣១
២.៤.១. ទីកន្លែងដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ .................................... ៣១

២.៤.២. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ..... ៣២
២.៤.៣. ការប្រកាសផ្សាយជាសាធារណៈ ..... ៣៣
២.៤.៤. ការប្ដឹងជំទាស់នៃអាពាហ៍ពិពាហ៍ ..... ៣៤
២.៤.៤.១. ជនដែលអាចធ្វើបណ្ដឹងជំទាស់អាពាហ៍ពិពាហ៍ ..... ៣៥
២.៤.៤.២. មូលហេតុជំទាស់នឹងគម្រោងរៀបអាពាហ៍ពិពាហ៍ ..... ៣៦
២.៤.៤.៣. ការសម្រេចលើការប្ដឹងជំទាស់ ..... ៣៧
២.៤.៥. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ..... ៣៧
២.៤.៦. ការចុះបញ្ជីអាពាហ៍ពិពាហ៍ ..... ៣៨
២.៤.៧. ការផ្ដល់សំបុត្រអាពាហ៍ពិពាហ៍ ..... ៣៨
**២.៥. អានុភាពនៃអាពាហ៍ពិពាហ៍** ..... ៣៩
២.៥.១. អានុភាពក្រៅបេតិកភណ្ឌ ..... ៣៩
២.៥.១.១. សិទ្ធិប្រើប្រាស់នាមត្រកូលប្ដី ប្រពន្ធ ..... ៤០
២.៥.១.២. ករណីយកិច្ចរួមរស់ សហការ និងជួយសង្គ្រោះគ្នា ..... ៤០
២.៥.១.៣. សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និងសិទ្ធិចូលរួមក្នុងសង្គម ..... ៤១
២.៥.១.៤. ទទួលបាននីតិភាពតាមរយៈអាពាហ៍ពិពាហ៍ ..... ៤១
២.៥.១.៥. សិទ្ធិអំណាចមេបាលើកូន ..... ៤២
២.៥.២. អានុភាពផ្នែកបេតិកភណ្ឌ ..... ៤៣
២.៥.២.១. ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមកិច្ចសន្យា ..... ៤៤
២.៥.២.២. នីតិវិធីនៃការចុះបញ្ជី ..... ៤៥
២.៥.២.៣. អានុភាពនៃការចុះបញ្ជី ..... ៤៨
២.៥.២.៤. ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធដែលកំណត់ដោយច្បាប់ ..... ៥០
២.៥.២.៥. សិទ្ធិគ្រប់គ្រង និងចាត់ចែងលើទ្រព្យសម្បត្តិប្ដីប្រពន្ធ ..... ៥៥
២.៥.២.៦. ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ ..... ៥៥
២.៥.២.៧. ការទទួលខុសត្រូវលើបំណុល និងកាតព្វកិច្ចផ្សេងៗទៀត ..... ៥៧

## ជំពូកទី៣
## ការបញ្ចប់អាពាហ៍ពិពាហ៍

**៣.១. មោឃភាពនៃអាពាហ៍ពិពាហ៍** ........ ៦០
៣.១.១. មូលហេតុនៃមោឃភាពអាពាហ៍ពិពាហ៍ ........ ៦១
៣.១.១.១. ការភាន់ច្រឡំលើមនុស្ស ........ ៦១
៣.១.១.២. ការបង្ខិតបង្ខំ ........ ៦១
៣.១.១.៣. ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ........ ៦២
៣.១.១.៤. ភាគីមិនបានជូនដំណឹងជាសាធារណៈ ........ ៦២
៣.១.១.៥. ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ........ ៦២
៣.១.១.៦. ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ........ ៦២
៣.១.២. អ្នកមានសិទ្ធិប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ ........ ៦២
៣.១.៣. អានុភាពនៃមោឃភាព ........ ៦៣
**៣.២. ការលុបចោលអាពាហ៍ពិពាហ៍** ........ ៦៣
៣.២.១. មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ ........ ៦៣
៣.២.១.១. ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ ........ ៦៣
៣.២.១.២. ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនគ្រប់អាយុ ........ ៦៤
៣.២.១.៣. ការលុបចោលក្នុងអំឡុងពេលហាមឃាត់អាពាហ៍ពិពាហ៍ថ្មី ........ ៦៤
៣.២.១.៤. ការលុបចោលអាពាហ៍ពិពាហ៍ដោយសារការឆបោក ឬការគំរាមកំហែង ........ ៦៥
៣.២.២. ការរំលត់សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ ........ ៦៥
៣.២.៣. អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍ ........ ៦៦
**៣.៣. ការអវត្តមាន និងការប្រកាសអំពីការបាត់ខ្លួន** ........ ៦៧
៣.៣.១. លក្ខខណ្ឌនៃការប្រកាសពីការអវត្តមាន និងការប្រកាសបាត់ខ្លួន ........ ៦៨
៣.៣.២. នីតិវិធីនៃការប្រកាសពីការអវត្តមាន និងការប្រកាសបាត់ខ្លួន ........ ៦៨
៣.៣.៣. អានុភាពនៃការអវត្តមាន និងប្រកាសអំពីការបាត់ខ្លួន ........ ៦៩
**៣.៤. មរណភាពរបស់សហព័ទ្ធ** ........ ៧០

៣.៤.១. នីតិវិធីនៃការបញ្ជាក់មរណភាព ........ ៧០

៣.៤.២. អានុភាពក្រោយមរណភាព ........ ៧១

**៣.៥. ការលែងលះ** ........ ៧១

៣.៥.១. ការលែងលះដោយការព្រមព្រៀង ........ ៧១

៣.៥.២. ការលែងលះតាមបណ្ដឹងទាមទារ ........ ៧៣

**សេចក្ដីសន្និដ្ឋាន** ........ ៧៥

**អនុសាសន៍** ........ ៧៦

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅលើសកលលោកយើងនេះ ការរៀបអាពាហ៍ពិពាហ៍មានលក្ខណៈផ្សេងៗពីគ្នា ទៅតាមប្រពៃណី ទំនៀមទម្លាប់ សាសនា និងច្បាប់របស់ប្រទេសនោះផងដែរ។ ដោយឡែកប្រសិនបើយើងទៅក្រឡេកមើល នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ ការបន្តពូជពង្សវង្សត្រកូលពិតជាសំខាន់ និងចាំបាច់ណាស់ សម្រាប់បង្កបង្កើនធនធានមនុស្សសម្រាប់ប្រទេសជាតិនិយាយជារួម និងបង្កើតជាកូន ពូនជាចៅសម្រាប់បន្តពូជពង្សវង្សត្រកូលនៃគ្រួសារនិយាយដោយឡែក។ នៅពេលដែលមនុស្សធំធាត់ចម្រើនពេញវ័យមនុស្សគ្រប់រូបតែងតែខិតខំសិក្សារៀនសូត្រក្រេបចំណេះដឹង និងស្វែងរកការងារមួយដែលអាចជួយទ្រទ្រង់ជីវភាពគ្រួសារបាន បន្ទាប់ពួកគេតែងនាំគ្នាគិតគូរស្វែងរកគូស្រករដោយការសម្រេចចិត្តខ្លួនឯង ឬក៏មានការផ្សំផ្គុំពីឪពុកម្តាយ ចាស់ព្រឹទ្ធាចារ្យ ញាតិមិត្ត បន្តមកពួកគេបានព្រមព្រៀងក្នុងការស្រឡាញ់គ្នា ស្ម័គ្រចិត្តរួមរស់នៅជាមួយគ្នា ទើបប្រាប់ឪពុកម្តាយ ដើម្បីធ្វើពិធីរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ផង និងតាមទំនៀមទម្លាប់ប្រពៃណីផងដែរ។

មុននឹងឈានដល់ការរៀបអាពាហ៍ពិពាហ៍នោះបុរស និងនារីត្រូវគោរពតាមលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍ រួមមាន គោលការណ៍ស្ម័គ្រចិត្តដោយមានការព្រមព្រៀងគ្នា ត្រូវមាន អាយុ ភេទ និងនីតិវិធីសម្រាប់ការរៀបអាពាហ៍ពិពាហ៍ រួមមាន ការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ ការប្រកាសជាសាធារណៈ ការចុះកិច្ចសន្យា ការចុះបញ្ជីអាពាហ៍ពិពាហ៍ និងតាមលក្ខខណ្ឌដែលច្បាប់តម្រូវនានាជាមុនសិន។ ទើបអាពាហ៍ពិពាហ៍នោះមានអានុភាពដល់ បុរស និងនារីដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍នាពេលអនាគត ឬក្លាយជាប្តីប្រពន្ធនឹងគ្នាដោយស្របច្បាប់របស់ប្រទេសកម្ពុជា ទទួលបាននូវសិទ្ធិដែលច្បាប់ផ្តល់ឱ្យ និងកាតព្វកិច្ចដែលត្រូវគោរពតាមច្បាប់ជាការចាំបាច់ផងដែរ។ ជាកិច្ចការបន្ទាប់បន្សំនោះ ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី គឺមានទំនៀមទម្លាប់មួយដែលមានចាប់តាំងពីបុរាណកាលមកហើយ ការធ្វើរបៀបនេះគេមានចេតនារំលឹកនឹកគុណដល់គ្រូបាអាចារ្យ ចាស់ព្រឹទ្ធាចារ្យ លោកមេបាចាស់ទុំជាដើម។

ចំពោះកិច្ចការ រៀបអាពាហ៍ពិពាហ៍តាមគន្លងច្បាប់ប្រទេសកម្ពុជាវិញបានផ្តល់នូវការពន្យល់ពីរបៀបរបប បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍នោះតាមរយៈក្រមរដ្ឋប្បវេណីអនុវត្ត ឆ្នាំ២០១១ ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ និងលិខិតបទដ្ឋានគតិយុត្តណែនាំនានាដែលនឹងកំពុងជាធរមាន។ អាពាហ៍ពិពាហ៍មានទម្រង់ច្រើនយ៉ាង រួមមាន អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅបរទេស អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋបរទេសនៅកម្ពុជា អាពាហ៍ពិពាហ៍រវាងពលបរទេស និងបរទេសនៅកម្ពុជា។ ដោយឡែកយើងខ្ញុំសូមលើកយកតែទម្រង់នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា មកធ្វើការស្រាវជ្រាវ ដើម្បីបញ្ចប់នូវការសិក្សារបស់យើងខ្ញុំ។ បន្ទាប់ពីមើលឃើញនូវអត្ថប្រយោជន៍ ចំពោះជាតិ ចំពោះគ្រួសារ ចំពោះ

ខ្លួនឯង និងសម្រាប់អ្នកសិក្សាស្រាវជ្រាវអំពីការរៀបអាពាហ៍ពិពាហ៍តាមទម្រង់បែបបទថ្មី និងនីតិវិធីនៃការបង្កើតអាពាហ៍ពិពាហ៍តាមរបៀបថ្មីផងដែរ។

អាស្រ័យហេតុដូច្នេះ យើងខ្ញុំទាំងពីរនាក់បានលើកយកនូវប្រធានបទដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ គឺប្រធានបទ “**អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា**” មកធ្វើការបកស្រាយ។ ដោយយល់ឃើញថាប្រធានបទនេះ មានអត្ថប្រយោជន៍ច្រើនក្នុងការជួយផ្តល់នូវធាតុចូលយ៉ាងមានសារៈសំខាន់ក្នុងការជួយប្រជាជនទាំងអស់ឱ្យបានយល់ដឹងស៊ីជម្រៅអំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍តាមនិយាមគតិយុត្តថ្មី នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងច្បាប់ស្តីពីអត្រានុកូលដ្ឋានថ្មី ឆ្នាំ២០២៣។ ជៀសវាងការដែលកើតមានឡើងនូវបញ្ហាប្រឈមដែលជាកិច្ចការពិបាកក្នុងដោះស្រាយនៅអំឡុងពេលលែងលះគ្នា និងក្រោយពេលដែលលែងលះគ្នានោះផងដែរ។ ម្យ៉ាងទៀតដើម្បីចូលរួមក្នុងការផ្សព្វផ្សាយអំពីច្បាប់ទៅដល់ស្ថាប័ន អាជ្ញាធរ មន្ត្រីមានសមត្ថកិច្ចអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព និងចែករំលែកនូវចំណេះដឹងដល់ប្រជាជនឱ្យបានច្បាស់លាស់ផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តើជាកិច្ចការដើម្បីមានភាពស្របច្បាប់ក្នុងការរៀបអាពាហ៍ពិពាហ៍មួយដែលច្បាប់ទទួលស្គាល់ថាត្រឹមត្រូវតាមទម្រង់បែបបទនោះ បុរស និងនារីត្រូវគោរពប្រតិបត្តិនូវលក្ខខណ្ឌ និងនីតិវិធីអ្វីខ្លះ? តើប្រសិនបើអាពាហ៍ពិពាហ៍នោះមិនបានគោរពប្រតិបត្តិនូវលក្ខខណ្ឌទាំងអស់នោះ នឹងមានផ្តល់ផលវិបាកដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃប្រធានបទ ដើម្បីស្វែងយល់បន្ថែមអំពីលក្ខខណ្ឌ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ និងលិខិតបទដ្ឋានគតិយុត្តថ្មីៗដែលកំពុងជាធរមាន។ គោលបំណងចម្បងបន្ថែមទៀតនោះ ដើម្បីស្វែងយល់លម្អិតអំពីផលវិបាករបស់គូភាគីនៃការមិនគោរពប្រតិបត្តិតាមបែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ដែលមានការទទួលស្គាល់ជាផ្លូវការតាមបញ្ញត្តិច្បាប់កំពុងជាធរមានផងដែរ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ប្រធានបទនេះ គ្រប់ដណ្តប់លើការរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានទម្រង់ជាអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា។ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការប្រព្រឹត្តទៅត្រូវអនុលោមភាពតាមបញ្ញត្តិដែលមានចែងកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ ផ្តោតលើនីតិវិធី បែបបទ ទម្រង់ នៃការរៀបអាពាហ៍ពិពាហ៍ និងកំណត់អំពីបុគ្គលមានសមត្ថកិច្ចទទួលបន្ទុកផ្តល់នូវអានុភាពនៃអាពាហ៍ពិពាហ៍ ព្រមទាំងមានភារកិច្ចដោះស្រាយនូវបញ្ហានានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលបានផ្តល់សមត្ថកិច្ចតាមការកំណត់របស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀតផង។ ក្នុងនោះស្ថាប័នដែលមានសមត្ថកិច្ចទាក់ទងពិសេសជាងគេនោះ រួមមាន

ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ស្ថាប័នទទួលបន្ទុកអនុវត្តច្បាប់ អាជ្ញាធរដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មន្ត្រីអត្រានុកូលដ្ឋានក្រោមជាតិ ស្ថាប័នតុលាការ សាលាដំបូងរាជធានី ខេត្ត សាលាឧទ្ធរណ៍ តុលាការកំពូលផងដែរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃប្រធានបទនេះ ជាធាតុចូលយ៉ាងសំខាន់សម្រាប់ផ្សព្វផ្សាយអំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា ដល់ក្រសួងទទួលបន្ទុកលើកិច្ចការគ្រប់គ្រងអត្រានុកូលដ្ឋាន រួមមាន ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ មន្ត្រីអនុវត្តច្បាប់ ជាពិសេសតុលាការរាជធានី ខេត្ត និងមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ដើម្បីបានជាចំណេះដឹងបន្ថែមសម្រាប់លំហូរនីតិវិធីនៃការអនុវត្តឱ្យមានការឯកភាពគ្នា។ ជាពិសេស រួមចំណែកក្នុងការចែករំលែកចំណេះដឹងបន្ថែមដល់សិស្សានុសិស្ស និស្សិត និងប្រជាពលរដ្ឋទាំងអស់ដែលមានគម្រោងនឹងរៀបអាពាហ៍ពិពាហ៍ដើម្បីជាអត្ថប្រយោជន៍បន្ថែមមួយ យល់ច្បាស់អំពីការបង្កើតអាពាហ៍ពិពាហ៍មួយដែលមានភាពស្របច្បាប់ និងមានអានុភាពដែលច្បាប់បានទទួលស្គាល់។ ជាពិសេសទៀតនោះ ប្រជាជនរស់នៅតាមទីក្រុង ទីប្រជុំជន ទីជនបទ ជាហេតុថាពួកគាត់រវល់ក្នុងការប្រកបមុខរបររកស៊ី អាជីវកម្ម ចិញ្ចឹមជីវិតរបស់ពួកគេ នាំឱ្យពួកគេមិនសូវបានជ្រាបអំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការរៀបចំគ្រួសារមួយដែលមានការទទួលពីផ្លូវច្បាប់នោះឡើយ។ ម្យ៉ាងទៀតពួកគាត់មិនសូវទទួលបានការពន្យល់អំពីនីតិវិធីតាមច្បាប់នានា និងដោយសារគាត់មានបញ្ហាលំបាកក្នុងជីវភាពគ្រួសារផងនោះ ទើបជាហេតុនាំឱ្យគាត់ធ្វើតាមទំនៀមទម្លាប់ចាស់ដោយគ្រាន់តែមានការរៀបចំមង្គលការតាមប្រពៃណី ឬជប់លៀងផ្សេងៗ ដែលជាហេតុនាំឱ្យអាពាហ៍ពិពាហ៍នោះមិនមានភាពស្របច្បាប់ ហើយច្បាប់មានភាពពិបាកក្នុងការចូលរួមអនុវត្តនៅពេលដែលពួកគាត់មានវិវាទរវាងគ្នាកើតឡើង។

សារៈប្រយោជន៍មួយទៀត ដើម្បីកាត់បន្ថយនូវការអនុវត្តតាមបែបបទ នីតិវិធីដែលជាបញ្ហាស្មុគស្មាញ ធ្វើឱ្យមានលក្ខណៈល្អប្រសើរឡើងវិញ ធានានូវ តម្លាភាព ប្រសិទ្ធភាពនៃអាពាហ៍ពិពាហ៍នោះ។ ដោយជៀសវាងនូវបញ្ហាដែលកើតឡើង រួមមាន ករណីទីមួយ ប្រសិនបើគាត់រស់នៅជាមួយគ្នាជាប្តីប្រពន្ធដែលមានលក្ខណៈជាអនីតិសង្វាស ត្រូវព្រមព្រៀងគ្នាលែងលះត្រឹមសាលាឃុំ សង្កាត់ ដោយចំណងនៃអាពាហ៍ពិពាហ៍របស់ពួកគាត់នោះងាយនឹងកាត់ផ្តាច់ចំណងគតិយុត្តរវាងសហព័ទ្ធនោះ ដោយសាលាឃុំ សង្កាត់ ឬភាគី មិនបានស្វែងយល់បន្ថែមអំពីផលវិបាកដែលកើតមានក្រោយពេលដែលលែងលះគ្នារួច។ ក្នុងនោះដែរ មិនមាននូវនីតិវិធី បែបបទកាតព្វកិច្ច អ្វីច្រើននោះឡើយ ក្នុងការលែងលះគ្នាដោយគ្រាន់តែមានការព្រមព្រៀងជាមួយគ្នា និងមានសាក្សីមួយចំនួនផ្តិតមេដៃទទួលស្គាល់ថាពួកគេបានព្រមព្រៀងគ្នាតែប៉ុណ្ណោះ។ ករណីទីពីរ ប្រសិនបើគាត់រស់នៅជាមួយគ្នាជាលក្ខណៈនីតិសង្វាស ដែលបានដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ ការប្រកាសជាសាធារណៈ ការចុះកិច្ចសន្យា ការចុះបញ្ជីអាពាហ៍ពិពាហ៍ និងមានការទទួលស្គាល់ជាផ្លូវការនោះ ការលែងលះរបស់ពួកគាត់ត្រូវតែមានការសម្រេចសេចក្តីនៃការលែងលះដោយចៅក្រមតាមរយៈ ដីកាសម្រេច សាលក្រម សាលដីកា សាលាដំបូងរាជធានី ខេត្ត និងតុលាការជាន់ខ្ពស់។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានប្រើប្រាស់នូវវិធីសាស្ត្រនៃការប្រមូលទិន្នន័យ ការវិភាគ ការពិភាក្សាជាមួយអ្នកជំនាញច្បាប់ ការសំយោគនូវគំនិតសំខាន់ៗរបស់លោក លោកស្រីសាស្ត្រាចារ្យ មន្ត្រីរាជការនៃសាលាច្បាប់ និងដោយមានការចូលរួមពីសំណាក់មន្ត្រីអនុវត្តច្បាប់ មន្ត្រីអត្រានុកូលដ្ឋាន មន្ត្រីដែលបានអនុវត្តនៅតាមស្ថាប័នតុលាការ និងសុំការណែនាំពីសាស្ត្រាចារ្យដឹកនាំសារណា សុំមតិយោបល់ពី លោក លោកស្រីចៅក្រម មេធាវី ក្រឡាបញ្ជី និងឯកសារច្បាប់ លិខិតរដ្ឋបាល លិខិតគតិយុត្ត រួមមាន (ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីណែនាំ សេចក្តីសម្រេច ដែលទាក់ទងទៅនឹងប្រធានបទនៃសារណាស្តីពីការរៀបអាពាហ៍ពិពាហ៍) ឯកសារដែលទទួលបានពីប្រព័ន្ធអ៊ីនធឺណេត ឯកសារពីបណ្ណាល័យច្បាប់ សៀវភៅច្បាប់សាលក្រម ដីកាសម្រេចនានា ដែលទទួលបានពីមន្ត្រីអនុវត្តនៅតាមតុលាការ និងសាស្ត្រាចារ្យសាលាច្បាប់ផ្សេងៗ និងឯកសារមួយចំនួនទៀតដែលទទួលបានពីសិស្សច្បង សុំមតិយោបល់ពីអ្នកដែលមានបទពិសោធន៍យល់ដឹងច្រើនអំពីការរៀបអាពាហ៍ពិពាហ៍ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីងាយស្រួលស្វែងយល់ស៊ីជម្រៅ និងយល់ដឹងច្បាស់អំពី បែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍មួយដែលមានភាពស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សារណានេះ យើងខ្ញុំបានបែងចែកជាមែងធាងតាមចំណែកនីមួយៗយ៉ាងលម្អិតជាងាយស្រួលចាប់បាននូវចំណុចសំខាន់ៗនីមួយៗ និងបានបែងចែកចេញជាបីជំពូកធំៗ និងមានផ្នែកបន្តបន្ទាប់ផ្សេងៗផងដែរ។ រួមមាន សេចក្តីផ្តើម (លំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ដែនកំណត់ និងវិសាលភាព សារៈសំខាន់ វិធីសាស្ត្រនៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ) ជំពូកទី១ សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍ (១.១. និយមន័យអាពាហ៍ពិពាហ៍ ១.២. ប្រវត្តិនៃការកកើតអាពាហ៍ពិពាហ៍ និង ១.៣. ការវិវត្តន៍នៃរបបគតិយុត្តអាពាហ៍ពិពាហ៍) ជំពូកទី២ របបគតិយុត្តនៃអាពាហ៍ពិពាហ៍បច្ចុប្បន្ន (២.១. របបគតិយុត្តនៃការរៀបអាពាហ៍ពិពាហ៍ ២.២. លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍ ២.៣. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ ២.៤. នីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ២.៥. ការប្តឹងជំទាស់នៃអាពាហ៍ពិពាហ៍ និង២.៦. អានុភាពនៃអាពាហ៍ពិពាហ៍) ជំពូកទី៣ ការបញ្ចប់អាពាហ៍ពិពាហ៍ (៣.១.មោឃភាពនៃអាពាហ៍ពិពាហ៍ ៣.២. ការលុបចោលនៃអាពាហ៍ពិពាហ៍ ៣.៣. ការអវត្តមាន និងការប្រកាសអំពីការបាត់ខ្លួន ៣.៤. មរណភាពរបស់សហព័ទ្ធ ៣.៥. ការលែងលះរបស់អាពាហ៍ពិពាហ៍) សេចក្តីសន្និដ្ឋាន អនុសាសន៍ គន្ថនិទ្ទេស ឧបសម្ព័ន្ធ ដើម្បីអ្នកសិក្សាស្រាវជ្រាវ អ្នកអាន អ្នកនិពន្ធងាយស្រួលក្នុងការយល់ដឹងច្បាស់ក្នុងការកត់ចំណាំប្លង់ផងដែរ។

# ជំពូកទី១
# សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

# ជំពូកទី១

# សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

ការរៀបអាពាហ៍ពិពាហ៍មានចាប់តាំងពីបុរាណកាលមក ហើយបន្តរហូតដល់បច្ចុប្បន្ន ប្រជាជនខ្មែរតែងតែមានការរៀបចំទុកដាក់កូនចៅ រៀបចំគិតគូរពីគូស្រករសម្រាប់កូនប្រុសកូនស្រីរបស់ខ្លួន នៅពេលដែលកូនប្រុសកូនស្រីនោះ បានចម្រើនវ័យដល់អាយុពេញវ័យមួយដែលអាចរៀបអាពាហ៍ពិពាហ៍បាន ឬកូនប្រុសកូនស្រីនោះអាចមានលទ្ធភាពក្នុងការរកស៊ីចិញ្ចឹមជីវិតរស់នៅបានសមរម្យហើយ។ ឪពុកម្តាយ ឬអាណាព្យាបាលតែងតែបានគិតគូរអំពីការរៀបចំទុកដាក់កូនចៅលើរឿងរៀបចំគ្រួសារ ដើម្បីបន្តពូជពង្សវង្សត្រកូលគ្រួសារជារៀងរហូតតទៅទៀត។ ការធ្វើពិធីរៀបអាពាហ៍ពិពាហ៍នោះត្រូវបានប្រជាជនកម្ពុជា បានប្រព្រឹត្តទៅតាមរបៀបរបបប្រពៃណីទំនៀមទម្លាប់ និងតាមការរៀបអាពាហ៍ពិពាហ៍ទៅតាមលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍តាមកន្លងច្បាប់ចាស់ផងដែរ។ លុះមកដល់ពេលបច្ចុប្បន្ន វិសាលភាពច្បាប់មានការទូលំទូលាយជាងមុន ហើយអាពាហ៍ពិពាហ៍ត្រូវអនុវត្តតាមកន្លងច្បាប់ថ្មីវិញ។ ជាធម្មតាប្រជាជនកម្ពុជាតែងតែមានការយល់ច្រឡំថាការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីថាជារឿងស្របច្បាប់ទៅវិញ មានន័យថាការរៀបអាពាហ៍ពិពាហ៍បច្ចុប្បន្នប្រព្រឹត្តទៅតាមប្រពៃណីគ្រាន់តែជាការអនុវត្តទៅតាមទំនៀមទម្លាប់ដែលមានចាប់តាំងពីដូនតាមកម្ល៉េះ។ ដើម្បីឱ្យអាពាហ៍ពិពាហ៍មួយប្រព្រឹត្តទៅមានភាពស្របច្បាប់នោះ លុះត្រាតែបុរស និងស្ត្រីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះបាន ត្រូវតែធ្វើការចុះសំបុត្រអាពាហ៍ពិពាហ៍នៅសាលាឃុំ សង្កាត់ ទើបអាពាហ៍ពិពាហ៍នោះទទួលស្គាល់ជារឿងពេញលេញតាមផ្លូវច្បាប់។

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដែលមានភាពពេញលេញតាមផ្លូវច្បាប់ដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន ។អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបានលុះត្រាតែគូភាគីទាំងបុរស និងនារីត្រូវតែបំពេញលក្ខខណ្ឌច្បាប់បានកំណត់ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ និងការបញ្ចប់អាពាហ៍ពិពាហ៍ជាដើម។ ការរៀបអាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ទើបមានភាពពេញលេញក្នុងការអនុវត្តតាមគន្លងច្បាប់។ ប៉ុន្តែបច្ចុប្បន្ននេះ ការរៀបអាពាហ៍ពិពាហ៍ត្រូវបានអនុលោមតាមបែបបទ នីតិវិធីនៃនិយាមគតិយុត្តថ្មីមកជំនួសតាមរយៈ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១ ច្បាប់ ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ និងសេចក្តីណែនាំ ស្តីពី ការចុះបញ្ជីអត្រានុកូលដ្ឋាន ស្របតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៤ សេចក្តីណែនាំ ស្តីពី បែបបទ នីតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ឆ្នាំ២០២៤ ដែលកំពុងនៅជាធរមាននឹងបានយកមកអនុវត្តតាម។

## ១.១. និយមន័យ

### ១.១.១. តាមន័យអក្សរសាស្ត្រ

អាពាហ៍ពិពាហ៍(សំ.បា.អាវាហ+ វិវាហ ខ្មែរប្រើផ្លាស់វាជា ព) ន. មង្គលការ គូរបុរសស្ត្រីដែលបាននាំមក ហើយនាំត្រឡប់ទៅវិញ (ពីរលើក) : តាមរូបសព្ទ អាវាហ (អាពាហ៍) ថា "នាំមក", វិវាហ (ពិពាហ៍) ថា "នាំត្រឡប់ទៅវិញ"; តាមអធិប្បាយក្នុងគម្ពីរកែសព្ទថា ការនាំកូនស្រីមកខាងលំនៅកូនប្រុស ហៅថា អាវាហៈ (អាពាហ៍), ការនាំកូនប្រុសត្រឡប់ទៅខាងលំនៅកូនស្រីវិញ ហៅថា វិវាហៈ (ពិពាហ៍) ;ប៉ុន្តែតាមទំនៀមខ្មែរត្រូវនាំកូនប្រុសមកខាងលំនៅកូនស្រីមុន ហៅថា អាពាហ៍ (ត្រូវធ្វើពីល្ងាច), លុះដល់វេលាព្រឹកឡើង នាំកូនស្រីទៅឯរោងខាងកូនប្រុសវិញ ហៅថា ពិពាហ៍; មង្គលការដែលបានធ្វើទាំងពីរបែបនេះទើបហៅថា មង្គលការអាពាហ៍ពិពាហ៍; បើបានធ្វើត្រឹមតែ អាពាហ៍ ហៅថា អាវាហមង្គល, បើធ្វើតែ ពិពាហ៍ ហៅថា វិវាហមង្គល : បានរៀបមង្គលការអាពាហ៍ពិពាហ៍ពេញច្បាប់។ (ព.កា.) បញ្ជាក់សព្ទ អាពាហ៍ និង ពិពាហ៍ ថា អាពាហ៍ប្រែថាការនាំមក នូវប្រុសពន្លកជាគូរភ្វា មកផ្ទះខាងស្រីតាមវេលា ពិពាហ៍ថានាំស្រីទៅវិញ។ ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ខ្មែរ ត្រូវមានការរៀបចំឱ្យមានរបៀបរៀបរយ តាមលំដាប់លំដោយ និងតាមប្រពៃណីទំនៀមទំលាប់ខ្មែរ ទោះបីក្នុងពិធីរៀបអាពាហ៍ពិពាហ៍ខ្មែរនាសម័យបច្ចុប្បន្ន ដែលពិធីខ្លះបានកាត់ផ្តាច់ ពុំត្រូវបានគេប្រារព្ធក៏ដោយ តែពិធីសំខាន់ៗផ្សេងទៀតក្នុងពិធីរៀបអាពាហ៍ពិពាហ៍ខ្មែរនៅតែត្រូវបានគេធ្វើ ឡើងដោយខានពុំបានឡើយ។

### ១.១.២. តាមន័យទំនៀមទម្លាប់

អាពាហ៍ពិពាហ៍ គឺជាពិធីមួយដែលរៀបចំឡើងសម្រាប់ផ្សំផ្គុំមនុស្សប្រុស និងមនុស្សស្រីពេញវ័យដើម្បីឱ្យក្លាយជាប្តីប្រពន្ធនឹងគ្នាដែលត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយផងដែរ។ អាពាហ៍ពិពាហ៍ ជាការភ្ជាប់សាច់ភ្ជាប់ឈាមរវាងក្រុមគ្រួសារពីរក្រុមមានខាងកូនកម្លោះ និងមានខាងកូនក្រមុំដើម្បីបន្តពូជពង្សវង្សត្រកូលបន្តទៅមុខទៀតទៅតាមគន្លងប្រពៃណីតាំងពីបុរាណកាលមក។ អាពាហ៍ពិពាហ៍ គឺជាការនាំកូនស្រីទៅរៀបមង្គលការនៅផ្ទះខាងកូនប្រុស ហើយនាំកូនប្រុសទៅរៀបមង្គលការនៅផ្ទះខាងកូនស្រី។ ប៉ុន្តែ ដោយសារទំនៀមទំលាប់ប្រពៃណីខ្មែរបានឱ្យតម្លៃខ្ពស់ទៅលើកូនស្រី ដូច្នេះហើយ អាពាហ៍ពិពាហ៍ មានន័យថា ការនាំកូនប្រុសទៅរៀបមង្គលការនៅផ្ទះខាងកូនស្រី។

### ១.១.៣. តាមន័យច្បាប់

តាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ បានផ្តល់និយមន័យថា អាពាហ៍ពិពាហ៍ សំដៅដល់កិច្ចសន្យាពិសេសដែលកើតចេញពីឆន្ទៈព្រមព្រៀងរវាងបុរសម្នាក់និងនារីម្នាក់ដែលមានបំណងរួមរស់ជាមួយគ្នានិងសង្គ្រោះគ្នាទៅវិញទៅមក ហើយបុរសនិងនារីនោះ ត្រូវតែមានលក្ខខណ្ឌដូចបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។[1] ក្រឡេកទៅមើលច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ បញ្ញត្តិថា ចំណងអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារឹកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាថារួម

---

[1] សន្ធានុក្រម ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ លេខរៀង ១៩។

សមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។[2] អាពាហ៍ពិពាហ៍ គឺជាសម្ព័ន្ធភាពមួយជីវិតរវាងបុរស និង នារី ដូច្នេះ បុរស និង នារីនោះចាំបាច់ត្រូវបានពេញវ័យទាំងផ្នែកសេដ្ឋកិច្ច សង្គម ផ្លូវចិត្ត និងផ្លូវកាយ។[3] គោលបំណងនៃការជំរុញឱ្យភាគីបានការរៀបអាពាហ៍ពិពាហ៍ស្របតាមការកំណត់ច្បាប់នោះដើម្បី ការពារសេចក្តីថ្លៃថ្នូរ និងពង្រឹងសុខដុមរមនា សុភមង្គល ក្នុងគ្រួសារ និងការគោរពសិទ្ធិគ្នាទៅវិញទៅមករវាងប្តីនិងប្រពន្ធ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តជាធរមាន។

## ១.២. ប្រវត្តិនៃការកកើតអាពាហ៍ពិពាហ៍

យោងតាមឯកសារស្រាវជ្រាវ ប្រពៃណីទំនៀមទម្លាប់ខ្មែរពាក់ព័ន្ធនឹងនរ វិទ្យា និងជាតិពិន្ទុវិទ្យា ដែលចងក្រងដោយលោក មៀច ប៉ុណ្ណ បោះពុម្ព ឆ្នាំ២០០៣ ត្រង់ទំព័រទី៣ បានឱ្យដឹងថា ក្បួន ឬទម្រង់អាពាហ៍ពិពាហ៍ខ្មែរ ដែលមនុស្សខ្មែរបាននឹងកំពុងអនុវត្តរហូតមកដល់សព្វថ្ងៃ គឺច្រើនធ្វើទៅតាមលំអានរឿងរ៉ាវគម្ពីរជាតក និងទាក់ទងទៅនឹងរឿងព្រេងផ្សេងៗទៀតដូចខាងក្រោមនេះ៖

- កាលព្រះវេស្សន្ត និងព្រះនាងមទ្រី រៀបអភិសេកបុត្រាបុត្រី គឺ ជាលី និងក្រឹស្នា ឱ្យបានទៅជាគូស្វាមីភរិយា (ព្រះវេស្សន្តជាតក)។
- កាលព្រះបាទមហាចក្រ នៅនគរនិគ្រោធគ្រាមាធ្វើពិធីរៀបអាពាហ៍ ពិពាហ៍ព្រះរាជបុត្រី ដែលមានរយៈពេល ៧ ថ្ងៃ ៧យប់ (តាមសាស្ត្រា ស្លឹករឹតៈ គម្ពីរក្បួនទម្រង់ការ ចារដោយភិក្ខុ ចន្ទ ថេរអ្លូង) ។
- កាលព្រះបាទទសរថ និង ឥសីមិថិលា រៀបអភិសេកព្រះរាម និង នាងសីតា (ក្នុងរឿងរាមកេរ្តិ៍)។
- កាលសេដ្ឋីបុណ្ណវឌ្ឍន រៀបការជាមួយនាងវិសាខា ដែលពិធីរៀប អាពាហ៍ពិពាហ៍នោះត្រូវបានប្រារព្ធអស់រយៈពេលបីខែ(តាមគម្ពីរធម្មបទ)។
- កាលព្រះថោង រៀបអភិសេកជាមួយនាងនាគ។

### ១.២.១. ប្រវត្តិសាស្ត្រ

ប្រទេសកម្ពុជា ជាប្រទេសហត្ថលេខីនៃសន្និសញ្ញាអន្តរជាតិស្តីពីផែនការសកម្មភាពប្រជាករ និងអភិវឌ្ឍន៍(ICPD 1994) នៅក្នុងកិច្ចព្រមព្រៀងនោះ ប្រទេសកម្ពុជាបានយល់ព្រមទទួលយកមកអនុវត្តលើច្បាប់អាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា តាមមាត្រាមួយចំនួន បុរសស្ត្រីដែលមានអាយុរៀបការមានសិទ្ធិរៀបការ និងបង្កើតគ្រួសារដោយមិនប្រកាន់សញ្ជាតិ ជនជាតិ និងសាសនាឡើយ។ ការរៀបអាពាហ៍ពិពាហ៍ ត្រូវតែធ្វើឡើងដោយមានការព្រមព្រៀងរវាងសាមីខ្លួនទាំងពីរដោយគ្មានការគំរាមកំហែង និងបង្ខិតបង្ខំពីនរណាម្នាក់ឡើយ។ គ្រួសារជាកោសិកាសង្គមតាមបែបធម្មជាតិ មានសារៈសំខាន់ និងមានសិទ្ធិទទួលការពារពីសង្គម និងពីរាជរដ្ឋាភិបាល។[4] គ្មានការរៀបអាពាហ៍ពិពាហ៍ណាមួយដែលត្រូវធ្វើឡើងដោយគ្មានការព្រមព្រៀង និងដោយ

[2] ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ មាត្រា ៣។

[3] សេចក្តីកំណត់ក្រមរដ្ឋប្បវេណី គន្លឹទី៧ ឆ្នាំ២០១០ មាត្រា ៩៤៨។

[4] សេចក្តីប្រកាសជាសាកលស្តីពីអំពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨ មាត្រា១៦។

គ្មានការស្ម័គ្រចិត្តពីភាគីទាំងសងខាងទេ។[5] បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ទោះបីមានគ្រួសារមួយចំនួនជ្រើសរើសគូរស្រករតាមរយៈម្ដាយឪពុកក៏ដោយ ក៏សាមីខ្លួនភាគច្រើនបានធ្វើការសម្រេចចិត្តដោយខ្លួនគេផ្ទាល់ក្នុងការជ្រើសរើសគូរអនាគតផងដែរ។[6]

### ១.២.២. រឿងព្រេងនិទាន

ព្រេងនិទាន ពង្សាវតារអំពីពិធីរៀបមង្គលការនៅកម្ពុជាដែលមានដើមកំណើតនៅដើមសតវត្សរ៍ទី១ ក្នុងគ្រិស្តសករាជ ៥២ នាសម័យកាល អាណាចក្រនគរភ្នំ ឬអាណាចក្រហ្វូណន (Funan Kingdom) នៃកំណត់ត្រារបស់ចិនដែលមានតំណាលរឿងព្រេងនិទានខ្មែរ ព្រះថោង និងនាងនាគ។ ថ្ងៃមួយព្រះថោងបាននាំពលរេហ៍ទៅក្រសាលតាមឆ្នេរខ្សាច់កោះបានយាងទៅដល់ទួលដំបូកគោកធ្លកដោយហេវហត់អស់កម្លាំងព្រះអង្គចូលទៅសំរាកក្រោមដើមធ្លកដល់ពេលរសៀលទើបព្រះអង្គភ្ញាក់ តែទឹកបានឡើងលិចព័ទ្ធជុំវិញទួលគោកធ្លកដោយមិនអាចវិលត្រលប់វាំងប្រាសាទបានព្រះថោងក៏ទ្រង់សំរាកនៅទីនោះរង់ចាំពេលទឹកស្រកដកទៅវិញ។ គ្រានោះនារាត្រីដ៏សែនស្ងាត់ជ្រងំព្រះនាងធារាវត្តី បុត្រីស្តេចភុជង្គនាគបាននាំអស់ពួកភីលៀងបរិវារចេញមកក្រសាលលេងកម្សាន្តលើកោះគោកធ្លក។ ព្រះថោងទតយល់ឃើញព្រះនាងកាលណាក៏លបលួចចាប់ចិត្តប្រតិព័ទ្ធស្នេហាភ្លាម។ ក្រោយដែលបានផ្ដោះផ្ដងសាកសួរគ្នាទៅវិញទៅមកព្រះថោង និងនាងនាគក៏ចាប់ផ្ដើមមានចិត្តស្នេហាស្មោះស្ម័គ្រនឹងគ្នាទៅវិញទៅមក។

ក្នុងរវាងប្រាំពីរថ្ងៃតាមពេលកំណត់រវាងគូស្នេហាទាំងពីរព្រះថោងត្រូវរៀបចំជំនូន និងបណ្ណាការគ្រប់បែបយ៉ាងមករង់ចាំនៅត្រង់ទីកន្លែងដដែល។ ចំណែកព្រះនាងធារាវត្តីកាលបើទៅដល់ឋានភុជង្គនាគក៏បានរ៉ាយរ៉ាប់រឿងរ៉ាវទាំងប៉ុន្មានតាមដំណើរទូលថ្វាយព្រះបិតា និងព្រះមាតា។ ស្ដេចភុជង្គនាគមិនបានយល់ជំទាស់ទេ។ ព្រះអង្គបានសុខចិត្តយល់ព្រមទៅតាមសំណូមពរគោលបំណងរបស់កូន។ ប្រាំពីរថ្ងៃកន្លងមក ព្រះថោងបាននាំពលរេហ៍សេនាលើកជំនូនសួយសារអាករគ្រប់បែបយ៉ាងរៀបចំដោយប្រណិតយ៉ាងបរិបូរណ៌ឥតមានខ្ចោះឥតមានខ្វះត្រង់ណាយកមកទុកត្រៀមខ្លួនរង់ចាំនៅក្រោមដើមធ្លក។ ដល់ថ្ងៃកំណត់ស្ដេចភុជង្គនាគ និងអគ្គមហេសីបានយាងចេញមកត្រង់កន្លែងដើមធ្លកមែនបានយល់ឃើញព្រះមាតាព្រះបិតាព្រះនាងធារាវត្តីភ្លាមកាលណាព្រះថោងទ្រង់លុតជង្គង់ក្រាបថ្វាយបង្គំដោយក្ដីគោរព។

ស្ដេចភុជង្គនាគ និងមហេសីពេញចិត្តត្រេកអរសាទរណាស់ បានទទួលព្រះថោងជាកូនប្រសាហើយក៏បានរៀបចំអភិសេកកូនស្រីកូនប្រុសជាគូស្វាមីភរិយាតរៀងមក។ ស្ដេចភុជង្គនាគព្រមទាំងបរិវារដើម្បីទុកជាចំណងដៃដល់កូនប្រុសស្រីបាននាំពលរេហ៍សេនា បឺតពង្រីងទឹកសមុទ្របង្កបង្កើតអោយកើតបានជាដីស្ងួតធំធេងទូលំទូលាយហើយបានកសាងប្រាង្គប្រាសាទ វាំងតូចធំទុកថ្វាយជាច្រើន។ ព្រះថោងនាងនាគ ត្រូវបាន

[5] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម ឆ្នាំ២០០៩។

[6] សៀវភៅ អរិយធម៌ខ្មែរ ដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកវិទ្យាស្ថានភាសាបរទេស ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឆ្នាំ២០១៣។

រៀបចំអភិសេក ជាគូស្វាមីភរិយានៅវេលាម៉ោង ៧ព្រឹក នៅថ្ងៃ១១កើត ខែពិសាខ ពស២៧៧ ឆ្នាំម្សាញ់ ត្រូវជាឆ្នាំ ២៦៧ មុនគ.ស។

### ១.២.៣. ប្រវត្តិពិធីផ្សេងៗនៃពិធីរៀបអាពាហ៍ពិពាហ៍

ពិធីផ្សេងៗជាច្រើនត្រូវបានបញ្ចូលក្នុងអាពាហ៍ពិពាហ៍ខ្មែរហើយដែលត្រូវបានមនុស្សខ្មែរប្រារព្ធជាប់ជាទំនៀមរហូតមក។ ពិធីទាំងនោះសុទ្ធតែទាក់ទងទៅនឹងរឿងព្រេងបុរាណខ្មែរ ដោយយើងខ្ញុំសូមលើកយកមកបង្ហាញដូចខាងក្រោមនេះ៖

ក. រឿងព្រេងទាក់ទងនឹងពិធីស៊ីស្លាដក់ ស្លាកន្សែង "បុរសឃ្វាលគោនិងបុរសឃ្វាលក្របី"

តាមដំណាលរឿងបានពោលថា មានបុរសពីរនាក់បានជួបគ្នាពេលទៅ ឃ្វាលគោ ឃ្វាលក្របី ហើយក៏បានសុំគ្នាធ្វើជាក្លើ (មិត្ត)។ ពួកគេទាំងពីរបាន និយាយប្រាស្រ័យទាក់ទងគ្នាដឹងថា បុរសទាំងពីរនាក់នោះ ម្នាក់មានកូនស្រី រីឯម្នាក់ទៀតមានកូនប្រុស។ ពួកគេបាននិយាយផ្សំផ្គុំកូនប្រុសស្រីរបស់ខ្លួន ជាគូសម្ព័ន្ធនឹងគ្នា។ ដើម្បីជាគ្រឿងបញ្ជាក់ចិត្តនឹងភ្ជាប់កិច្ចសន្យាជាមួយគ្នា បុរស ដែលមានកូនប្រុសបានស្រាយយកស្លាដែលចងវេចថ្នក់ ដក់នឹងកន្សែង ឱ្យ បុរសមានកូនស្រីធី ទុកជាកិច្ចសញ្ញាដល់គ្នានឹងគ្នាតទៅ។ បុរសដែលមានកូន ស្រីក៏ព្រមទទួលតាម។ ដោយសារតែហេតុដូច្នេះហើយ ទើបក្នុងពិធីអាពាហ៍ពិពាហ៍ខ្មែររហូត មកដល់សព្វថ្ងៃ មានធ្វើកិច្ចពិធីពិសាស្លាកន្សែងដើម្បីជាសក្ខីភាពបញ្ជាក់ថា មាតាបិតាកូនប្រុសកូនស្រីទាំងសងខាងយល់ព្រមធ្វើជាដន្លងនឹងគ្នា។

ខ. រឿងព្រេងទាក់ទងនឹងពិធីក្រុងពាលី

តាមដំណាលរឿងព្រេងនេះមាននិទានក្នុងគម្ពីរសូត្រសព្វថា ក្នុងគ្រា លង្វែកសាសនា ព្រះសមណគោតមបរមពោធិសត្វជាម្ចាស់នៃយើង អន្ទោល យកកំណើតជាស្តេចស្វា ខ្មៅ រីឯស្តេចក្រុងពាលីបានកើតជាស្តេចស្វាស ដែលស្តេចស្វាទាំងពីរនេះមានពលសេនាឬបរិស័ទរៀងៗខ្លួន ដោយរស់នៅ បាំងសមុទ្រម្ខាងម្នាក់។ ពួកស្វាទាំងពីរកងនេះតែងតែប្រឈមមុខឈ្លោះទាស់ ទែងគ្នា ប្រខាំយកឈ្នះចាញ់ គ្រប់ពេលដែលរកស៊ីជួបមុខគ្នា។ ដោយសារ មានជម្លោះទាស់ទែងគ្នាញឹកញាប់ពេកទៅ កងស្វាខ្មៅក៏ប្រជុំលើកគ្នាទៅប្តឹង ព្រះពោធិសត្វដែលជាចៅហ្វាយនាយរបស់ខ្លួនថា មានហ្វូងស្វា-ស ព្រហើន កោងកាចសាហាវ ចេះតែរុករានទន្ទ្រានទី ហើយឈ្លោះទាស់ទែង ខាំសម្លាប់ គ្នាយើងខ្ញុំមិនលោះពេលសោះឡើយ។ ព្រះពោធិសត្វបានស្តាប់យល់ហេតុ ការហើយ ក៏សួរកូនចៅរបស់ខ្លួនថា តើពពួកស្វា-សទាំងនោះមានមេកើយ ត្រួតត្រាដែរឬទេ។ កូនចៅរបស់ព្រះពោធិសត្វពោលតបថា មាន តែពួកគេមិន ដែលបានឃើញទេ គឺឮតែតាមគេប៉ុណ្ណោះ។ ព្រះពោធិសត្វបានព្រមទទួលបណ្តឹងរបស់បរិស័ទដោយប្រាប់ថា "ចាំយើងទៅជម្រះរឿងនេះឱ្យ"។ ព្រះពោធិសត្វបានអធិដ្ឋានបារមីឱ្យខ្លួនឯងអាចហោះបាននាពេលនោះ ហើយក៏ហោះឆ្ពោះទៅកាន់ពពួកស្វា-ស។ ចំណែកពួកស្វា-សពេលឃើញព្រះពោធិសត្វក៏មានភាពភ័យស្លន់ស្លោ រត់ទៅប្រាប់ស្តេចស្វារបស់ខ្លួនថា មានស្វា ខ្មៅមួយធំណាស់ មិនដឹងមកពីទីណាទេមានឫទ្ធានុភាពពូកែ ចេះហោះហើរ ដើរលើអាកាសវេហា ហើយបានចុះមកចំកណ្តាលហ្វូងស្វា-សយើង ហើយ ស្វា-សយើងទាំងប៉ុន្មានប្រហែលចុះចូលគេអស់ហើយក៏មិនដឹង។ ឮដូច្នេះ ស្តេចស្វា-សខឹងច្រឡោត

យ៉ាងខ្លាំងដោយស្រែកថា នៅទីនេះមានតែអញម្នាក់ គត់ដែលធំ រួចចុះអាណាក្លាហានអាងចេះហោះហើរមក ប្រមូលពលរបស់ អញតាមអំពើចិត្តបែបនេះ។ ស្តេចស្វា-សកំពុងតែក្រេវក្រោធដូច្នេះ ក៏ស្រាប់តែ មានស្វា-ខ្មៅមួយដែលជាកូនចៅរបស់ព្រះពោធិសត្វបានមកទូលស្តេចស្វា-ស ថា ស្តេចស្វាខ្មៅនៅទីព្រៃបាំងសមុទ្ទម្ខាងនោះ សុំចូលមកជួបស្តេចស្វា-ស ដោយការស្លូតត្រង់ទេ សូមស្តេចស្វា-ស មេត្តាកុំចាប់ទោសអួសដំណើរអី។ ស្តេចស្វា-សឮដូច្នោះក៏យល់ព្រមឱ្យស្តេចស្វាខ្មៅចូលមក។ ពេលមកដល់ជួប មុខគ្នា ស្តេចស្វាទាំងពីបានគោរពគ្នាទៅវិញទៅមក ហើយស្តេចស្វា-ខ្មៅបាន និយាយថា "អ្នកអើយ! ខ្ញុំឮគេហៅឈ្មោះអ្នកពីរោះក្រអូបទៅដល់ខ្ញុំញឹកញយ ណាស់ ថាអ្នកជាស្តេចស្វាមានចិត្តល្អ សប្បុរសធម៌ មិនដែលព្យាបាទ អាឃាត ចងពៀរជាមួយសត្វដូចគ្នាឡើយ ដោយហេតុនេះហើយទើបខ្ញុំមកសុំអ្នកធ្វើជា មិត្តសំឡាញ់នឹងគ្នា គ្រាន់មានទុក្ខធុរៈអ្វី ជួយការពារគ្នា រក្សាគ្នា។ លុះឮពាក្យ ពោលសរសើរដូច្នេះ ស្តេចស្វា-ស ក៏ទន់ចិត្តយល់ព្រម។ ព្រះពោធិសត្វក៏បាន សម្តែងពីកល្យាណមិត្តឱ្យស្តាប់ រហូតធ្វើឱ្យស្តេចស្វា-សជក់ស្លុងលង់អារម្មណ៍ ទន់ចិត្ត ពោលពាក្យពិតតបទៅព្រះពោធិសត្វថា "បើសម្លាញ់ជាគ្រូបានត្រាស់ ដឹងនូវសម្ពោធិញ្ញាណទៅអនាគត ក៏សូមកុំឱ្យផុតពីសេចក្តីទំនុកបម្រុងគ្នាទៅ វិញទៅមកឡើយ!" លុះកន្លងជាតិមក បរមពោធិសត្វមកកើតជាព្រះសិទ្ធិត្ថ គឺជាតិដែលបាន ត្រាស់ជាព្រះពុទ្ធ។ រីឯស្តេចស្វា-សបានទៅកើតជាតិជាស្តេចក្រុងពាលី ដែល សោយរាជ្យកណ្តាលចក្រវាឡ មានរូបសណ្ឋានជាមនុស្សពាក់កណ្តាល ជា សត្វតិរច្ឆានពាក់កណ្តាល គឺមុខមាត់និងសម្បៀកបំពាក់ពេញជាមនុស្ស, ម្រាមដៃ ម្រាមជើង និងកន្ទុយពេញជាស្វា-ស ហើយតាំងខ្លួនជាស្តេចបរមចក្រ អួតអាងអំណាចឫទ្ធានុភាព វាតទីយកទឹកដីទាំង៤ទ្វីបមកកាន់កាប់។ ស្តេច ក្រុងពាលី ឬស្តេចស្វា-សនោះមានកូន៧នាក់ គឺប្រុស៦នាក់ និងកូនស្រីពៅ ម្នាក់ ដោយម្នាក់ៗទទួលបានចំណែកទឹកដីដែលឪពុកផ្តល់ឱ្យគ្រប់គ្រងរៀង ខ្លួន រួមទាំងនាងនាថវតីជាកូនស្រីពៅគ្រប់គ្រងទឹកដីខាងជម្ពូទ្វីប ឱ្យមាននគរ ១៦ នឹងបានផ្សំផ្គុំកូនស្រីនោះឱ្យទៅជម្ពូបាបកាស ដែលជាស្តេចនាគរាជ។ សម័យនោះព្រះសម្មាសម្ពុទ្ធជាម្ចាស់បានត្រាស់ដឹងឡើងនូវរឿងរ៉ាវក្នុង លោកិយទាំងមូលទ្រង់ក៏យាងទៅគ្រប់នគរទាំង១៦ ដោយមានព្រះទ័យ សន្តោសប្រោសសត្វដោយមេត្តា បានដោយការពេញចិត្តពីឧបាសក និង ឧបាសិកាគ្រប់ៗគ្នាក៏លះបង់ចោលលទ្ធិបុរាណ បែរមកកាន់គោរពតាមឱវាទ ទូន្មាននៃព្រះសម្ពុទ្ធវិញ។ ជម្ពូបាបកាសដឹងដូច្នេះក៏ទៅទូលស្តេចពាលីដែល ជាឪពុកក្មេក។ បានស្តាប់ដឹងឮគ្រប់ការហើយស្តេចពាលីខឹងយ៉ាងខ្លាំងក៏ចាត់ ឱ្យគេតាមរកព្រះសម្ពុទ្ធ។ ព្រះសម្ពុទ្ធទ្រង់ញាណដឹងថាស្តេចពាលីកំពុងចង់ជួបក៏បំប្រួញផែនដីដើម្បីឱ្យស្តេចពាលីឆាប់ជួបព្រះសម្ពុទ្ធ ត្បិតព្រះអង្គនៅចាំ សន្យាថាជួយសង្គ្រោះក្រុងពាលីតាំងពីយកកំណើតជស្តេចស្វា-ស ខ្មៅម្លេះ។ ព្រះអង្គទ្រង់គង់នៅមាត់សមុទ្រ រំពេចនោះក៏លេចស្តេចក្រុងពាលីហោះមករក ព្រះអង្គ។ កាលបើឃើញព្រះសម្ពុទ្ធហើយ ស្តេចពាលីក៏រលត់រលាយកំហឹង ទោសៈអស់ពីខ្លួនមួយរំពេចត្បិតឃើញព្រះភក្ត្រព្រះអង្គជាក់ ធ្លាក់ទឹកចិត្តក្តុក លាន់មាត់សរសេរថា "យី! អ្នកនេះរូបអីក៏ល្អជាងទេវតាទៅទៀតម្លេះ ហើយ ប្រកបដោយឥរិយាបទសមរម្យទាំងព្រម!" ថែមទាំងសួរព្រះសម្ពុទ្ធថា "អ្នកឯង ហ្នឹងឬដែលឈ្មោះសមណៈគោតម?"។ ព្រះពុទ្ធតបថា "ថ្វាយពរ! តថាគតហ្នឹង ហើយ!"។ ស្តេចពាលីក៏តបថា "តើអ្នកឯង ហេតុអ្វីក៏ដើរបញ្ចុះបញ្ចូលមនុស្ស យកទឹកដីកូនយើងអស់ដូច្នេះ?"។ ព្រះសមណៈគោតមក៏ឆ្លើយតបថា "ទូល មហា

បពិត្រ! តថាគតមិនមែនចង់បានទឹកដីនោះធ្វើអីទេ, តថាគតជាកូនស្តេច មហាចក្រពត្រាធិរាជ បើសិនតថាគត ចង់បានទឹកដី មិនមែនលះរាជសម្បត្តិ ចេញមកបព្វជ្ជាទេ ប៉ុន្តែការតាថាគតដែលបានត្រាស់ដឹងជាព្រះពុទ្ធហើយ ត្រូវតែខំដើរប្រោសសត្វឱ្យរួចផុតពីចំណងទុកតែប៉ុណ្ណោះ, តថាគតមិនមែន ប្រាថ្នាចង់បានទឹកដីនោះទេ"។ ព្រះពុទ្ធទ្រង់ក៏បានលើកនិទានតាំងពីអតីតជាតិ ដែលបានយកកំណើតជាស្តេចស្វា-ស ស្វាខ្មៅ ជាសំឡាញ់នឹងគ្នា ដែលកាល ណោះស្តេចស្វា-ស បានសន្យានឹងតថាគតថា "ក្នុងអនាគតជាតិ សូមកុំឱ្យផុត សេចក្តីទំនុកបម្រុង គ្នាឡើយ, ឥឡូវនេះតថាគត បានត្រាស់ជាព្រះពុទ្ធហើយ តថាគតមិនភ្លេចសច្ចានោះទេ។" បានស្តាប់យល់ការ ហើយ ស្តេចក្រុងពាលីឱនសិរសា យំខ្សឹកខ្សួល អាណិតជាតិខ្លួនណាស់ ក៏ពោលពាក្យសុំព្រះពុទ្ធអត់នូវទោស ចំពោះខ្លួន នឹងសុំរស់នៅជាមួយព្រះអង្គផង។ ដោយសារតែស្តេចក្រុងពាលីមានរូបកាយ ជាតិជាមនុស្សពាក់កណ្តាល និងសត្វតិរច្ឆានពាក់កណ្តាល ព្រះពុទ្ធមិនអាចឱ្យ បួសជាបព្វជិតក្នុងសាសនាបានឡើយ តែព្រះជួយ សង្គ្រោះដោយផ្តល់សីល៥ កម្មបថ១០ ទុកធ្វើជាពូជទៅអនាគតចុះ។ តថាគតបានប្រកាសប្រាប់អស់ពុទ្ធ បរិស័ទទាំងអស់ក្នុងសាសនាឱ្យដឹងគ្រប់គ្នាថា "ចាប់តាំងពីថ្ងៃនេះតទៅ បើអ្នក ឯណាមានសទ្ធាជ្រះថ្លានឹងថ្វាយ មហាទានចំពោះតថាគត ឬអគ្គសាវ័កក្តី ភិក្ខុសាមណេរបុថុជ្ជនក្តី ត្រូវឱ្យឧទ្ទិសចំណែកកុសលទៅជួយរំដោះទុក្ខ ស្តេច ក្រុងពាលីផង។" ស្តេចពាលីក៏មានចិត្តត្រេកអរទទួលសាធុ។ ក្រោយនោះមក ពួកឧបាសក ឧបាសិកា កាលណាត្រូវធ្វើបុណ្យទាន ប្រគេនភិក្ខុសង្ឃ-សាមណេរ គេតែងតែឧទ្ទិសចំណែកផលទៅដល់ស្តេចក្រុង ពាលី គ្រប់គ្នារៀងដរាបមក តាមបង្គាប់ព្រះសម្មាសម្ពុទ្ធដែលទ្រង់បញ្ញត្តទុកឱ្យ នោះឯង។ ប៉ុន្តែក្រោយពេលព្រះពុទ្ធអង្គ ចូលបរិនិព្វានទៅ មិនយូរប៉ុន្មាន មានជនអគតិដែលកាន់គោរពសាសនាផ្សេងនាំគ្នាពោលបន្ទុះបង្អាប់សាសនា ព្រះពុទ្ធ ធ្វើពិធីប្រឡូកច្រឡំជាមួយគ្នាក្នុងសាសនាផ្សេង យូរៗតមកទៀតមិន ត្រឹមតែឧទ្ទិសផល តែបែរជាជ្រុល ដល់ទៅរៀបសែនព្រេងឱ្យស្តេចក្រុងពាលី ទៀត ហើយនាំគ្នាស្រែកពោលថា "ព្រះបង្គាប់ឱ្យធ្វើដូច្នេះព្រោះគេជាធំ ត្រួតត្រា ទឹកដី។" មិនត្រឹមតែប៉ុណ្ណោះទេ ក្នុងការរៀបពិធីអាពាហ៍ពិពាហ៍ ក៏តាំងរៀប ពលីការបួងសួងសែនព្រេង ឱ្យស្តេចក្រុងពាលីមុនព្រះសង្ឃទៅវិញ។[7]

គ. រឿងព្រេងទាក់ទងនឹងពិធីបង្វិលពពិលក្នុងអាពាហ៍ពិពាហ៍ខ្មែរ

ខ្លឹមសាររឿងបាននិទានមកថា ព្រះឥសូរ ដែលគង់ជាស្តេចនៅឋាន កៃលាស ជាប់ចង្កេះភ្នំហិមាល័យ មានឫទ្ធានុភាពខ្លាំងពូកែ និងមានមហេសី ឈ្មោះនាង "ឧមាភោគវតី" ដែលមានន័យថា ស្ត្រីគ្រប់លក្ខិណា ប្រសើរ លើសទេវតា និងស្ត្រីទាំងពួងក្នុងទ្វីបទាំងបួនលើលោកា។ ព្រះឥសូរ មានឫទ្ធានុភាពខ្លាំងណាស់ សូម្បីតែ អង្គជាតិ (លិង្គ) របស់លោក និងយោនី របស់នាងឧមាភោគវតី ក៏ខ្លាំងពូកែរសក្តិសិទ្ធិដែរ។ ថ្ងៃមួយព្រះឥសូរ ទទួល បង្រៀនសិស្សម្នាក់ឈ្មោះព្រះជ័យសុរិយារាជកុមារនៅឯនគរកែកេតជម្ពូ នាជម្ពូទ្វីប។ បន្ទាប់ពីរៀនចេះ សព្វគ្រប់វិជ្ជាហើយ ព្រះជ័យសុរិយារាជកុមារ ក៏ក្រាបបង្គំសុំពរជ័យមង្គលមួយទុកជាព្រះកេរ្តិ៍សម្រាប់ជម្ពូទ្វីប ដើម្បីយកទៅ ប្រសិទ្ធិពរក្នុងវេលារៀបអាពាហ៍ពិពាហ៍ ពួកជាតិមនុស្សទាំងពួងឱ្យបានរុង រឿងដូចពិធីមង្គលការឯ

[7] សៀវភៅ ប្រជុំរឿងព្រេងខ្មែរ ភាគ ៩ នៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ។

ឋានកៃលាសផង ព្រោះកំណើតមនុស្សលោកកើត ឡើងថយថោកណាស់ គ្មានរិទ្ធីអំណាចអ្វីទេ។ យល់សេចក្តីរៀបរាប់ពីព្រះជ័យ រាជកុមារហើយ ព្រះឥសូរក៏បានហោះទៅយកខ្សាច់ពេជ្រពីចក្រវាឡ មកប្រសិទ្ធិជាស្លឹកពោធិមាសជាតំណាងយោនីព្រះនាងឧមាគោតវតី នឹងយកថ្ម ពេជ្រពីភ្នំហិមាល័យ មកប្រសិទ្ធិជាទៀនមាស ជាតំណាងលិង្គរបស់ព្រះអង្គ។ លុះលោកប្រសិទ្ធិរួចហើយ ក៏សន្មតឱ្យឈ្មោះថា "ពរពីរតន៍" មានន័យថា "ពរពីរនេះភ្លឺដូចប្រាថ្នា"។ ប៉ុន្តែការហៅតគ្នាយូៗមក ក៏នៅត្រឹមថា "ពពិលៗ" រហូតមកដល់សព្វថ្ងៃតែម្តងទៅ។ ព្រះឥសូរបានបង្គាប់ព្រះជ័យសុរិយារាជ កុមារទៀតថា ចូរអ្នកយកទៅទុកនៅឯឋានជម្ពូទ្វីបទុកជាកេរ្តិ៍តរៀងទៅ ដោយ ត្រូវយកទៀនមាស បិទនឹងស្លឹកពោធិមាស ហើយយកភ្លើងអុជឱ្យឆេះមុននឹង បង្វិលបីជុំសាមីខ្លួនដែលកំពុងរៀបមង្គលការ រួចសឹមពន្លត់ទៅវិញ បន្ទាប់មក ត្រូវយកផ្សិតបក់ផ្សែងឱ្យចូលមាត់ច្រមុះសាមីខ្លួនទាំងប្រុសស្រី ដើម្បីឱ្យមាន កម្លាំងកាមារាលរាល ខ្លាំងដូចដំរីសារ មានបុត្រាបុត្រីប្រកបដោយបញ្ញាវាងវៃ និងរស់នៅជាមួយគ្នាមានសុភមង្គលតរៀងទៅ។ កាលវេលាដ៏យូរក្រោយកទៀត ទើបអស់ទៀនទៅ ស្តេច មន្ត្រី សេដ្ឋីនិង បណ្តាជនទាំងអស់ក៏នាំគ្នារចនាធ្វើទៀនដោយខ្លួនឯងជំនួស សម្រាប់ប្រើក្នុង ពិធីរៀបអាពាហ៍ពិពាហ៍កូនប្រុសស្រីរហូតមក។ អាស្រ័យរឿងនេះហើយ ទើបបានជាជាប់មានទំនៀមទំលាប់បង្វិលពពិលរហូតដល់សព្វថ្ងៃនេះ។[8]

ឃ. ទម្រង់ផ្សេងៗនៃអាពាហ៍ពិពាហ៍ខ្មែរ

ទម្រង់អាពាហ៍ពិពាហ៍ខ្មែរ មានការវិវត្តប្រែប្រួលទៅតាមសម័យកាល ចាប់តាំងពីសម័យលង្វែករហូតមកដល់បច្ចុប្បន្ន ដោយសារទំនោរសង្គម វប្បធម៌ សង្គមសេដ្ឋកិច្ច និងសង្គមប្រវត្តិសាស្ត្រផងដែរ។ ទម្រង់ទាំងនោះមាន ចំនួន៦ គឺៈ

១. អាពាហ៍ពិពាហ៍បែបបុរាណ

២. អាពាហ៍ពិពាហ៍បែបលើកត្រៃ

៣. អាពាហ៍ពិពាហ៍បែបសែន

៤. អាពាហ៍ពិពាហ៍បែបកំព្រាគូ

៥. អាពាហ៍ពិពាហ៍បែបផ្តាច់ការ សមូហភាព

៦. អាពាហ៍ពិពាហ៍បែបសម័យទំនើប។

## ១.៣. ការវិវត្តន៍នៃរបបគតិយុត្តអាពាហ៍ពិពាហ៍

ក្នុងចន្លោះការវិវត្តន៍នៃរបបគតិយុត្តអាពាហ៍ពិពាហ៍ ដែលយើងបានផ្តោតទៅលើទិដ្ឋភាពច្បាប់ដែលមានសម្រាប់ការអនុវត្តសម័យកាលនោះ ដើម្បីជាមូលដ្ឋានក្នុងការយកមកពន្យល់ ពិភាក្សាទៅលើផ្លូវច្បាប់ដែលបានកើតមាននៅក្នុងអំឡុងពេលនោះ។ ដោយមិនបានលើកយកជាប្រវត្តិសាស្ត្រមកបង្ហាញទាំងស្រុងនោះទេ ពោលត្រូវបានលើកជារបបគតិយុត្តដែលបានអនុវត្តក្នុងអំឡុងសម័យកាលនោះ ដើម្បីបង្កើតចំណងគតិយុត្តនៃការរៀបអាពាហ៍ពិពាហ៍មួយដែលបានកើតឡើងក្នុងសម័យកាលនោះ ជាទិដ្ឋភាពផ្លូវច្បាប់ និងការវិវត្តន៍របស់ច្បាប់។

[8] សៀវភៅ ប្រជុំរឿងព្រេងខ្មែរ ភាគ ៩ នៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ។

**១.៣.១. របបគតិយុត្តពីឆ្នាំ (១៩២០ - ១៩៧៥)**

នៅប្រទេសកម្ពុជាចន្លោះពីឆ្នាំ១៩២០ ដល់ឆ្នាំ១៩៧៥ ស្ថិតនៅក្នុងសម័យសង្គមរាស្ត្រនិយម និងសម័យសាធារណៈរដ្ឋខ្មែរ ត្រូវបានអនុវត្តតាមក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ក្នុងពេលនោះប្រទេសកម្ពុជាកាន់របបរាជានិយម ដែលពេលនោះច្បាប់ត្រូវបានធ្វើឡើងដោយប្រកាន់ទៅលើទំនោរនយោបាយ និងអំណាចរបស់អ្នកដឹកនាំបានជាហេតុនេះ បានជាច្បាប់ធ្វើឡើងមានការឱ្យតម្លៃលើបុរសធំជាងស្ត្រី ដោយសារអំឡុងពេលនោះប្រទេសកម្ពុជានាសម័យនោះប្រកាន់របបរាជាណាចក្រដែលស្តេចមានអំណាចទើបច្បាប់ក៏តែងតែតម្រូវតាមផ្នត់គំនិតរបស់ថ្នាក់ដឹកនាំ និងតម្រូវការតាមស្ថានភាពជាក់ស្តែងនៃសម័យនោះផង។ នៅក្នុងឯកសារ និងខ្លឹមសារនៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ក្នុងសម័យសង្គមរាស្ត្រនិយមដែលអនុម័តដោយរដ្ឋសភាជាតិ នាសម័យនោះឈរលើគោលការណ៍ បុរសមានសិទ្ធិជាងស្ត្រី គឺបុរសមានសិទ្ធិរៀបការប្រពន្ធបានច្រើន ចំណែកនារីមានសិទ្ធិជ្រើសរើសគូស្រករបានតែម្នាក់គត់។[9] អំណាចរបស់ប្តីធំជាងប្រពន្ធក្នុងការចាត់ចែងគ្រួសារ គឺប្រពន្ធគ្មានសិទ្ធិផ្តល់យោបល់ឱ្យប្តីស្តាប់ទេ បើប្តីមិនចង់ស្តាប់ គឺស្រេចតែប្តី ប៉ុន្តែបើប្តីឱ្យដំបូន្មានប្រពន្ធត្រូវស្តាប់ ទោះបីដំបូន្មាននោះខុស ឬត្រូវក៏ដោយ។[10] បុរសត្រូវមានអាយុ ១៧ឆ្នាំហើយ នារីមានអាយុ ១៤ឆ្នាំ ទើបច្បាប់អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បានមានន័យថាការរៀបអាពាហ៍ពិពាហ៍នោះ ករណីបុរសមានអាយុមិនដល់ ១៧ឆ្នាំ ស្រីមានអាយុមិនដល់ ១៤ឆ្នាំ មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។

ក្នុងករណីការប្រកាសជាសាធារណៈវិញ អាពាហ៍ពិពាហ៍អាចនឹងរៀបបានតែនៅថ្ងៃខាងក្រោយនៃការបិទប្រកាសចំនួន ៨ថ្ងៃ។ នាកាល ការចូលដណ្តឹងបានស្រេចហើយ មេបាខាងប្រុស ខាងស្រីក៏បានសម្រេចថ្ងៃ ខែរៀបអាពាហ៍ពិពាហ៍ហើយឪពុក ឬម្តាយខាងប្រុស ខាងស្រី ឬអ្នកដែលបានជួលឪពុកម្តាយត្រូវទៅប្តឹងមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំខាងស្រីអំពីអាពាហ៍ពិពាហ៍នោះ។[11] មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើប្រកាសបិទនៅសាលាឃុំដើម្បីផ្សាយភ្លាម។ ប្រកាសមួយទៀតត្រូវមន្ត្រីអត្រានុកូលដ្ឋានបញ្ជូនទៅឱ្យមេឃុំខាងលំនៅនៃអនាគតប្តីប្រពន្ធឱ្យយកទៅបិទទ្វារសាលាឃុំនោះភ្លាម។ ប្រកាសនេះត្រូវបិទកំណត់ប្រាំបីថ្ងៃ។ លុះផុតកំណត់នេះហើយទើបសាមីខ្លួនអាចរៀបការបាន។ មន្ត្រីអត្រានុកូលដ្ឋាន នាកាលបានទទួលបណ្តឹងទាស់ពីខាងណាហើយត្រូវចុះសេចក្តីបណ្តឹងទាល់នោះយ៉ាងសង្ខេបលើប្រកាសនោះមួយរំពេច។ នៅថ្ងៃដែលរៀបការ រួចស្រេចហើយប្តីប្រពន្ធថ្មីនេះត្រូវទៅប្តឹងមន្ត្រីអត្រានុកូលដ្ឋានជាថ្មីទៀត មន្ត្រីនេះបើឥតមានបណ្តឹងទាស់ទៀតទេ ត្រូវចុះអាពាហ៍ពិពាហ៍នោះ ក្នុងបញ្ជីអាពាហ៍ពិពាហ៍ព្រមទាំងព័ត៌មានដែលបានជូនហើយពីថ្ងៃមុនផង។ មន្ត្រីនេះត្រូវឱ្យប្តីប្រពន្ធថ្មី ឪពុកម្តាយ ឬជនណាដែលបានជំនួសឪពុកម្តាយនិងអ្នកមហា ឬ សាក្សី២នាក់ចុះហត្ថលេខា។ បើមានអ្នកប្តឹង និងសាក្សីមិនចេះសរសេរ និងចុះហត្ថលេខា មិនកើតនោះ ត្រូវឱ្យផ្តិតមេដៃកត់ថាជននោះ ចុះហត្ថលេខាមិនកើតទេ ត្រូវមានអ្នកសរសេរជំនួស រួចអានឱ្យស្តាប់ និងចុះហត្ថលេខានោះ រួចមកត្រូវចុះនិទ្ទេស។

[9] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ មាត្រា ១៤១។

[10] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ មាត្រា ១៨៩។

[11] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ មាត្រា ៦០។

### ១.៣.២. សម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)

ប្រទេសកម្ពុជាកាលពីចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ត្រូវបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប៉ុល ពត ដែលជារបបកម្ពុជាប្រជាធិបតេយ្យ មិនមានច្បាប់ណាមួយក្នុងការអនុវត្តសម្រាប់សម័យនោះឡើយ។ ក្នុងពេលដែលច្បាប់សម័យសង្គមរាស្ត្រនិយម និងសម័យសាធារណៈរដ្ឋខ្មែរត្រូវបានគេឈប់យកមកប្រើប្រាស់ទៀត ហើយទោះបីជាបានអនុវត្តយូរមកហើយក៏ដោយ។ ក្នុងពេលរៀបអាពាហ៍ពិពាហ៍បុរស និងនារីមិនត្រូវបានជ្រើសរើសគ្នាជាមុននោះទេ ពោលគឺនៅថ្ងៃរៀបអាពាហ៍ពិពាហ៍បុរស នារីទាំងអស់ត្រូវជាពីរជួរបន្ទាប់មកប្រធានភូមិបញ្ជាឱ្យអ្នកទាំងនោះចាប់ដៃគ្នាហើយធ្វើការប្ដេជ្ញាថានឹងរួមរស់ជាមួយគ្នាអស់មួយជីវិតនេះបញ្ជាក់ថា បុរស នារីទាំងនោះបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នារួចមកហើយ។

អាពាហ៍ពិពាហ៍ដែលរៀបចំឡើងដោយបក្សកុម្មុយនីស្តកម្ពុជា មានលក្ខណៈខុសប្លែកពីអាពាហ៍ពិពាហ៍តាមបែបប្រពៃណីដូនតាខ្មែរ។ កូនក្រមុំ និងកូនកំលោះតម្រូវឱ្យរៀបការទាំងរាងកាយស្គាំងស្គម ល្វិតល្វៃ ដោយសារការទទួលទានអាហារមិនគ្រប់គ្រាន់ និងធ្វើការងារហួសកម្លាំង។ យុវជន និងយុវជនត្រូវឈរតម្រៀបជួរម្ខាងម្នាក់ដើម្បីត្រៀមខ្លួនទទួលយកអនាគតដែលអង្គការរៀបចំទុកដាក់ឱ្យជាមុន។ អាពាហ៍ពិពាហ៍ធ្វើឡើងមិនឱ្យសាមីខ្លួនដឹងមុន សូម្បីតែឈ្មោះ មុខមាត់នៃអនាគតប្ដី ឬប្រពន្ធមិនស្គាល់ដែរ។ ឪពុកម្ដាយបង្កើត និងមិត្តភក្តិ ក៏មិនបានចូលរួមអបអរសាទរក្នុងពីធីរៀបមង្គលការនោះឡើយ។ មានករណីមួយចំនួនការជ្រើសរើសពីអ្នកដែលមានប្រវត្តិដូចគ្នា និងមកពីវណ្ណៈទាំងបីគឺ វណ្ណៈកណ្ដាលថ្នាក់លើ វណ្ណៈថ្នាក់កណ្ដាល និងវណ្ណៈថ្នាក់ក្រោម មានន័យថា គូស្វាមី ភរិយានីមួយៗ ត្រូវស្ថិតនៅក្នុងប្រវត្តិរូប និងវណ្ណៈស្មើគ្នា។

អង្គការខ្មែរក្រហមចាត់ទុកពិធីរៀបមង្គលការតាមប្រពៃណីខ្មែរ ទៅនឹងការគោរពប្រណិប័តន៍ ជំនឿសាសនា និងការសិក្សាតាមសាលារៀន ឬមហាវិទ្យាល័យ សកម្មភាពទាំងអស់នោះជាការចំណាយពេលឥតប្រយោជន៍ និងគ្មានបានអ្វីទាល់តែសោះ ការចំណាយពេលលើការបង្កបង្កើនផលស្រូវទើបទទួលបានផល ជាក់ស្ដែង (សញ្ញាឃើញ)។ ការរៀបមង្គលការ ដែលត្រូវចំណាយពេលវេលាតិច និងថវិកាតិចតួចទើបទទួលបានពេលវេលា និងថវិការសេសសល់ ស្របតាមការសហករណ៍ "បដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យ" ដែលជាពាក្យស្លោកចម្លងចេញពីបក្សកុម្មុយនីស្តចិនដឹកនាំដោយលោក ម៉ៅ សេតុង មេដឹកនាំផ្ដាច់ការរបស់ប្រទេសចិន។

ជាការសន្និដ្ឋានការរៀបមង្គលការក្នុងសម័យខ្មែរក្រហម ត្រូវបានរៀបចំដោយអង្គការ គូស្វាមី ភរិយា មានសិទ្ធិត្រឹមតែឆ្លើយថាយល់ព្រម និងប្ដេជ្ញាបង្កើតធនធានមនុស្សសម្រាប់បម្រើមនោគមន៍វិជ្ជា។ គោលការណ៍របស់ខ្មែរក្រហមបង្កើតមនុស្សដើម្បីទប់ទល់នឹងសត្រូវខាងក្រៅ (ប្រទេសវៀតណាម ប្រទេសថៃ ប្រទេសឡាវ និងពួកបច្ចិមប្រទេស) និងស៊ីរូងផ្ទៃក្នុង (អ្នកស៊ើបការ គិញសម្ងាត់ អ្នកក្បត់អង្គការ) បង្កើតធនធានមនុស្សថ្មីបរិសុទ្ធសម្រាប់កសាងប្រទេសជឿនលឿនលើគ្រប់វិស័យ។

**១.៣.៣. របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា** (**១៩៧៩ - ១៩៨៩**)

ក្រោយមកសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨១។ ប៉ុន្តែមិនមានចែងអំពីការរៀបអាពាហ៍ពិពាហ៍ដែលត្រូវបានការពារតាមរដ្ឋធម្មនុញ្ញឡើយ។ ប្រជាជនខ្មែរយើងបានយកចិត្តទុកដាក់លើអាពាហ៍ពិពាហ៍តាមគន្លងប្រពៃណីគឺលោកចាប់ផ្សំផ្គុំកូនចៅតាមគន្លងប្រពៃណីបុរាណវិញ ហើយពិធីមង្គលការនេះគេច្រើននិយមធ្វើតែមួយថ្ងៃមួយយប់ ដោយសារពេលនោះប្រជាពលរដ្ឋពុំមានធនធាន ព្រោះតែពេលនោះប្រទេសទើបតែងើបពីសង្គ្រាមស៊ីវិលយ៉ាងរាំរ៉ៃ។ ជាហេតុដែលធ្វើឱ្យប្រពៃណីទំនៀមទម្លាប់មួយនេះពុំត្រឹមត្រូវតាមក្បួនខ្នាតបែបនេះ កត្តាមកពីការសំយោគគ្នារវាងវប្បធម៌ខ្មែរ និងវប្បធម៌បរទេស ហើយរួមផ្សំទាំងលោកអាចារ្យរៀបចំកម្មវិធីមង្គល គាត់បានអនុវត្តកម្មវិធីធ្វើតាមគ្នា តាមអ្វីដែលលោកចាំតៗគ្នា ការរៀបអាពាហ៍ពិពាហ៍ក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា តាមទីស្នាក់ការឃុំនីមួយៗមានក្រុមប្រឹក្សាសមាគមយុវជនយុវនារីដែលជាអ្នកមានសមត្ថកិច្ចអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ដោះស្រាយលើបណ្តឹងទាស់ដោះស្រាយរាល់ពាក្យបណ្តឹងលែងលះ(ការផ្សះផ្សា និងអនុញ្ញាតឱ្យលែងលះ) ហើយប្រធានយុវជន យុវនារី គឺជាមេឃុំ។ សម័យកាលនោះយុត្តិធម៌ឃុំ ស្រុក សង្កាត់ ជាអ្នកផ្សព្វផ្សាយដោះស្រាយរឿងរដ្ឋប្បវេណីនិងរឿងគ្រួសារ ដើម្បីរក្សានូវសណ្តាប់ធ្នាប់សង្គម។ តែបើរឿងណាមានលក្ខណៈស្មុគស្មាញទើបបញ្ជូនទៅតុលាការ មានន័យថាគ្រប់រឿងរដ្ឋប្បវេណី និងរឿងគ្រួសារ គេប្រគល់សមត្ថកិច្ចទៅឱ្យយុត្តិធម៌មូលដ្ឋានផ្សះផ្សាដោះស្រាយឱ្យអស់លទ្ធភាពជាមុនសិន។ បើផ្សះផ្សានិងដោះស្រាយមិនបានសម្រេច ទើបធ្វើរបាយការណ៍វាយតម្លៃពីការមិនស្រុះស្រួលគ្នា បញ្ជូនទៅតុលាការប្រជាជន។ ក្នុងករណីនេះគឺដើម្បីជួយសម្រួលដល់ការងារដែលមានចំនួនច្រើនហួសប្រមាណចំពោះតុលាការប្រជាជន។ ចំណែកច្បាប់នាពេលបច្ចុប្បន្នដែលយើងយកមកធ្វើការដោះស្រាយនេះបានឆ្លងកាត់នូវដំណាក់កាលជាច្រើន តាំងពីសម័យបុរាណរហូតមកដល់សម័យទំនើបហើយដែលបានធ្វើការផ្លាស់ប្តូរនូវអត្ថន័យ ក៏ដូចជាខ្លឹមសារមួយចំនួន ដើម្បីឱ្យមានលក្ខណៈល្អប្រសើរទៅតាមសម័យកាលនីមួយៗរបស់ប្រទេស។

**១.៣.៤. របបគតិយុត្តសម័យរដ្ឋកម្ពុជា** (**១៩៨៩ - ២០១១**)

ប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ១៩៨៩ ដល់ឆ្នាំ២០១១ លក្ខខណ្ឌ បែបបទ នៃការរៀបអាពាហ៍ពិពាហ៍ត្រូវបានអនុវត្តតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ដោយមានការសម្របសម្រួល និងនីតិវិធី តាមរយៈ អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០ អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា ឆ្នាំ២០០២ អនុក្រឹត្យស្តីពីការសម្រួលមាត្រា ឆ្នាំ២០០៤ និងអនុក្រឹត្យស្តីពីការកែសម្រួលមាត្រា ឆ្នាំ២០០៥ ជាបន្តបន្ទាប់មានការបោះផ្សាយនូវកម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ឆ្នាំ២០០៥ រួចក៏យកមកអនុវត្តរហូតដល់មានក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ទើបការរៀបអាពាហ៍ពិពាហ៍នោះត្រូវមកអនុវត្តតាមការណែនាំដែលមានក្នុងបទប្បញ្ញត្តិជាធរមានដែលមានចែងតាមច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១ វិញ។

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដោយផ្អែកលើមាត្រា៧ និងមាត្រា៨ នៃរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា មានគោលដៅដាក់បទបញ្ញា និងការពារការរៀបអាពាហ៍ពិពាហ៍ និងគ្រួសារ ធានាសមភាពរវាងសហព័ទ្ធក្នុងអាពាហ៍ពិពាហ៍ និងក្នុងជីវភាពគ្រួសារ ពង្រឹងការទទួលខុសត្រូវរបស់ឪពុកម្តាយក្នុងការចិញ្ចឹមថែរក្សាកូន និងជំរុញការបណ្តុះបណ្តាលសីលធម៌ និងការអប់រំកូន ដើម្បីអោយទៅជាពលរដ្ឋល្អ មានមនសិកាស្នេហាជាតិ ស្រឡាញ់ការងារ មានសម្បជញ្ញៈទទួលខុសត្រូវ ចំពោះសង្គម។[12] ការហាមឃាត់ដាច់ខាតនូវអាពាហ៍ពិពាហ៍ដែលគូស្រករនៅក្មេងពេក អាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំ អំពើដែលមានឧបសគ្គដល់សេរីភាពនៃអាពាហ៍ពិពាហ៍។[13] បុរស និងនារីដែលមានអាយុពេញលក្ខណៈច្បាប់មានសិទ្ធិពេញលេញក្នុងការសំរេចអាពាហ៍ពិពាហ៍។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ។[14]

អាចរៀបអាពាហ៍ពិពាហ៍បាន បុរសចាប់ពីអាយុ២០ឆ្នាំឡើង នារីចាប់អាយុ១៨ឆ្នាំឡើង។ អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្រប តាមខ្នាតដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩។ ច្បាប់នេះ បានហាមឃាត់មិនអាចរៀបអាពាហ៍ពិពាហ៍បាន (បុគ្គលមានភេទដូចគ្នា បុគ្គលគ្មានពលានុភាពនៃលិង្គ បុគ្គលមានជម្ងឺឃ្លង់ របេង មហារីក កាមរោគ ដែលមិនទាន់ព្យាបាលបានជាដាច់)។[15]ជានីតិវិធីនៃការអនុវត្តមុនពេលរៀបអាពាហ៍ពិពាហ៍ អនាគតប្តី ប្រពន្ធ ត្រូវប្តឹងដល់គណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ខាងលំនៅរបស់នារី ដោយមានឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលចូលរួមផងក៏បាន។ ប្រធាន ឬសមាជិកនៃគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ក្នុងឋានៈជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រកាសផ្សាយជាសាធារណៈនូវអាពាហហ៍ពិពាហ៍នោះ ដោយបិទបណ្ណប្រកាសនៅលំនៅឋានរបស់ នារី និង នៅទីស្នាក់ការឃុំ ឬសង្កាត់របស់ខ្លួន។ បណ្ណប្រកាសពីរទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ខាងបុរស ដើម្បីយកទៅបិទលំនៅរបស់បុរស និងនៅទីស្នាក់ការឃុំ ឬសង្កាត់របស់ខ្លួន។ បណ្ណប្រកាសត្រូវបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃ ដើម្បីអោយជនដែលមានផលប្រយោជន៍ក្នុងរឿងនេះដឹងឮ ហើយអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ។ ផុតរយៈពេល១០ថ្ងៃនេះ ពិធីអាពាហ៍ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្តឹងជំទាស់។

### ១.៣.៥. សម័យព្រះរាជាណាចក្រកម្ពុជា (២០១១ - បច្ចុប្បន្ន)

នៅប្រទេសកម្ពុជាចន្លោះពីឆ្នាំ២០១១ រហូតមកដល់បច្ចុប្បន្ន ការរៀបចំពិធីរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជារឿងមួយដែលពេញនិយមណាស់សម្រាប់ប្រជាជនបច្ចុប្បន្ននេះ ហើយដោយសារជីវភាពមានភាពធូរធារជាងមុនពួកគេបានប្រារព្ធពិធីរៀបចំមង្គលការកូនប្រុសកូនស្រីរបស់ពួកគេនោះ មានភាពឱឡារឹកធំធេងទៅ

[12] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ១។

[13] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ២។

[14] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ៤។

[15] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ៦។

តាមលទ្ធភាពគ្រួសាររបស់ពួកគេ។ ចាស់ពីបុរាណ មានជំនឿថា ប្រសិនមិនបានធ្វើពិធីនេះនឹងត្រូវគេចាត់ទុកថាជាអ្នកគ្មានសិរីសួស្តី និងគ្មានកិត្តិយសដល់គ្រួសារនោះឡើយ។

ទោះបីជាការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីមានភាពគេនិយមពិតមែន ប៉ុន្តែការរៀបអាពាហ៍ពិពាហ៍នោះយើងមិនត្រូវឃ្លាតឆ្ងាយពីវិធានការរបស់រដ្ឋ និងនីតិវិធីផ្លូវច្បាប់នោះទេ។ ពីព្រោះប្រទេសកម្ពុជាជាប្រទេសដែលមានរដ្ឋធម្មនុញ្ញ មានអធិបតេយ្យជាតិ មានច្បាប់ និងឯករាជ្យ។ ប្រទេសកម្ពុជាបានកំពុងនឹងប្រកាន់យកគោលការណ៍នីតិរដ្ឋដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះរាល់ច្បាប់ វិធាន បញ្ញត្តិទាំងឡាយដែលបានបង្កើតឡើងតាមរយៈ អង្គនីតិបញ្ញត្តិក្តី អង្គនីតិប្រតិបត្តិក្តី និងតុលាការក្តី ត្រូវគោរពតាមគោលការណ៍ឋានានុក្រមចំពោះរដ្ឋធម្មនុញ្ញផងដែរ។ បច្ចុប្បន្ននីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ត្រូវបានយកមកអនុវត្តតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០១១ និងច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ អនុក្រឹត្យលេខ ១០៣ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន សេចក្តីណែនាំ ស្តីពី ការចុះបញ្ជីអត្រានុកូលដ្ឋាន ស្របតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៤ និងសេចក្តីណែនាំ លេខ ០០៦ សណន ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤ ស្តីពី បែបបទ នីតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន។

សរុបមក យើងខ្ញុំសូមគោរពអនុញ្ញាតធ្វើការបកស្រាយលម្អិតដូចខាងក្រោម រួមមាន លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ដែលមានលក្ខណៈស្របរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តដែលកំពុងជាធរមាន និងការអនុវត្តកិច្ចការការងារនៅក្នុងសង្គមជាក់ស្តែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិក្តី មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រោមជាតិក្តី ជាពិសេសមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ និងក្រសួង ស្ថាប័ន អង្គភាពអាជ្ញាធរដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយមានការចូលរួមក្នុងការអនុវត្តច្បាប់របស់តុលាការតាមសាលាដំបូងរាជធានី ខេត្ត សាលាឧទ្ធរណ៍តំបន់ តុលាការកំពូល និងដៃគូពាក់ព័ន្ធលើវិស័យរដ្ឋប្បវេណី ចាប់តាំងពីលក្ខខណ្ឌការបង្កើតអាពាហ៍ពិពាហ៍ បន្ទាប់មកអាពាហ៍ពិពាហ៍មានអានុភាព រហូតដល់លែងលះផងដែរ។

# ជំពូកទី២
# របបគតិយុត្តនៃអាពាហ៍ពិពាហ៍បច្ចុប្បន្ន

# ជំពូកទី២
# របបគតិយុត្តនៃអាពាហ៍ពិពាហ៍បច្ចុប្បន្ន

ជាទូទៅនៅក្នុងប្រពៃណីទំនៀមទំលាប់ខ្មែរ កំជាប់ពាក្យ ឬ ជាទូទៅត្រូវបានហៅថា ភ្ជាប់ពាក្យ គឺជាពិធីបែបប្រពៃណីមួយ ជាពិធីមួយដែលធ្វើក៏បាន ឬមិនធ្វើក៏បាន ច្បាប់មិនបានដាក់ជាកាតព្វកិច្ចត្រូវធ្វើឡើយ និងមិនបានហាមឃាត់ក្នុងធ្វើពិធីនោះដែរ។ ប្រជាជនធ្វើពិធីកំជាប់ពាក្យនេះ ដែលត្រូវបានប្រជានជនអនុវត្តតៗគ្នាតាំងពីបុរាណកាលរហូតមកដល់ពេលបច្ចុប្បនេះ។ ក្នុងគោលបំណងភ្ជាប់នូវសម្ព័ន្ធភាពរវាងគ្រួសារពីរ មុននឹងឈានដល់ពិធីអាពាហ៍ពិពាហ៍។ យើងសម្គាល់ឃើញថា បុរស និងនារី ដែលមានបំណងនឹងរៀបអាពាហ៍ពិពាហ៍តែងតែរៀបចំនូវពិធីកំជាប់ពាក្យនេះឡើង ដោយហៅជាសាមញ្ញថា ពិធីស្ដីដណ្ដឹង ឬ តាមប្រពៃណីហៅថា ពិធីលើកស្លា ដែលក្នុងពិធីនេះយើងឃើញថា ភាគីខាងបុរសរៀបចំនូវ ជំនូន បណ្ណាការ ជូនទៅខាងនារី ដោយមានការចូលរួមពីឳពុកម្ដាយ ញាតិមិត្ត បងប្អូនទាំងសងខាង ដើម្បីចូលថៃវចូវខាងកូនស្រី។

កំជាប់ពាក្យត្រូវបានប្រជាជនខ្មែរមានជំនឿ និងគោរពយ៉ាងតឹងរឹងនូវឆន្ទៈរបស់ជនដែលពាក់ព័ន្ធនោះ គឺមាន បុរស និងនារី មិនមែនគោរពទៅលើឆន្ទៈរបស់ឳពុកម្ដាយនោះឡើយ។ ប៉ុន្តែជាក់ស្ដែងនៅក្នុងសង្គមខ្មែរវិញកំជាប់ពាក្យត្រូវបានគោរពតាមឆន្ទៈរបស់ឳពុកម្ដាយទៅវិញ។ នៅក្នុងទំនាក់ទំនងនៃកំជាប់ពាក្យយើងបានសង្កេតឃើញថា មានស្ថានភាពជាច្រើនដែលនាំឱ្យគោលបំណងនៃកំជាប់ពាក្យនោះសម្រេចផង ដោយឆន្ទៈរបស់ពួកគេមានភាពស្មោះស្ម័គ្រជាមួយគ្នា ដោយយើងមើលឃើញមានគូស្រករមួយចំនួនបានសម្រេចបំណងដល់បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយរួមរស់ជាគូស្វាមីភរិយាតទៅ។ ប៉ុន្តែមានករណីមួយចំនួនទៀតបុរសនារីដែលបានប្រារព្ធពិធីកំជាប់ពាក្យហើយ ក៏មិនអាចសម្រេចបាននូវអាពាហ៍ពិពាហ៍ជាមួយគ្នាផងដែរ ដោយត្រូវរំលាយកំជាប់ពាក្យទៅវិញ។ ពោលមានស្ថានភាពជាច្រើនដែលនាំឱ្យគោលបំណងនៃកំជាប់ពាក្យមិនបានសម្រេច ដែលជាហេតុនាំឱ្យកំជាប់ពាក្យត្រូវបានរំលាយដូចជា ការទទួលមរណភាពរបស់ភាគីម្ខាងទៀត ការប្រព្រឹត្តកំហុសធ្ងន់ធ្ងរដោយភាគីម្ខាងទៀត ឬដោយការព្រមព្រៀងគ្នាជាអាទិ៍។ ទាំងនេះសុទ្ធសឹងតែជាមូលហេតុនៃការរំលាយកំជាប់ពាក្យ។

បើភាគីបុរសជាអ្នកជូនជំនូន នោះភាគីខាងបុរសអាចទាមទារជំនូននោះ ពីភាគីខាងនារីវិញបាន។ កំជាប់ពាក្យត្រូវបានបង្កើតឡើងរួចហើយ ហើយភាគីម្ខាងបានប្រកាសរំលាយកំជាប់ពាក្យនោះដោយគ្មានមូលហេតុត្រឹមត្រូវ នោះភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតបាន ដែលការទាមទារសំណងនេះ អាចឈរលើមូលដ្ឋាននៃការមិនអនុវត្តកាតព្វកិច្ច ឬអំពើអនីត្យានុកូល ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។ ចំពោះសំណងនៃការខូចខាតដែលត្រូវទាមទារ អាចរាប់បញ្ចូលទាំងសំណងខាងផ្លូវចិត្ត សម្ភារៈ និងសេដ្ឋកិច្ច។ បើភាគីដែលបដិសេធ កំជាប់ពាក្យជាភាគីខាងបុរសវិញ នោះខាងនារីមិនអាចទាមទារឱ្យសងជំនូនបានឡើយ ដោយហេតុថា ជំនូនត្រូវបានភាគីខាងនារីទទួលបានហើយ តែភាគីខាងនារីអាចទាមទារនូវការខូចខាតដូចជាថ្លៃជួលរោង តុចុងភៅ សំអាងការ ថ្លៃគ្រឿងអលង្ការ (ចិញ្ចៀនភ្ជាប់ពាក្យ) និងសំណងជំងឺចិត្តជាអាទិ៍។

## ២.១. ទំនាក់ទំនងគតិយុត្តមុនរៀបអាពាហ៍ពិពាហ៍ (កំជាប់ពាក្យ)

### ២.១.១. និយមន័យកំជាប់ពាក្យ

ពាក្យ "កំជាប់" ភាពមិនដាច់គ្នា ភាពមិនឃ្លាតគ្នា ភាពដែលជាប់តតដាច់។ រីឯពាក្យ "ពាក្យ" ភាសាសម្តី ប្រយោគសម្តី។ ឯកតាភាសាដែលមានសូរមួយ ឬច្រើននៅក្នុងខ្សែសម្តី ឬសំណេរតាងសូរទាំងនោះ ហើយមានន័យ។ ពាក្យផ្សំឡើងដោយរូបសព្ទមួយ ឬលើសពីមួយ។ ពាក្យថា កំជាប់ពាក្យ មានន័យថាពីធីតាមទំនៀមទម្លាប់ប្រពៃណី ដែលច្បាប់ទទួលស្គាល់ដែលតាមរយៈពិធីនេះ បុរស និងនារីសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត[16]។ កំជាប់ពាក្យ ត្រូវបង្កើតឡើង តាមសេចក្តីសន្យារវាងបុរស នារី ថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នា នាពេលអនាគត និង ដោយធ្វើពិធីកំជាប់ពាក្យ។[17] កំជាប់ពាក្យ គឺសេចក្តីសន្យាដែលជនពីរនាក់បានប្តេជ្ញាថានឹងយកគ្នាជាប្តីប្រពន្ធតាមច្បាប់។[18]

### ២.១.២. ការសងជំនួនដោយកំជាប់បានរលាយ

យោងតាមក្រមរដ្ឋប្បវេណី មាត្រា ៩៤៥ ក្នុងករណីដែលភាគីណាម្ខាងបានបដិសេធចោលនូវកំជាប់ពាក្យដោយគ្មានមូលហេតុត្រឹមត្រូវ ភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតដែលកើតឡើងដោយសារការបដិសេធចោលនោះបាន។[19] ក្នុងករណីដែលកំជាប់ពាក្យបានរលាយ ភាគីដែលបានលើកជំនូននៅពេលកំជាប់ពាក្យ ដោយសង្ឃឹមថានឹងបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារឱ្យភាគីម្ខាងទៀត សងជំនូននោះមកវិញបាន។[20] ផ្ទុយមកវិញ បើកំជាប់ពាក្យត្រូវបានរំលាយដោយសារការព្រមព្រៀង ភាគីអាចកំណត់ពីការទទួលខុសត្រូវរៀងៗខ្លួនបាន ហើយភាគីត្រូវគោរពតាមការព្រមព្រៀងនោះ។ ឧទាហរណ៍ថា ភាគីបុរស និងនារីបានព្រមព្រៀងគ្នារំលាយកំជាប់ពាក្យដោយមិនទាមទារអ្វីពីគ្នាទៅវិញទៅមកឡើយ ដោយខាងបុរសមិនទាមទារជំនូន ហើយខាងនារីមិនទាមទារថ្លៃសោហ៊ុយកំជាប់ពាក្យជាដើម។

### ២.១.៣. ការទទួលខុសត្រូវការបដិសេធមិនត្រឹមត្រូវ

ដោយយោងតាមបញ្ញត្តិមាត្រា ៩៤៦ នៃក្រមរដ្ឋប្បវេណី ក្នុងករណីដែលភាគីណាម្ខាងបានធ្វើការរំលាយកំជាប់ពាក្យចោលដោយមូលហេតុមិនត្រឹមត្រូវ ឬមិនសមស្រប ភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតបាន។[21] មានន័យថាករណីបើភាគីបុរសជាអ្នកជូនជំនូនទៅខាងស្រី នោះភាគីខាងបុរសមានសិទ្ធិអាចទាមទារជំនូននោះ ពីខាងភាគីខាងស្រីវិញបានផងដែរ។ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ករណីកំជាប់ពាក្យនោះត្រូវបានបង្កើតឡើងរួចហើយនោះ បន្ទាប់មកភាគីម្ខាងបានប្រកាសរំលាយកំជាប់ពាក្យ

[16] សន្ទានុក្រម ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ លេខរៀង ២៦។
[17] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៤៤។
[18] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ មាត្រា ១០៦។
[19] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៤៦។
[20] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៤៥។
[21] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៤៦។

នោះដោយគ្មានមូលហេតុត្រឹមត្រូវតាមច្បាប់ ឬគ្មានមូលហេតុសមរម្យនោះទេ ភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតបាន ដែលការទាមទារសំណងនៃការខូចខាតនេះ ត្រូវបានអាចឈរលើមូលដ្ឋាននៃការមិនអនុវត្តកាតព្វកិច្ច ឬអំពើអនីត្យានុកូល ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីត្រូវបានយកមកអនុវត្តក្នុងករណីនេះផងដែរ។

### ២.១.៤. អំឡុងពេលដាក់ពាក្យបណ្ដឹង

ចំពោះការទាមទារឱ្យសងជំនួន និងការទាមទារសំណងខូចខាត ភាគីអាចអនុវត្តសិទ្ធិទាមទារតាមផ្លូវតុលាការ ដោយយោងតាមមាត្រា ៩៤៧ នៃក្រមរដ្ឋប្បវេណី។ អំឡុងពេលនៃការដាក់ពាក្យបណ្ដឹងទាមទារត្រូវធ្វើឡើងក្នុងរយៈពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះត្រូវបានរលាយ ។ឧទាហរណ៍ កំជាប់ពាក្យត្រូវបានរំលាយ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨ នោះថេរៈវេលាមួយឆ្នាំ គឺ ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ ដូច្នេះភាគីអាចដាក់ពាក្យបណ្ដឹងក្នុងអំឡុងពេលនេះបាន។ ផុតរយៈពេលខាងលើ ភាគីលែងមានសិទ្ធិទាមទារសំណងទៀតឡើយ (ផ្ដាច់សិទ្ធិ)។ បណ្ដឹងដែលទាក់ទងទៅនឹងមាត្រា ៩៤៥ (ការសងជំនួន) ឬ មាត្រា ៩៤៦ (ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ) ខាងលើនេះ ត្រូវប្ដឹងនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះ បានរលាយ។[22]

## ២.២. លក្ខខណ្ឌនៃបង្កើតអាពាហ៍ពិពាហ៍

លក្ខខណ្ឌសម្រាប់បង្កើតអាពាហ៍ពិពាហ៍ត្រូវបានអនុវត្តតាមបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១។ ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ត្រូវបានអនុវត្តតាមទំនៀមទម្លាប់ ឬពិធីតាមបែបសាសនាណាមួយបាន។ ការរៀបអាពាហ៍ពិពាហ៍មួយនោះមិនត្រូវបានទទួលស្គាល់ថាមានអានុភាពតាមផ្លូវច្បាប់ និងទំនាក់ទំនងគតិយុត្តរវាងភាគីទាំងពីរនោះទេ។ ហេតុនេះ ទើបច្បាប់បានតម្រូវឱ្យបុរសនារីចាំបាច់ត្រូវចុះបញ្ជីអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិល (Etat Civil) នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ដោយគោរពតាម បែបបទ និងនីតិវិធីនៃច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ និងសេចក្ដីណែនាំស្ដីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ស្របតាម ច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ទើបអាចក្លាយជាប្ដីប្រពន្ធស្របច្បាប់បាន។

### ២.២.១. គោលការណ៍ស្ម័គ្រចិត្ត

រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពនិងករណីយកិច្ចដូចគ្នា ទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈ សង្គម ធនធាន ឬស្ថានភាពឯទៀត

[22] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៤៧។

ឡើយ។ ការប្រើសិទ្ធិ សេរីភាពផ្ទាល់ ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់។[23] ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន។[24]

រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បានចែងថា ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល។ ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រី ត្រូវហាមឃាត់។ បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងវិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។ អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ។[25] មានន័យថាចំពោះភេទរបស់ភាគីក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវតែបុរសនិងស្ត្រី ហើយត្រូវធ្វើឡើងទៅតាមលក្ខខណ្ឌទម្រង់នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា មិនត្រូវធ្វើឡើងដោយខុសទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ឡើយ។

ក្នុងការទិដ្ឋភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ឈរលើគោលការណ៍ស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្ត ដែលពេលខ្លះទំនោរទៅលើទំនៀមទម្លាប់ប្រពៃណីមានភាពខ្លាំងពេក នាំឱ្យឪពុកម្តាយប្រកាន់យកនូវពាក្យស្លោក នំមិនធំជាងនាឡិ មានន័យថា កូនៗ ជាពិសេសកូនស្រីត្រូវស្តាប់តាមបង្គាប់ឪពុកម្តាយ ជីដូនជីតា ក្នុងរឿងអាពាហ៍ពិពាហ៍។ កាលណា នៅពេលកូនៗឈានដល់វ័យរៀបអាពាហ៍ពិពាហ៍ គឺទុកឱ្យឪពុកម្តាយ ជាអ្នកសម្រេចចិត្តជំនួសសាមីខ្លួន។ ប៉ុន្តែបច្ចុប្បន្ន កូនចៅប្រុសស្រី មានសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករជាងមុន ដោយសារតែប្រទេសមានការរីកចម្រើន ប្រជាជនមានការយល់ដឹងជាងមុន និងដោយមានការទទួលឥទ្ធិពលពីការសិក្សាការអប់រំ សាសនា និងវប្បធម៌បរទេសផងដែរ។

**២.២.២. ភេទរបស់ភាគី**

នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តិថា បុរស និងនារី ដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។[26] បញ្ញត្តិត្រង់នេះបានផ្តោតតែទៅលើបុរស និងនារី សុទ្ធសាធ មិនបានផ្តោតលើការរៀបអាពាហ៍ពិពាហ៍ដែលមានភេទដូចគ្នា (បុរស និង បុរស ឬ នារី និង នារី)។ល។ ចំណែកក្រមរដ្ឋប្បវេណី ឆ្នាំ ១៩២០ វិញចែងថា អាពាហ៍ពិពាហ៍អាចរៀបបានតែរវាងបុគ្គលដែលមានភេទផ្សេងគ្នា។[27] ចំពោះករណីភេទត្រង់ចំណុចនេះ មានបញ្ហាប្រឈមមួយសម្រាប់អាពាហ៍ពិពាហ៍ក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ដោយសារតែមានបុគ្គលមួយចំនួនបានស្រឡាញ់ភេទដូចគ្នា គឺមានបុរសស្រឡាញ់បុរស និងនារីស្រឡាញ់នារីហើយក៏ការរៀបការជាមួយគ្នានោះដែលជាហេតុនាំឱ្យមានបញ្ហាផ្សេងៗកើតឡើង។ ការរៀបអាពាហ៍ពិពាហ៍របៀបនេះតាមប្រពៃណីមិនជាបញ្ហានោះឡើយ ប៉ុន្តែបើមានការអនុវត្តនីតិវិធីតាមផ្លូវច្បាប់វិញ ច្បាប់មិនទទួលការរៀបអាពាហ៍ពិពាហ៍

[23] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មាត្រា ៣១។

[24] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មាត្រា ៣២ កថាខណ្ឌទី១។

[25] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មាត្រា ៤៥ កថាខណ្ឌទី៣ និងកថាខណ្ឌទី៤។

[26] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៤៨ កថាខណ្ឌទី១។

[27] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ មាត្រា ១១៥ ។

ពេញលេញតាមច្បាប់ឡើយដោយសារផ្ទុយនឹងបញ្ញត្តិច្បាប់។ ការចង់បានកូន បង្កើតកូន ការងាររឆ្លងជំងឺកាមរោគ ការពិបាកក្នុងការបង្កើតធនធានមនុស្សក្នុងសង្គម ការរើសអើងផ្លូវភេទជាដើម។

បើយើងក្រឡេកមើលច្បាប់ស្តីពីឯកពន្ធភាពមាត្រា ២ ក៏បានចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរដែលមានដែលចំណងរៀបអាពាហ៍ពិពាហ៍ ត្រូវគោរពគោលការណ៍ឯកពន្ធភាពដោយស្មគ្រចិត្តប្តីមួយប្រពន្ធមួយ។ នៅក្នុងមាត្រានេះបានបញ្ជាក់ថា ចំពោះការរៀបអាពាហ៍ពិពាហ៍នោះត្រូវតែពលរដ្ឋខ្មែរទាំងពីរភេទភាគីទាំងពីរត្រូវមានភេទផ្ទុយគ្នាគឺប្រុសនិងស្រី មិនមែនការរៀបការជាមួយភេទដូចគ្នានោះឡើយ។

តាមគោលការណ៍ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបង្ហាញឱ្យឃើញថាភាគីដែលសម្រេចចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍បាននោះ ត្រូវជាបុរស និងនារីទើបអាពាហ៍ពិពាហ៍នោះអាចស្របច្បាប់បាន។ ប៉ុន្តែក្នុងករណីជាក់ស្តែងមានបុគ្គលមួយចំនួន នៅប្រទេសកម្ពុជាបច្ចុប្បន្នបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានឹងភេទដូចគ្នាដែលជាហេតុធ្វើឱ្យមានការផ្ទុយនឹងវិធានច្បាប់។

ឧទាហរណ៍ លោក សុខ និងលោក សៅ ឬ កញ្ញា វត្តី និងកញ្ញា ជីជី បានស្រឡាញ់គ្នា។ ក្រោយមកមានការព្រមព្រៀងពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលក្នុងការរៀបអាពាហ៍ពិពាហ៍ផងដែរ។ ប៉ុន្តែបើទោះបីជាមានការយល់ព្រមពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីក៏ដោយ ច្បាប់មិនទទួលស្គាល់ការរៀបអាពាហ៍ពិពាហ៍នោះស្របច្បាប់ឡើយ ពួកគេបានត្រឹមរស់នៅជាមួយគ្នាជាអនីតិសង្វាសជន។

**២.២.៣. អាយុរបស់ភាគី**

ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍ បុរស និង នារី ដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ។[28] ករណីក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩២០ ប្រុសមានអាយុមិនដល់១៧ ឆ្នាំ ស្រីមានអាយុមិនដល់ ១៤ឆ្នាំ មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។[29] សូមបញ្ជាក់ថា ភាគីណាម្នាក់ម្ខាងនឹងដល់នីតិភាពនៅពេលដែលគេមានអាយុ ១៨ឆ្នាំ ឬក៏ទទួលបាននូវអត្តាធីនភាព។ ក្នុងករណីដែលពួកគេបានទទួលបានអត្តាធីនភាពតាមច្បាប់កំណត់គឺមានពីរករណី ករណីទី១ តាមដីកាសម្រេចរបស់តុលាការ ដោយតាមការស្នើសុំរបស់អនីតិជនដែលបានដល់អាយុ ១៦ឆ្នាំ។ ករណីទី២ តាមរយៈការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន។

ទោះបីជាយ៉ាងណាក្តី ជនប្រុស ស្រី ទាំងអស់ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ពួកគេអាចរៀបអាពាហ៍ពិពាហ៍បាន ដោយតាមការសម្រេចចិត្តរបស់ខ្លួន និងមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយ ឬអ្នក

[28] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៤៨។

[29] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ មាត្រា ១១៦។

អាណាព្យាបាលឡើយ។ ពោល គឺក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានផ្តល់សិទ្ធិពេញលេញដល់ពលរដ្ឋខ្មែរក្នុងការសម្រេចចិត្តជ្រើសរើសដៃគូ ដើម្បីទទួលបានការរៀបចំអាពាហ៍ពិពាហ៍។

ឧទាហរណ៍ លោក សុខជា អាយុ ២០ ឆ្នាំ និងកញ្ញា ទេពី អាយុ ២០ ឆ្នាំ ពួកគេបានយល់ព្រមរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដោយស្មគ្រចិត្ត។ ក្នុងករណីនេះ ពួកគេជានីតិជនមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលនោះទេ។ ពួកគេអាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ និងចុះបញ្ជីអាពាហ៍ពិពាហ៍បានដោយច្បាប់បានទទួលស្គាល់ជាផ្លូវការ។

**២.២.៤. ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន**

អនីតិជន គឺសំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។[30] យោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ជនដែលស្ថិតនៅក្រោមរបបអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ចំពោះការអនុវត្តនូវកិច្ចគតិយុត្តតម្រូវឱ្យទទួលបានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាល។ សកម្មភាពដែលធ្វើឡើងដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន។ អនីតិជន ជាជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម ១៨ឆ្នាំ។[31]

ចំពោះការរៀបអាពាហ៍ពិពាហ៍វិញ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តិថា បុរស និងនារីដែលមិនទាន់ដល់នីតិភាពអាយុ ១៨ឆ្នាំ មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាពហើយភាគីម្ខាងទៀតជានីតិជនដែលមានអាយុមិនតិចជាង ១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បានដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ។[32] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តិថា ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជនៈ

១-ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាអនីតិជន អនីតិជននោះចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាច មេបា ឬ អាណាព្យាបាលសម្រាប់អនីតិជននោះ។

២-បើអ្នកដែលមានអំណាចមេបាណាម្ខាងមិនយល់ព្រមទេ គ្រាន់តែមានការយល់ ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាម្ខាង ជាការគ្រប់គ្រាន់ហើយ។

៣-ក្នុងករណីដែលអ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជន បដិសេធការយល់ព្រមដោយគ្មានមូលហេតុសមរម្យ អនីតិជនដែលមានបំណងចង់រៀប អាពាហ៍ពិពាហ៍ អាចទាមទារទៅតុលាការឱ្យសម្រេចសេចក្តីជំនួសការយល់ព្រមនោះបាន។[33]

[30] វចនានុក្រម រៀបចំដោយ គណកម្មការរៀបចំវចនានុក្រមខ្មែរ ឆ្នាំ២០២២។

[31] សន្ធានុក្រម ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ លេខរៀង ១៨៧។

[32] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៤៨។

[33] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥៣។

ឧទាហរណ៍ លោក ពិសិដ្ឋ អាយុ ២០ ឆ្នាំ និងកញ្ញា ចន្ថា អាយុ ១៦ ឆ្នាំ ដែលមានគ្រោងថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត។ ដោយមើលឃើញលោក ពិសិដ្ឋ មានចរិតល្អ និងសុជីវធម៌ល្អ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់ ចន្ថា បានយល់ព្រមឱ្យនាងរៀបអាពាហ៍ពិពាហ៍ជាមួយលោក ពិសិដ្ឋ តាមការជ្រើសរើសរបស់កញ្ញា ចន្ថា ដែលជាកូនស្រី។

ភាគីដែលជាអនីតិជនដែលមិនទាន់គ្រប់អាយុ ១៨ឆ្នាំ ត្រូវតែមានអាយុយ៉ាងតិច ១៦ឆ្នាំ ឡើងទៅ ទើបច្បាប់អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បាន ដោយមានលក្ខខណ្ឌដូចខាងក្រោម៖

#### ២.២.៤.១. អនីតិជន និងនីតិជន

បុរស នារី មានបំណងរៀបអាពាហ៍ពិពាហ៍ តែភាគីម្ខាងមានអាយុតិចជាង ១៦ ឆ្នាំ ឡើងទៅ ហើយភាគីម្ខាងទៀតមានអាយុ ១៨ ឆ្នាំ ឡើងទៅ ត្រូវតែមានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជននោះទើបអាចរៀបអាពាហ៍ពិពាហ៍បាន។

#### ២.២.៤.២. ជនដែលទទួលបានអត្តាធីនភាព

អនីតិជនដែលទទួលបានអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព។[34] ល័ក្ខខ័ណ្ឌនៃអត្តាធីនភាព ១. ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបានតាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការការឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា។ ២. អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ។ ៣. ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាព មិនត្រូវរលត់ឡើយ។[35] ដូច្នេះ អនីតិជនដែលទទួលបានអត្តាធីនភាព អាចរៀបអាពាហ៍ពិពាហ៍បានដោយពុំចាំបាច់មានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាល។ ក្នុងករណីដែល អាពាហ៍ពិពាហ៍នោះបានកើតឡើងរវាង អនីតិជនដែលទទួលបានអត្តាធីន ភាព និងអនីតិជន ចាំបាច់ត្រូវមានការយល់ព្រមពីឪពុកម្តាយរបស់អនីតិជននោះ ទើបអាចរៀបអាពាហ៍ពិពាហ៍បាន។ ប្រសិនបើ អាពាហ៍ពិពាហ៍នោះកើតឡើងរវាង អនីតិជនដែលទទួលបានអត្តាធីនភាព និងអនីតិជនដែលទទួលបានអត្តាធីនភាពដូចគ្នា ពួកគេអាចរៀបអាពាហ៍ពិពាហ៍បានដោយពុំចាំបាច់មានការយល់ព្រមពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលឡើយ។

### ២.២.៥. ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ សំដៅដល់នីតិជនដែលស្ថិតនៅក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនជានិរន្តដោយសារមានវិបត្តិផ្នែកស្មារតី

[34] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ២២។

[35] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ២១។

ហើយត្រូវបានប្រកាសដាក់ឱ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅ។ ចំពោះជននៅក្រោមអាណាព្យាបាលទូទៅ អាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីដែលមានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអប្បបរមាដែលចាំបាច់ ដើម្បីរៀបអាពាហ៍ពិពាហ៍។ ក្នុងករណីនេះមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ។[36] មានន័យថាជនវិកលចរិតនេះអាចសម្រេចចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍ដោយខ្លួនឯងបាន ដោយមិនចាំបាច់ មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅ។ ជនដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ត្រូវហៅថា ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ។[37]

ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ

១- ចំពោះជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពី លទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការ ចាប់ផ្តើមអាណាព្យាបាលទូទៅបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំនៅពេលដែលមានពាក្យសុំ។

២- ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជន នៅក្រោមហិតូបត្ថម្ភ តុលាការត្រូវបានលុបចោលការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភចំពោះជននោះ។ [38]

ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅៈ

១- បើប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ដោយឆន្ទានុសិទ្ធិ។

២- ប្រសិនបើខ្វះអ្នកអាណាព្យាបាលទូទៅ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅសហព័ទ្ធ របស់ជននៅក្រោមអាណាព្យាបាលទូទៅសហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោម អាណាព្យាបាលទូទៅតំណាងអយ្យការ ឬបុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬដោយ ឆន្ទានុសិទ្ធិ។

៣- ទោះបីជាបានជ្រើសតាំងអ្នកអាណាព្យាបាលទូទៅហើយក៏ដោយ បើយល់ឃើញថាចាំបាច់តុលាការ អាចជ្រើសតាំងអ្នកអាណាព្យាបាលទូទៅថែមទៀត តាមការទាមទាររបស់បុគ្គលដែលបានកំណត់នៅក្នុងកថា ខណ្ឌទី២ ខាងលើនេះ ឬអ្នកអាណាព្យាបាលទូទៅ ឬដោយឆន្ទានុសិទ្ធិបាន។

---

[36] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥៤។

[37] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ២៥។

[38] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ២៤។

៤- ដើម្បីជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ តុលាការត្រូវគិតពីចារណាអំពីស្ថានភាពផ្លូវកាយនិងផ្លូវចិត្ត និងស្ថានភាពជីវភាព និងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅវិជ្ជាជីវៈ និងប្រវត្តិរូបរបស់អ្នក ដែលត្រូវធ្វើជាអ្នកអាណាព្យាបាលទូទៅ និងអត្ថិភាព ឬនត្ថិភាព នៃទំនាក់ទំនងនឹងផលប្រយោជន៍ រវាងអ្នកអាណាព្យាបាលទូទៅ និងជននៅក្រោមអាណាព្យាបាលទូទៅ និងស្ថានភាពផ្សេងទៀតទាំងស្រុង។ ប្រសិនបើអ្នកអាណាព្យាបាលទូទៅ ជានីតិបុគ្គលតុលាការត្រូវគិតពិចារណាផងដែរអំពីប្រភេទ និងខ្លឹមសារនៃកិច្ចការរបស់នីតិបុគ្គល និងអត្ថិភាពនៃទំនាក់ទំនងទៅនឹងផលប្រយោជន៍រវាងនីតិបុគ្គល និងអ្នកតំណាងរបស់នីតិបុគ្គលនោះ និងជននៅក្រោមអាណាព្យាបាលទូទៅ។

៥- ក្នុងករណីដែលជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ចំពោះអនីតិជន តុលាការ អាចយកអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន មកជ្រើសតាំងជាអ្នកអាណាព្យាបាលទូទៅបាន។ ក្នុងករណីដែលតុលាការយកជន ក្រៅពីអ្នកមានអំណាចមេបារបស់អនីតិជន ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនមកជ្រើសតាំងជាអ្នកអាណាព្យាបាលទូទៅ តុលាការត្រូវកំណត់អំពីការបែងចែកកិច្ចការរបស់អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅ។[39]

ឧទាហរណ៍ លោក ដារ៉ា មានអាយុ ២៧ ឆ្នាំ និងកញ្ញា សោភា មានអាយុ ២៥ ឆ្នាំ មានគម្រោងរៀបការជាមួយគ្នា។ ក៏ប៉ុន្តែជា អកុលស លោក ដារ៉ា បានជួបគ្រោះថ្នាក់ចរាចរណ៍បណ្តាលឱ្យលោក ដារ៉ា បានបាត់បង់ស្មារតីដឹងខុសដឹងត្រូវបាន។ ហេតុនេះហើយទើបមានការប្រកាសដាក់លោក ដារ៉ា ឱ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅតាមដីកាសម្រេចរបស់តុលាការ ដោយកំណត់ឱ្យបងប្រុសបង្កើតរបស់លោក ដារ៉ា ធ្វើជា អ្នកអាណាព្យាបាលទូទៅ របស់លោក ដារ៉ា។ ក្រោយមកវិញបន្តិចស្ថានភាពរបស់លោក ដារ៉ា បានល្អប្រសើរឡើងវិញ ក៏ប៉ុន្តែមិនទាន់ជាសះស្បើយទាំងស្រុងឡើយ។ ក្នុងករណីដែលលោក ដារ៉ា អាចបង្ហាញឆន្ទៈថានឹងរៀបការជាមួយនឹងកញ្ញា សោភា បាន នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន (មេឃុំ ឬចៅសង្កាត់) នោះ លោក ដារ៉ា និងកញ្ញា សោភា អាចរៀបការជាមួយគ្នាបាន ដោយមិនចាំបាច់មានការយល់ព្រមឯកភាពពីបងប្រុសបង្កើតរបស់លោក ដារ៉ា នោះទេ។

### ២.២.៦. ជននៅក្រោមហិតូបត្ថម្ភ

ជនដែលបានទទួលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូបត្ថម្ភ ហើយត្រូវស្ថិតនៅក្នុងការថែរក្សាដោយហិតូបត្ថម្ភកៈ។[40] ជនទាក់ទងនឹងសមត្ថភាពចំពោះជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ (ជនដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី) អាចរៀបអាពាហ៍ពិពាហ៍បាន ដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈឡើយ។ តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងអំពីការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភះ

[39] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១១០៥។

[40] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ២៩។

១- ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន និង វិនិច្ឆ័យ ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នក អាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការ នេះ ប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅចំពោះជននោះ។ តាមរយៈមាត្រា ៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ពុំបានចែងអំពីការហាមឃាត់ ឬសិទ្ធិលុបចោលពីហិតូបត្ថម្ភកៈទៅលើសកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភនោះទេ។[41] មានន័យថាសកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភអំពីជីវភាពរស់នៅប្រចាំថ្ងៃ មិនចាំបាច់មានការយល់ព្រមពីជននៅក្រោមហិតូបត្ថម្ភកៈឡើយ ក្នុងន័យនេះត្រូវបានបូករួមទាំងសកម្មភាពអាពាហ៍ពិពាហ៍ផងដែរ។

ឧទាហរណ៍ ៖ លោក សំភី មានអាយុ ៣០ ឆ្នាំ។ ក្រោយពីជួបប្រទះនូវ គ្រោះថ្នាក់ចរាចរណ៍ដែលមានការប៉ះទង្គិចត្រង់ក្បាលរួចមក លោក សំភី បាន ក្លាយជាមនុស្សដែលមិនសូវដឹងខុសត្រូវដូចពីមុនទេ ប៉ុន្តែវេជ្ជបណ្ឌិតជំនាញបាន បញ្ជាក់ថា គាត់មិនមែនមិនដឹងខុសត្រូវទាំងស្រុងទេ គឺគ្រាន់តែដឹងខុសត្រូវតិច តួចតែប៉ុណ្ណោះ។ ក្នុងករណីបែបនេះ គឺគេអាចស្នើសុំឱ្យតុលាការសម្រេចដាក់ លោក សំភី ឱ្យស្ថិតនៅក្រោមហិតូបត្ថម្ភតាម ដីកាសម្រេច ដោយជ្រើសតាំង នរណាម្នាក់ឱ្យធ្វើជាហិតូបត្ថម្ភកៈ (អ្នកគ្រប់គ្រង) របស់លោក សំភី។ ទោះបីជា ក្នុងករណីយ៉ាងនេះក៏ដោយ លោក សំភី នៅតែអាចរៀបការបាន ដោយមិនចាំ បាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈឡើយ។[42]

## ២.៣. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍

### ២.៣.១. ការហាមឃាត់មិនឱ្យទ្វេពន្ធភាព

យោងតាមមាត្រា ៩៤៩ នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តិថា បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ។[43] ផ្អែកតាមការកំណត់នេះ ចំណងអាពាហ៍ពិពាហ៍ គឺសំដៅទៅលើការប្រព្រឹត្តតាមច្បាប់ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ អេតាស៊ីវិល និងមានសុពលភាព ហើយបុរស ឬនារីនោះបានទៅបង្កើតចំណងអាពាហ៍ពិពាហ៍ ដោយមានការចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីទៀតមួយជាមួយបុរស ឬនារី ផ្សេងទៀតនោះ។ ក្នុងករណីដែលភាគីណាម្ខាងមានចំណងអាពាហ៍ពិពាហ៍ពីមុនមក ហើយចំណងអាពាហ៍ពិពាហ៍នោះពុំទាន់ត្រូវបានរលាយនៅឡើយនោះ គាត់ពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានទេ។ បុរសនារីដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍តាមនីតិវិធីរួច ទើបក្លាយជាប្តីប្រពន្ធស្របច្បាប់ ត្រូវគោរពស្រឡាញ់គ្នាទៅវិញទៅមក និងមានភាពស្មោះត្រង់ចំពោះគ្នា។ ក្នុងន័យនេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤៥ កថាខណ្ឌ ៤ ក៏បាន

[41] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ២៨។

[42] រុន ពណ្ណារិទ្ធ ចាំង ស៊ីណាត សៀវភៅនីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ ឆ្នាំ២០២២។

[43] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៤៩។

បញ្ញត្តិថា អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ។[44]

ក្នុងករណីបើមានបុគ្គលម្នាក់បានរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់រួច ហើយធ្វើការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ម្តងទៀត ដោយអាពាហ៍ពិពាហ៍តាមច្បាប់មុនមិនទាន់រំលាយ បុគ្គលម្នាក់នេះបានប្រព្រឹត្តបទល្មើសទ្វេពន្ធភាព ដែលសំដៅដល់ចំណងអាពាហ៍ពិពាហ៍ដែលបុរសមានប្រពន្ធពីរ ឯស្ត្រីមានប្តីពីរ។

បទទ្វេពន្ធភាព ក្នុងមាត្រា ៣៥០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានបញ្ញត្តិថា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យ ជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើដែលចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មី មុនការរំលាយអាពាហ៍ពិពាហ៍ចាស់។

ត្រូវផ្តន្ទាទោសដូចគ្នា ចំពោះមន្ត្រីអត្រានុកូលដ្ឋានដែលដឹងហេតុការណ៍នោះច្បាស់ នៅតែអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ ឬចុះបញ្ជីអាពាហ៍ពិពាហ៍នេះ មុនការរំលាយអាពាហ៍ពិពាហ៍ចាស់។[45]

ឧទាហរណ៍ លោក សុខា និងលោកស្រី សុផា គឺជាប្តីប្រពន្ធនឹងគ្នាស្របច្បាប់។ ក្រោយលោក សុខា បានលួចទាក់ទងជាមួយនារីម្នាក់ទៀតឈ្មោះ ស្រីនួន ជាស្រីកំណាន់ នឹងតែងតែទៅរួមមេត្រីជាមួយគ្នាជារឿយៗ ទាំងដែលលោក សុខា និងលោកស្រី សុផា មិនទាន់លែងលះគ្នានោះទេ បន្ទាប់មកអ្នកទាំងពីរបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីជាមួយគ្នា។ ក្រោយមករឿងនេះក៏បានដឹងដល់ លោកស្រី សុផា ជាប្រពន្ធ ហើយលោកស្រីក៏បានដាក់ពាក្យប្តឹងនៅអាជ្ញាធរមានសមត្ថកិច្ច។

សរុបមក ទ្វេពន្ធភាព គឺជាចំណងអាពាហ៍ពិពាហ៍តាមច្បាប់ (ចុះបញ្ជីអាពាហ៍ពិពាហ៍) ដែលបុរសមានប្រពន្ធពីរ ឯស្ត្រីមានប្តីពីរ ហើយត្រូវចាត់ទុកថាមានបានប្រព្រឹត្តបទទ្វេពន្ធភាព ចំពោះបុរស ឬស្ត្រីណា ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយនៅឡើយ ហើយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀតនោះ។

### ២.៣.២. អំឡុងពេលហាមឃាត់បង្កើតអាពាហ៍ពិពាហ៍ថ្មី

អំឡុងពេលដែលច្បាប់បានហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

១- នារីពុំអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ប្រសិនបើអំឡុងពេល ១២០ថ្ងៃ (មួយរយម្ភៃ) ថ្ងៃ ពុំទាន់កន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ ឬលុបចោល។

២- បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោលហើយបានសម្រាលកូន ឬ ចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះ ពីវេជ្ជបណ្ឌិត។[46]

តាមការកំណត់របស់សេចក្តីកំណត់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១០ មាត្រា ៩៥០ កំណត់អំឡុងពេលហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ត្រូវបានកំណត់ឡើងសម្រាប់នារី ដើម្បីជៀសវាងការប្រកួតប្រជែងទាក់ទង

---

[44] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មាត្រា ៤៥។

[45] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា ៣៥០។

[46] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥០។

នឹងការសន្មតបិតុភាពរបស់កូន ដែលមានន័យថា តើកូនដែលកើតមកគួរត្រូវសន្មតថាជាកូនរបស់ប្ដីមុន ឬប្ដីក្រោយ។ ដោយហេតុថា នៅប្រទេសកម្ពុជា អំឡុងពេលប្រកួតប្រជែងគ្នានេះ គឺ ១២០ ថ្ងៃ ដូច្នេះការរៀបអាពាហ៍ពិពាហ៍ថ្មីនៅក្នុងអំឡុងពេលនោះត្រូវបានកម្រិត។ ករណីលើកលែងត្រូវបានអនុញ្ញាត បញ្ញត្តិស្ដីពីអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានលិខិតបញ្ជាក់អំពីភាពគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបាន។[47]

### ២.៣.៣. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត

ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ រវាងញាតិលោហិត ទី១ អាពាហ៍ពិពាហ៍ មិនអាចធ្វើបានឡើយ រវាងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតក្នុង ៣ (បី) ថ្នាក់ រាប់ទាំងថ្នាក់ទី៣ (បី) ផង។ ទី២ បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ នៅក្រោយពេលដែលទំនាក់ទំនងញាតិ ត្រូវបានបញ្ចប់ ដោយបញ្ញត្តិនៃមាត្រា ១០១៤ (ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត) មាត្រា ១០១៦ (ការកាត់កាល់នៃសុំកូនពេញលេញ) ឬ មាត្រា ១០៣២ (អានុភាពនៃការកាត់កាល់សុំកូនធម្មតា) នៃក្រមនេះ។ ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត រួមមាន ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតខ្សែផ្ទាល់ ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិត ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុក ឬម្ដាយបង្កើតជាមួយអតីតកូនបង្កើត ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងឪពុក ឬម្ដាយចិញ្ចឹមជាមួយកូនសុំជាដើម។

ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតខ្សែផ្ទាល់ អាពាហ៍ពិពាហ៍មិនអាចធ្វើឡើងបានឡើយ រវាងញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៣ រវាងបងប្អូនបង្កើត(ញាតិលោហិតថ្នាក់ទី១) រវាងជីតា ឬជាមួយចៅ (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី២) រវាងជីទួតជាមួយចៅទួត រវាងពូ ឬមីង ជាមួយក្មួយ(ញាតិលោហិតថ្នាក់ទី៣)។

ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិត អាពាហ៍ពិពាហ៍ ហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតក្នុង ៣ថ្នាក់ រវាងបងប្អូនបង្កើត (សាខាញាតិថ្នាក់ទី២) រវាងពូ ឬមីង ជាមួយក្មួយ (សាខាញាតិថ្នាក់ទី៣)។ ចំពោះសាខាញាតិចាប់ពីថ្នាក់ទី៤ទៅ អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន ដូចជា បងប្អូនជីដូនមួយ ឬបងប្អូនជីទួតមួយជាដើម។

### ២.៣.៤. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ ទី១ អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងញាតិពន្ធនៃខ្សែផ្ទាល់។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាដែរ ក្រោយពេលដែលបានបញ្ចប់ទំនាក់ទំនងញាតិពន្ធ ដោយបញ្ញត្តិមាត្រា ៩៤១ (ការរលត់ទំនាក់ទំនងញាតិពន្ធ) ឬ មាត្រា ១០១៦ (ការកាត់កាល់នៃសុំកូនពេញលេញ) នៃក្រមនេះ។ ទី២ អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងសាខាញាតិពន្ធនៅក្នុង ៣(បី) ថ្នាក់រាប់ទាំងថ្នាក់ទី៣ (បី) ផង។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្រោយពេលបានបញ្ចប់ទំនាក់ទំនងញាតិពន្ធ

[47] សេចក្ដីកំណត់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១០ មាត្រា ៩៥០។

តាមបញ្ញត្តិមាត្រា ៩៤១ (ការរលត់ទំនាក់ទំនងញាតិពន្ធ) ខាងលើនេះ។ ប៉ុន្តែ បើសហព័ទ្ធណាម្ខាងបានទទួលមរណភាព សហព័ទ្ធដែលនៅរស់ អាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិពន្ធ នៅក្នុង ៣ ថ្នាក់បាន។[48]

ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធខ្សែផ្ទាល់ ការហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ទាំងអស់ ហើយទោះបីទំនាក់ទំនងញាតិពន្ធខ្សែផ្ទាល់ត្រូវបានបញ្ចប់ក៏ដោយមានដូចជា រវាងឪពុកម្តាយក្មេក និងកូនប្រសារ រវាងជីដូនជីតាក្មេក និងចៅប្រសារ រវាងជីដូនជីតាទួតក្មេក និងចៅទួតប្រសារ រវាងជីលួតក្មេក និងចៅលួតប្រសារ រវាងជីលាក្មេក និងចៅប្រសារ រវាងអតីតឪពុកម្តាយក្មេក និងអតីតកូនប្រសារ រវាងអតីតជីដូនជីតាក្មេក និងអតីតចៅប្រសារ រវាងអតីតជីដូនជីតាទួតក្មេក និងអតីតចៅទួត រវាងអតីតជីលួតក្មេក និងអតីតចៅលួតប្រសារ រវាងអតីតជីលាក្មេក និងអតីតចៅលាប្រសារ។

ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធនៅក្នុង៣ថ្នាក់ រាប់ថ្នាក់ទី៣ ផង ហើយទោះបីជាទំនាក់ទំនងញាតិពន្ធត្រូវបានបញ្ចប់ហើយក៏ដោយ ក៏មិនអាចរៀបអាពាហ៍ពិពាហ៍បានដែរ មានដូចជា រវាងបងថ្លៃ ប្អូនថ្លៃ (សាខាញាតិពន្ធថ្នាក់ទី២) រវាងអតីតបងថ្លៃ និងអតីតប្អូនថ្លៃ រវាងពូ ឬមីងក្មេក ជាមួយក្មួយប្រសារ (សាខាញាតិពន្ធថ្នាក់ទី៣) រវាងអតីតពូមីងក្មេក ជាមួយអតីតក្មួយប្រសារ រវាងបងប្អូនបង្កើតរបស់ប្តី ជាមួយបងប្អូនបង្កើតរបស់ប្រពន្ធ រវាងអតីតបងប្អូនបង្កើតរបស់ប្តី ជាមួយអតីតបងប្អូនបង្កើតរបស់ប្រពន្ធ។ ករណីលើកលែងអាចរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ ក្នុងករណីសហព័ទ្ធណាម្នាក់បានទទួលមរណភាព ហើយសហព័ទ្ធម្ខាងទៀតនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយសាខាញាតិរបស់សហព័ទ្ធម្ខាងទៀតបាននៅក្នុង៣ថ្នាក់បាន។ ពោលអាចរៀបអាពាហ៍ពិពាហ៍រវាងអតីតពូ មីងសាច់ថ្លៃ ឬអតីតប្អូនថ្លៃបាន។

### ២.៣.៥. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ក្រោយកាត់កាលសុំកូន

អាពាហ៍ពិពាហ៍ត្រូវបានហាមឃាត់ផងដែរ ចំពោះញាតិភាពដែលបង្កើតឡើងតាមរយៈការសុំកូនធម្មតា និងសុំកូនពេញលេញ ពីព្រោះថាកូនសុំ និងកូនបង្កើតក៏ជាញាតិនឹងគ្នា។ ក្នុងករណីសុំកូនពេញលេញ និងសុំកូនធម្មតា ត្រូវបានបង្កើតឡើងនូវទំនាក់ទំនងញាតិ (ញាតិលោហិតខ្សែផ្ទាល់ និងសាខាញាតិ) រវាងឪពុកម្តាយ និងកូនបង្កើត ត្រូវបានបញ្ចប់។ មួយវិញទៀតកូនសុំ ក្រោយបញ្ចប់ទំនាក់ទំនងសុំកូនតាមរយៈការកាត់កាលកូនសុំកូនសុំពេញលេញ និងសុំកូនធម្មតា មិនអាចរៀបអាពាហ៍ពិពាហ៍ ជាមួយនឹងបុគ្គលដែលធ្លាប់ជាញាតិលោហិត ឬសាខាញាតិលោហិតក្នុង ៣ថ្នាក់ របស់ឪពុកម្តាយចិញ្ចឹមខ្លួនបានទេ។

ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុក ឬម្តាយបង្កើតជាមួយអតីតកូនបង្កើតដែលបានបញ្ចប់ញាតិភាពជាមួយ នឹងឪពុកម្តាយបង្កើតសុំកូនពេញលេញ។ មានន័យថា ក្នុងករណីដែលអតីតឪពុកបង្កើត

[48] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥២។

ឬអតីតម្តាយបង្កើតត្រូវបានបញ្ចប់នូវភាពជាឪពុក ឬម្តាយបង្កើតដោយសារមូលហេតុណាក៏ដោយក៏អតីតឪពុកបង្កើត ឬអតីតម្តាយបង្កើត មិនរៀបអាពាហ៍ពិពាហ៍ជាមួយអតីតកូនបង្កើតរបស់ខ្លួនបានដែរ។[49]

ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងឪពុក ឬម្តាយចិញ្ចឹមជាមួយកូនសុំ ច្បាប់ហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹមជាមួយកូនសុំ។ ទោះបីជាទំនាក់ទំនងញាតិត្រូវបានកាត់ផ្តាច់ហើយដោយសារមូលហេតុណាក៏ដោយ ក៏អតីតឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយអតីតកូនចិញ្ចឹមបានដែរ។

## ២.៤. នីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍

ដើម្បីអាចរៀបចំនីតិវិធីក្នុងការចុះសំបុត្រអាពាហ៍ពិពាហ៍បានយើងត្រូវស្គាល់មន្ត្រីអត្រានុកូលដ្ឋានជាមុនសិន។ បញ្ជីអត្រានុកូលដ្ឋាន រួមមាន បញ្ជីកំណើតរស់ បញ្ជីមរណភាព និងបញ្ជីអាពាហ៍ពិពាហ៍។[50] បញ្ជីអត្រានុកូលដ្ឋានអាចរក្សាទុកក្នុងទម្រង់ជាក្រដាសនិង/ឬទម្រង់អេឡិចត្រូនិច។[51] មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ គឺជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាមន្ត្រីអត្រានុកូលដ្ឋានក្រុង ស្រុក ខណ្ឌ ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មានសមត្ថកិច្ច ពិនិត្យនិងកត់ត្រាព័ត៌មានចាំបាច់ទាក់ទងនឹងកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍។ ចេញសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ច្បាប់ដើមនិងសេចក្តីចម្លង។

### ២.៤.១. ទីកន្លែងដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

តាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ បុរសម្នាក់និងនារីម្នាក់ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវដាក់ពាក្យសុំដើម្បីរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលបុរស ឬនារីនោះរស់នៅ។[52] មានន័យថាគូភាគីទាំងពីរនាក់ត្រូវទៅសាលាឃុំ ឬសង្កាត់ ទាំងខាងផ្ទះប្រុស ឬនារីដើម្បីដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែចំពោះការចុះបញ្ជីអាពាហ៍ពិពាហ៍វិញ ដាច់ខាតត្រូវប្រព្រឹត្តឡើងនៅខាងសាលាឃុំ ឬសង្កាត់របស់នារីនោះ។

យោងអនុក្រឹត្យលេខ ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០ អាពាហ៍ពិពាហ៍ នឹងចាត់ទុកជាត្រឹមត្រូវតាមគោលការណ៍ច្បាប់បាន លុះត្រាតែបុរស និងនារីដែលស្ម័គ្រចិត្តទទួលគ្នាជា ប្តី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍

[49] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ចំណុច២ មាត្រា៩៥១។

[50] ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ មាត្រា ៥។

[51] ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម មាត្រា ៦ កថាខណ្ឌទី១។

[52] ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ មាត្រា ៦៧។

ពិពាហ៍ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់នារី។ កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខា ដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តីប្រពន្ធ និងសាក្សីគ្រប់អាយុការចំនួន ០២នាក់ផង។

ដូច្នេះ បុគ្គលដែលចង់រៀបអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ជាលាយលក្ខណ៍អក្សរ ហើយមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ និងពិនិត្យមើលដើម្បីឱ្យច្បាស់ថា មានការព្រមព្រៀងដោយសេរី (ឆន្ទៈរៀបអាពាហ៍ពិពាហ៍) របស់បុគ្គលដែលពាក់ព័ន្ធ និងគ្មានមូលហេតុដែលរារាំងដល់អាពាហ៍ពិពាហ៍នោះទេ ហើយក្រោយអំឡុងពេល ១០ ថ្ងៃ នៃការជូនដំណឹងជាសាធារណៈបានកន្លងផុតទៅ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នឹងត្រូវបានធ្វើឡើងហើយអាពាហ៍ពិពាហ៍នឹងត្រូវបានចុះបញ្ជីអាពាហ៍ពិពាហ៍។

### ២.៤.២. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

ការរៀបអាពាហ៍ពិពាហ៍នឹងត្រូវមានអានុភាព ដោយការអនុវត្តតាមនីតិវិធីតាំងពីការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងរហូតដល់ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវធ្វើដោយផ្អែកតាមនីតិវិធីដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន។[53] ទាក់ទងនឹងការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅឃុំ សង្កាត់ មន្ត្រីអត្រានុកូលដ្ឋានមានសិទ្ធិពិនិត្យមើលសារជាតុនៃអាពាហ៍ពិពាហ៍ថា តើអាពាហ៍ពិពាហ៍នោះមានភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានស្តីពីអាពាហ៍ពិពាហ៍ដែរ ឬទេ។[54] ប៉ុន្តែមានករណីខ្លះមន្ត្រីអត្រានុកូលដ្ឋាន ប្រសិនបើការពិនិត្យពាក្យសុំរៀបអាពាហ៍ពិពាហ៍ ពុំអាចទទួលយកបានឡើយ បើបានទទួលស្គាល់ថាអាពាហ៍ពិពាហ៍នោះ ផ្ទុយនឹងបញ្ញត្តិចាប់ពីមាត្រា ៩៤៥ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា ៩៥៤ (ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ) ខាងលើនេះ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត។[55] ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ត្រូវបានកំណត់ដូចខាងក្រោម៖

១- បុរសម្នាក់និងនារីម្នាក់ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានដូចមានកំណត់នៅក្នុងមាត្រា៦៧ (ទីកន្លែងដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍) នៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។ ទម្រង់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

២- ពាក្យសុំរៀបអាពាហ៍ពិពាហ៍ត្រូវភ្ជាប់នូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងឯកសារផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

---

[53] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥៥។

[54] សេចក្តីកំណត់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១០ មាត្រា ៩៥៦។

[55] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥៦។

៣- ប្រសិនបើបុរសឬនារីមិនទាន់ដល់នីតិភាព ប៉ុន្តែមានអាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍ដោយអនុលោមតាមមាត្រា ៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណីអ្នកមានអំណាចមេបាឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់បុរសឬនារីនោះ ត្រូវផ្តល់ការយល់ព្រមនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឬជាលាយលក្ខណ៍អក្សរ។

៤- មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យនិងផ្ទៀងផ្ទាត់ពាក្យសុំនិងឯកសារភ្ជាប់ដោយអនុលោមតាមមាត្រា ៩៥៦ (ការទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី។[56]

**២.៤.៣. ការប្រកាសផ្សាយជាសាធារណៈ**

យោងតាមបញ្ញត្តិច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ ការជូនដំណឹងជាសាធារណៈអំពីការរៀបអាពាហ៍ពិពាហ៍ មានដូចខាងក្រោម៖

១- ការប្រកាសជាសាធារណៈរបស់មន្ត្រីអត្រានុកូលដ្ឋានត្រូវផ្សព្វផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍តាមរយៈការបិទបណ្ណប្រកាស១(មួយ) ច្បាប់នៅលំនៅឋានរបស់នារី និង១(មួយ) ច្បាប់ទៀតនៅសាលាឃុំ សង្កាត់ នៃលំនៅឋានរបស់នារីនិងត្រូវបញ្ជូនបណ្ណប្រកាសចំនួន២(ពីរ) ច្បាប់ ទៀតទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលបុរសរស់នៅ ដើម្បីបិទបណ្ណប្រកាសនោះ១(មួយ)ច្បាប់នៅលំនៅឋានរបស់បុរសនិង១(មួយ) ច្បាប់ទៀត នៅសាលាឃុំ សង្កាត់នៃលំនៅឋានរបស់បុរស។

២- ទម្រង់និងព័ត៌មាននៃបណ្ណប្រកាសនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៣- ការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍ ត្រូវធ្វើឡើងជាប់គ្នាជាបន្តបន្ទាប់ក្នុងរយៈពេល ១០(ដប់)ថ្ងៃ ក្នុងគោលបំណងបង្កលក្ខណៈឱ្យជនដែលមានផលប្រយោជន៍នៅក្នុងរឿងនេះអាចប្ដឹងជំទាស់អាពាហ៍ពិពាហ៍នេះបាននៅក្នុងរយៈពេល១០(ដប់)ថ្ងៃនោះ។ ប្រសិនបើគ្មានការជំទាស់នៅក្នុងរយៈពេល១០(ដប់)ថ្ងៃនោះទេ អាពាហ៍ពិពាហ៍អាចធ្វើឡើងគ្រប់ពេលវេលា នៅក្នុងរយៈពេល៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។

៤- ប្រសិនបើបុរសនិងនារីដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ មិនបានមកចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអាចរំលឹកដោយការជូនដំណឹងទៅបុរសនិងនារីនោះបាន។[57]

តាមអនុក្រឹត្យលេខ ១០៣ ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទបណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងធ្វើនោះ ផ្សាយជាសាធារណៈ នៅលំនៅដ្ឋាន និង នៅសាលាឃុំ ឬ សាលាសង្កាត់ នៃសាមីខ្លួននារី ០១ ច្បាប់។ បណ្ណប្រកាសអាពាហ៍ពិពាហ៍ ០២ច្បាប់ទៀតត្រូវផ្ញើទៅជូនមន្ត្រី

[56] ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ មាត្រា ៦៨។

[57] ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ មាត្រា ៦៩។

អត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និង បិទនៅសាលាឃុំ ឬ សង្កាត់នៃសាមីខ្លួនបុរស ០១ច្បាប់។ បណ្ណប្រកាសត្រូវចុះ៖

១- នាមត្រកូល នាមខ្លួន អាយុ និង លំនៅនៃអនាគត ប្តី ប្រពន្ធ។

២- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅរបស់ ឪពុក ម្តាយ នៃអនាគត ប្តី ប្រពន្ធ បើឪពុក ឬ ម្តាយស្លាប់ ត្រូវដាក់ថាស្លាប់។

៣- រយៈពេលប្តឹងជំទាស់

បណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ដើម្បីជនដែលមានផលប្រយោជន៍ក្នុងរឿងនេះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ។ ផុតរយៈពេល ១០ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើបាន បើគ្មានការប្តឹងជំទាស់ បើមានបណ្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្តឹងជំទាស់ត្រូវបានសមត្ថកិច្ចដោះស្រាយ។[58]

អនុលោមតាមសេចក្តីណែនាំស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ស្របតាម ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៤ ទម្រង់ និងព័ត៌មានពាក្យសុំរៀបអាពាហ៍ពិពាហ៍ បណ្ណប្រកាសអាពាហ៍ពិពាហ៍ មានសុពលភាពរយៈពេល៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដាក់ពាក្យ សុំរៀបអាពាហ៍ពិពាហ៍។ បណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយជាសាធារណៈ ដោយធ្វើឡើងជាប់គ្នាជាបន្តបន្ទាប់ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ ក្នុងគោលបំណងបង្កលក្ខណៈឱ្យជនដែលមានផលប្រយោជន៍នៅក្នុងរឿងនេះ អាចប្តឹងជំទាស់អាពាហ៍ពិពាហ៍នេះបាននៅក្នុងរយៈពេល ១០ (ដប់) ថ្ងៃនោះ។ ប្រសិនបើគ្មានការជំទាស់នៅក្នុងរយៈពេល ១០ (ដប់)ថ្ងៃនោះទេ អាពាហ៍ពិពាហ៍អាចធ្វើឡើងគ្រប់ពេលវេលានៅក្នុងរយៈពេល ៦ (ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ក្នុងករណីទុកឱ្យហួសរយៈពេលនេះ បុរសនារី ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ឡើងវិញ។[59]

**២.៤.៤. ការប្តឹងជំទាស់នៃអាពាហ៍ពិពាហ៍**

បណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយជាសាធារណៈ ដោយធ្វើឡើងជាប់គ្នាជាបន្តបន្ទាប់ក្នុង រយៈពេល ១០ (ដប់)ថ្ងៃ ក្នុងគោលបំណងបង្កលក្ខណៈឱ្យជនដែលមានផលប្រយោជន៍នៅក្នុងរឿងនេះ អាចប្តឹងជំទាស់អាពាហ៍ពិពាហ៍នេះបាននៅក្នុងរយៈពេល ១០ (ដប់) ថ្ងៃនោះ។ ប្រសិនបើមានជនណាម្នាក់ដាក់ពាក្យប្តឹងជំទាស់ទៅនឹងគម្រោងរៀបអាពាហ៍ពិពាហ៍ មន្ត្រីនៃស្ថាប័នពាក់ព័ន្ធត្រូវដោះស្រាយបណ្តឹងនោះឱ្យចប់សព្វគ្រប់សិន ទើបអាចរៀបអាពាហ៍ពិពាហ៍បាន។

[58] អនុក្រឹត្យលេខ ១០៣ ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០ មាត្រា ២៩។

[59] សេចក្តីណែនាំស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានស្របតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៤។

### ២.៤.៤.១. ជនដែលអាចធ្វើបណ្ដឹងជំទាស់អាពាហ៍ពិពាហ៍

ប្រសិនបើមានជនណាម្នាក់ដាក់ពាក្យប្ដឹងជំទាស់ទៅនឹងគម្រោងរៀបអាពាហ៍ពិពាហ៍ មន្ត្រីនៃស្ថាប័ន ពាក់ព័ន្ធ ត្រូវដោះស្រាយបណ្ដឹងនោះឱ្យចប់សព្វគ្រប់សិន ទើបអាចរៀបអាពាហ៍ពិពាហ៍បាន។[60]

ជនដែលមានផលប្រយោជន៍ អាចជាសាច់ញាតិ ឪពុកម្ដាយ ឬ អ្នកអាណាព្យាបាល ឬ តតិយជនណាម្នាក់ដែលអាចមានការពាក់ព័ន្ធជាមួយអាពាហ៍ពិពាហ៍ដោយផ្ទាល់ ដូចជាភាគីដែលគ្រោងរៀបអាពាហ៍ពិពាហ៍ធ្លាប់ជាប្ដីប្រពន្ធរបស់ខ្លួន ហើយមកលួចរៀបអាពាហ៍ពិពាហ៍ជាថ្មី ឬ ធ្លាប់រស់នៅជាមួយគ្នាពីមុនដោយមិនបានរៀបអាពាហ៍ពិពាហ៍ជាដើម អាចធ្វើការប្ដឹងជំទាស់គម្រោងអាពាហ៍ពិពាហ៍ក្នុងចន្លោះពេល ១០ថ្ងៃ ចាប់ពីការបិទបណ្ណប្រកាសអំពីអាពាហ៍ពិពាហ៍ដែលគ្រោងនឹងរៀបចំនេះ។

ភស្តុតាង ដើម្បីយកទៅបង្ហាញ ក្នុងករណីដែលអ្នកទាំងពីរមានសំបុត្រស្នាក់នៅជាមួយគ្នា ឬមានសំបុត្រគ្រួសារ សម្រាប់បញ្ជាក់ទំនាក់ទំនងរវាងគ្នាទៅបង្ហាញមេឃុំ ឬ ចៅសង្កាត់ ឬ ទៅតុលាការ។ សំបុត្រស្នាក់នៅជាមួយគ្នា ឬ មានសំបុត្រគ្រួសារ មិនមែនជាសំបុត្រអាពាហ៍ពិពាហ៍ដែលបញ្ជាក់ច្បាស់ថា ភាគីទាំងពីរជាប្ដីប្រពន្ធនឹងគ្នាទេ សំបុត្រនោះគ្រាន់តែបញ្ជាក់អំពីការស្នាក់នៅ នឹងអត្តសញ្ញាណគ្រួសារប៉ុណ្ណោះ។ មេឃុំ ឬ ចៅសង្កាត់ ឬ តុលាការ នៅតែមិនមាន ភស្តុតាងសម្រាប់ការសម្រេចសេចក្ដីជំទាស់នឹងគម្រោងរៀបអាពាហ៍ពិពាហ៍។ បញ្ហានេះមិនមានវិធានច្បាប់ដោះស្រាយទេ ហើយនៅក្នុងទម្លាប់អនុវត្តរបស់មេឃុំ ឬ ចៅសង្កាត់ ឬ តុលាការ គឺអនុវត្តដូចអ្វីដែលបានរៀបរាប់ខាងលើនេះ។ គោលការណ៍នេះ មិនសមស្របឡើយសម្រាប់ភាគីដែលមិនមានដំណោះស្រាយសម្រាប់ពួកគេដោយមេឃុំ ឬ ចៅសង្កាត់ ឬ តុលាការ មិនទទួលការដោះស្រាយចំពោះការរស់នៅជាមួយគ្នាតាមរបៀបអនីតិសង្វាស។ ជាគោលការណ៍ទទួលស្គាល់អាពាហ៍ពិពាហ៍ស្របច្បាប់ ប៉ុន្តែមិនទទួលស្គាល់អាពាហ៍ពិពាហ៍មិនស្របច្បាប់។

យ៉ាងណាមិញ ក្នុងរយៈពេល១០ថ្ងៃនៃការប្រកាសអាពាហ៍ពិពាហ៍ជាសាធារណៈ មិនមានអ្នកប្ដឹងជំទាស់នោះទេ គឺពិធីមង្គលការការនោះអាចប្រព្រឹត្តទៅបានធម្មតា។ ប្រសិនបើបុរស និងនារីដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ មិនបានមកចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអាចរំលឹកដោយការជូនដំណឹងទៅបុរសនិងនារីនោះបាន។[61] បណ្ដឹងទាស់នេះ អ្នកប្ដឹងទាស់ ឬតំណាងរបស់ខ្លួនយកទៅជូនមេឃុំ ឬចៅសង្កាត់ដែលជាមន្ត្រីអត្រានុកូលដ្ឋាន ក្នុងដែនដីដែលខ្លួនគ្រប់គ្រងខាងលំនៅដ្ឋានអនាគតប្រពន្ធ ត្រូវមានសមត្ថកិច្ចពិនិត្យសម្រេចចាត់ការទៅលើបណ្ដឹងជំទាស់នឹងការរៀបអាពាហ៍ពិពាហ៍នោះ។ មេឃុំ ឬចៅសង្កាត់ត្រូវសម្រេច ក្នុងរយៈពេលឱ្យបានឆាប់និងយ៉ាងយូរក្នុងរយៈពេល ០៣ ថ្ងៃ គិតពីថ្ងៃទទួលបណ្ដឹងទាស់។ បើអ្នកប្ដឹងជំទាស់ ឬអនាគតប្ដីប្រពន្ធ មិនសុខចិត្តនឹងសេចក្ដីសម្រេចនេះទេ មេឃុំ ឬចៅសង្កាត់ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ក្នុងរយៈពេល ០៥ ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលបណ្ដឹងទាស់ដើម្បីសម្រេច។ ម៉្យាងទៀត ក្នុងករណីដែលជាបទល្មើសទ្វេពន្ធភាព បទស្មន់ បទផិត ប្ដី

[60] អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០ មាត្រា ២៩ កថាខណ្ឌទី៣។

[61] ច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ មាត្រា ៦៩។

ប្រពន្ធមុន ឬសាច់ញាតិអាចប្តឹងទៅមេ ឬប្រធាន នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំសង្កាត់ក៏បាន ដើម្បីឱ្យធ្វើការត្រួតពិនិត្យបទល្មើសកំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។

### ២.៤.៤.២. មូលហេតុជំទាស់នឹងគម្រោងរៀបអាពាហ៍ពិពាហ៍

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ពុំអាចទទួលយកបានឡើយប្រសិនបើក្នុងករណីមានមូលហេតុណាមួយដូចខាងក្រោមនេះ៖[62]

- អនាគតប្តី ឬ ប្រពន្ធមិនទាន់ដល់នីតិភាព (អាយុក្រោម១៨ឆ្នាំ) ឬ ក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតមានអាយុក្រោម១៦ឆ្នាំ
- ករណីភាគីមានសហព័ទ្ធហើយ (មានប្តី ឬ ប្រពន្ធ)
- អំឡុង ពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀតក្នុងករណីដែលនារីត្រូវបានរំលាយ ឬ លុបចោល អាពាហ៍ពិពាហ៍មុន ហើយនៅមិនទាន់គ្រប់រយៈពេល១២០ថ្ងៃ
- ករណីដែលអាពាហ៍ពិពាហ៍បានធ្វើឡើងរវាង ញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតរហូតដល់ថ្នាក់ទី៣ និងរាប់ទាំងថ្នាក់ទី៣ផង
- ករណីដែល អាពាហ៍ពិពាហ៍គ្រោងធ្វើឡើងរវាងញាតិពន្ធនៃខ្សែផ្ទាល់ ឬ អាពាហ៍ពិពាហ៍គ្រោងធ្វើឡើងរវាងសាខាញាតិពន្ធ រហូតថ្នាក់ទី៣ និងរាប់ទាំងថ្នាក់ទី៣ផង
- អាពាហ៍ពិពាហ៍របស់អនីតិជនដែលមិនមានការយល់ព្រមពីអ្នកដែល មានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន
- និងអាពាហ៍ពិពាហ៍របស់ជនវិកលចរិត (ជននៅ ក្រោមអាណាព្យាបាលទូទៅ) ដែលមិនមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមាបាន។

អាចជាភាគីដែលគ្រោងរៀបអាពាហ៍ពិពាហ៍ ធ្លាប់ជាប្តីប្រពន្ធរបស់ខ្លួន ហើយមកលួចរៀបអាពាហ៍ពិពាហ៍ជាថ្មី ឬធ្លាប់រស់នៅជាមួយគ្នាពីមុនដោយមិនបានរៀបអាពាហ៍ពិពាហ៍ជាដើម អាចប្តឹងជំទាស់គម្រោងអាពាហ៍ពិពាហ៍ក្នុងចន្លោះ១០ថ្ងៃ ចាប់ពីការបិទបណ្ណប្រកាសអំពីអាពាហ៍ពិពាហ៍ដែលគ្រោងនឹងរៀបចំនោះ។ បណ្តឹងទាស់នឹងយកជាការបាន លុះត្រាតែអ្នកប្តឹងទាស់ចុះហត្ថលេខាលើពាក្យបណ្តឹងរបស់ខ្លួន ដោយផ្ទាល់ខ្លួនឯង ហើយបង្ហាញឱ្យបានច្បាស់លាស់អំពីចំណុចដែលខ្លួនប្តឹងទាស់ រួចហើយបញ្ជូនទៅមេឃុំ ឬចៅសង្កាត់ខាងលំនៅឋាននៃអនាគតប្រពន្ធ។

នៅក្នុងករណីទាំងអស់ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានមានសិទ្ធិមិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ ឬមានសិទ្ធិប្តឹងជំទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍បាន។

---

[62] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥៦។

ដូច្នេះ មូលហេតុដែលអាចយកមកប្តឹងទាស់បានដោយហេតុថាមានច្បាប់ហាមឃាត់ចំពោះអនាគតប្តីប្រពន្ធរួមមានអនាគតប្តីប្រពន្ធមានអាយុក្រោមការកំណត់របស់ច្បាប់ អនាគតប្តីប្រពន្ធត្រូវបានហាមឃាត់ដោយសារជាប់ចំណងញាតិលោហិត ឬញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ អនាគតប្តីប្រពន្ធត្រូវហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ ដោយសារជាសាខាញាតិរហូតដល់ថ្នាក់ទី៣។

### ២.៤.៤.៣. ការសម្រេចលើការប្តឹងជំទាស់

នៅក្នុងក្រមរដ្ឋប្បវេណី មិនបានកំណត់ពីនីតិវិធី និងរយៈពេលដែលមេឃុំ ចៅសង្កាត់ អាចធ្វើការជំទាស់មិនទទួលយកសំណើរៀបអាពាហ៍ពិពាហ៍ទេ ក៏ដូចជាសិទ្ធិរបស់ភាគីក្នុងការប្តឹងតវ៉ាចំពោះការបដិសេធរបស់មេឃុំ ចៅសង្កាត់។ ប៉ុន្តែនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ បានកំណត់នូវនីតិវិធីមួយចំនួនដូចតទៅៈ

មេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្តីសម្រេចស្តីពីសុពលភាពនៃបណ្តឹងនោះក្នុងរយៈពេល៣ថ្ងៃ ប្រសិនបើមេឃុំ ចៅសង្កាត់ដែលសម្រេចជំទាស់ពីពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ទាន់ពេលវេលាហើយ ហើយដើមបណ្តឹង ឬ អនាគតប្តីប្រពន្ធ មិនយល់ស្របនឹងសេចក្តីសម្រេចរបស់មេឃុំ ចៅសង្កាត់ទេ គេអាចប្តឹងតវ៉ាទៅតុលាការ។[63]

អនាគតប្តីប្រពន្ធនោះអាចតវ៉ាដោយបញ្ជាក់នូវការមិនយល់ស្របទៅនឹងសេចក្តីសម្រេចរបស់មេឃុំ ចៅសង្កាត់ ដែលបានធ្វើសេចក្តីសម្រេច ក្នុងរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃដែលភាគីមិនយល់ស្របនឹងសេចក្តីសម្រេចនោះ មេឃុំ ចៅសង្កាត់ដែលបានធ្វើសេចក្តីសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅតុលាការ។[64]

តុលាការត្រូវពិនិត្យសំណុំរឿងឡើងវិញ ហើយចេញសេចក្តីសម្រេចក្នុងរយៈពេល៧ថ្ងៃ យ៉ាងយូរគិតពី ថ្ងៃបានទទួលសំណុំរឿង។ បើសិនតុលាការចេញសាលក្រមរក្សាទុកសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានជាការត្រឹមត្រូវ នោះភាគីពុំអាចអនុញ្ញាតឱ្យធ្វើពិធីរៀបអាពាហ៍ពិពាហ៍បានឡើយ។ បើសិនតុលាការសម្រេចបដិសេធចោលសេចក្តីសម្រេចរបស់មេឃុំ ចៅសង្កាត់ នោះពិធីរៀបអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបានដោយស្របច្បាប់។[65] សេចក្តីសម្រេចរបស់តុលាការ មិនអាចប្តឹងតវ៉ាបានឡើយ ពោលគឺមិនមានសិទ្ធិប្តឹងឧទ្ធរណ៍ទេ។

### ២.៤.៥. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍

ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ត្រូវបានធ្វើឡើងបន្ទាប់ពីបានបិទបណ្ណប្រកាសអាពាហ៍ពិពាហ៍បានចំនួន ១០ ថ្ងៃ ដោយមិនបានគិតអំពីរយៈពេលនៃការប្តឹងជំទាស់ទេ សាមីខ្លួនទាំងសងខាងត្រូវទៅសាលាឃុំសង្កាត់ ដើម្បីចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងត្រូវមានសាក្សីពីរនាក់គ្រប់អាយុការទៅជាមួយ ដើម្បីបញ្ជាក់ពីការដឹងលឺ ឬធ្វើជាសាក្សី។

[63] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ១៨ កថាខណ្ឌទី១។

[64] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ១៨ កថាខណ្ឌទី២។

[65] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ១៩។

**២.៤.៦. ការចុះបញ្ជីអាពាហ៍ពិពាហ៍**

បន្ទាប់ពីបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍រួច មន្ត្រីអត្រានុកូលដ្ឋានត្រូវស្រង់ទិន្នន័យភាគីទាំងសងខាង និងធ្វើការចុះបញ្ជីអាពាហ៍ពិពាហ៍ រួចត្រូវប្រគល់ឱ្យប្តី ប្រពន្ធ នូវ សំបុត្រអាពាហ៍ពិពាហ៍ ច្បាប់ដើម និងចេញសេចក្តីចម្លងអាពាហ៍ពិពាហ៍តាមការស្នើសុំរបស់សាមីខ្លួនដើម្បីទុកប្រើប្រាស់។ សំបុត្រចុះអាពាហ៍ពិពាហ៍ ឬ ប្រជាពលរដ្ឋទូទៅស្គាល់ថា អេតាស៊ីវិល ជាលិខិតមួយប្រភេទដែលគូស្វាមីភរិយាក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទៅសាលាឃុំ ឬសង្កាត់ ដើម្បីសុំចុះឈ្មោះក្នុងបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

ការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានៈ

១- អាពាហ៍ពិពាហ៍ត្រូវចាត់ទុកថាស្របច្បាប់ លុះត្រាណាតែបុរសនិងនារីបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ ដែលបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ។

២- ព័ត៌មានឬចំណុចដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ ត្រូវបញ្ចូលទៅក្នុងបញ្ជីអាពាហ៍ពិពាហ៍ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននិងចុះហត្ថលេខាឬផ្តិតស្នាមមេដៃដោយបុគ្គលដែលមានបំណងធ្វើជាសហព័ទ្ធនិងដោយមានសាក្សីចំនួន២(ពីរ)រូបជានីតិជន។[66] ចំពោះការសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ សាមីខ្លួន និង សាក្សី ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[67]

**២.៤.៧. ការផ្តល់សំបុត្រអាពាហ៍ពិពាហ៍**

យោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងថា អាជ្ញាធរឃុំ ឬសង្កាត់ អាចចេញសំបុត្រចុះបញ្ជីអាពាហ៍ពិពាហ៍ឱ្យគូស្វាមីភរិយាបាន លុះត្រាតែគូស្វាមីភរិយាបានដាក់ពាក្យសុំចុះបញ្ជីអាពាហ៍ពិពាហ៍នេះ និងបានធ្វើកិច្ចសន្យាអាពាហ៍ពិពាហ៍ជាលាយលក្ខណ៍អក្សរជាមុនសិន។ ទន្ទឹមនេះ អាជ្ញាធរឃុំ ឬសង្កាត់ មានសិទ្ធិចេញសំបុត្រចុះបញ្ជីអាពាហ៍ពិពាហ៍ឱ្យគូស្វាមីភរិយានេះ ត្រូវធ្វើឡើងតាមការស្ម័គ្រចិត្ត ហើយមានការដឹងឮ និងយល់ព្រមពីសាច់ញាតិនៃគ្រួសារទាំងសងខាង មានសាក្សីដែលជាជនមានសមត្ថភាពពេញលេញ ២ (ពីរ) នាក់ផងដែរ។ ការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលនេះ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការថែរក្សាចំណងអាពាហ៍ពិពាហ៍ស្វាមីភរិយាឱ្យបានយូរអង្វែង ដោយក្លាយជាប្តីប្រពន្ធពេញច្បាប់។ កាលណាមានអេតាស៊ីវិល គឺប្តីប្រពន្ធមិនអាចទៅស្រឡាញ់ ឬទាក់ទងជាមួយអ្នកណាបានទៀតឡើយ។ តែក្នុងករណីចង់លែងលះគ្នាក៏មានការលំបាកដែរ ដោយហេតុថា ត្រូវប្តឹងទៅ ដល់តុលាការ ដើម្បីឱ្យចៅក្រមកាត់សេចក្តី ទើបអាចលែងគ្នាបាន។ អនុលោមភាពតាម ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ បញ្ញត្តិថា ក្រោយពេលចុះបញ្ជីអាពាហ៍ពិពាហ៍រួចរាល់ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម១(មួយ)ច្បាប់ជូនប្តីប្រពន្ធនោះដោយឥតគិតថ្លៃ។[68]

[66] ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ មាត្រា ៧០។

[67] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០ មាត្រា៤ កថាខណ្ឌទី២។

[68] ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ មាត្រា ៧១។

## ២.៥. អានុភាពនៃអាពាហ៍ពិពាហ៍

បន្ទាប់ពីការរៀបអាពាហ៍ពិពាហ៍រួច ប្តី ប្រពន្ធត្រូវសិទ្ធិ និងករណីយកិច្ចជាមួយគ្នាចាប់តាំងពីពេលអាពាហ៍ពិពាហ៍នោះ មានសុពលភាពរហូតមក។ កាលណាមនុស្សពីរនាក់រៀបអាពាហ៍ពិពាហ៍ជាមួយគ្នាគេទាំងពីរនាក់ត្រូវមានការទទួលខុសត្រូវខ្លះចំពោះគ្នាទៅវិញទៅមក និងចំពោះកូនរបស់ពួកគេដែលបានបង្កើតក្នុងចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាមក។ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងអំពីអានុភាពនៃអាពាហ៍ពិពាហ៍របស់ប្តី ប្រពន្ធក្នុងចំណងអាពាហ៍ពិពាហ៍នោះ។ អានុភាពនៃអាពាហ៍ពិពាហ៍ត្រូវបានបែងចែកជា ២ (ពីរ) ធំៗ គឺ ២.៥.១. អានុភាពក្រៅបេតិកភណ្ឌ និង ២.៥.២. អានុភាពផ្នែកបេតិកភណ្ឌ។ ២.៥.១. អានុភាពក្រៅបេតិកភណ្ឌត្រូវបានចែកជាលម្អិតដូចជា ២.៦.១.១. សិទ្ធិប្រើប្រាស់នាមត្រកូល ប្តី ប្រពន្ធ ២.៥.១.២. ទទួលបាននីតិជនតាមរយៈអាពាហ៍ពិពាហ៍ ២.៥.១.៣. សិទ្ធិអំណាចមេបាលើកូន ២.៥.១.៤. ករណីយកិច្ចរួមរស់ សហការ និងជួយសង្គ្រោះគ្នា ២.៥.១.៥. សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និងសិទ្ធិចូលរួមក្នុងសង្គម។ និង ២.៥.២. អានុភាពផ្នែកបេតិកភណ្ឌ ត្រូវបានចែកជាលម្អិតដូចជា ២.៥.២.១. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ២.៥.២.៤. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយច្បាប់។ បន្ទាប់មកយើងនឹងធ្វើការពន្យល់លម្អិតអំពីអានុភាពនៃអាពាហ៍ពិពាហ៍ជាបន្តបន្ទាប់ដូចខាងក្រោម៖

### ២.៥.១. អានុភាពក្រៅបេតិកភណ្ឌ

សិទ្ធិក្រៅបេតិកភណ្ឌ ជាសិទ្ធិដែលភ្ជាប់ទៅនឹងបុគ្គលជាម្ចាស់សិទ្ធិ គឺជាសិទ្ធិគ្រួសារ ហើយនឹងសិទ្ធិបុគ្គលភាព។ សិទ្ធិនេះមិនទាក់ទងនឹងទ្រព្យសម្បត្តិ មិនអាចគិតជាប្រាក់បាននោះឡើយ។ សិទ្ធិគ្រួសារ សិទ្ធិនេះមានមូលដ្ឋានគ្រឹះរបស់វាគឺការរៀបចំគតិយុត្តរបស់គ្រួសារ។ ជាសិទ្ធិដែលគ្រប់គ្រងទៅលើទំនាក់ទំនងរបស់សមាជិកភាពនៃគ្រួសារជាមួយគ្នា ទំនាក់ទំនងរវាងប្តី ប្រពន្ធ និងកូនរបស់គេ (អំណាចមេបា)។ សិទ្ធិបុគ្គលភាព សិទ្ធិនេះមានសារៈសំខាន់ជាងសិទ្ធិឯទៀត។ ដូច្នេះច្បាប់ការពារបុគ្គលភាពរបស់មនុស្សម្នាក់ៗ គឺការពារបណ្តាចរិតលក្ខណៈខាងរូបកាយ ហើយនឹងខាងផ្លូវចិត្តរបស់បុគ្គល។ សិទ្ធិខាងបូរណភាពរូបរាងកាយ មនុស្សម្នាក់ៗមានសិទ្ធិលើបូរណភាពនៃរូបរាងកាយរបស់ខ្លួនផ្ទាល់ សិទ្ធិលើអាយុជីវិតលើរូបរាងកាយដែលតម្រូវឱ្យមានការគោរពពីអ្នកដទៃ។ ការប៉ះពាល់ ការបង្កឱ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ហើយនឹងបើកឱ្យជនរងគ្រោះដែលបណ្តាលមកអំពីព្យសនកម្មលើរូបរងកាយទាមទារសំណងជួសជុលការអន្តរាយ។ សិទ្ធិបូរណភាពខាងផ្លូវចិត្ត ឬការការពារក្រៅរូបរាងកាយ បុគ្គលម្នាក់ៗមានសិទ្ធិការពារបុគ្គលភាពរបស់ខ្លួន ចំពោះការប៉ះពាល់ទៅនឹងរូបរាងកាយរបស់ខ្លួនផ្ទាល់ និងការប៉ះពាល់ទៅនឹងសិទ្ធិផ្សេងៗដែលគេចាត់ទុកថាជាសិទ្ធិចម្បងរបស់បុគ្គលម្នាក់ៗ។

### ២.៥.១.១. សិទ្ធិប្រើប្រាស់នាមត្រកូលប្តី ប្រពន្ធ

ផ្អែកតាមការកំណត់នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តីប្រពន្ធ អាចប្រើនាមត្រកូលរបស់ប្តី ឬ ប្រពន្ធ ឬ អាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន។[69] នាមត្រកូលត្រូវបានយកមកអនុវត្តក្នុងសង្គមកម្ពុជាបច្ចុប្បន្នច្រើនហើយសព្វថ្ងៃនេះ ដោយអ្នកគិតថាការដាក់របៀបនេះជាការបង្ហាញពីការស្រឡាញ់ទៅលើ ប្រពន្ធឬប្តី ហើយក៏បង្ហាញថាបុគ្គលនោះជាប្តីឬប្រពន្ធរបស់នរណាម្នាក់ផងដែរ។ ភាគច្រើននាមត្រកូលដែលបានយកមកដាក់នោះគេតែងតែឃើញដាក់នៅខាងក្រោយ នាមត្រកូលរបស់ម្ចាស់នាមនោះទៅវិញ ប្តីអាចដាក់នាមត្រកូលប្រពន្ធ និងប្រពន្ធអាចដាក់នាមត្រកូលប្តី។

សិទ្ធិប្រើប្រាស់នាមត្រកូល ត្រូវបានគោរពសិទ្ធិស្វ័យសម្រេចចំពោះនាមត្រកូល សិទ្ធិបុគ្គល និង ធានារបបដែលប្តីប្រពន្ធអាចជ្រើសរើសប្រើនាមត្រកូលខុសគ្នា។ ជាគោលការណ៍ ប្តីប្រពន្ធនៅប្រទេសកម្ពុជា ប្រើនាមត្រកូលខុសគ្នា ដោយសារតែនាមត្រកូលបង្ហាញឱ្យតំណខ្សែលោហិត ឬសគល់នៃឪពុកម្តាយ និងដូនតា ហើយដោយសារតែវាមានតួនាទីសម្គាល់អត្តសញ្ញាណរបស់ជនគ្រប់រូបជាមួយនឹងនាមខ្លួន។

ឧទាហរណ៍ ជាក់ស្តែងក្នុងសង្គមការប្រើប្រាស់នូវនាមត្រកូលប្តីប្រពន្ធ គេសង្កេតឃើញថាភាគច្រើនមានតែភាគីប្រពន្ធតែប៉ុណ្ណោះ ដែលយកនាមត្រកូលប្តីមកប្រើប្រាស់ជាពិសេសអ្នកដែលមានឋានៈ ឬគោរម្យងារខ្ពង់ខ្ពស់(សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលឈ្មោះភរិយារបស់លោកគឺ សម្តេចគិតព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន) និងលោកជំទាវទី១ បណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត ជាដើម។

### ២.៥.១.២. ករណីយកិច្ចរួមរស់ សហការ និងជួយសង្គ្រោះគ្នា

ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ និងសង្គ្រោះគ្នាទៅវិញទៅមក។[70] ក្រោយពេលរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធទាំងពីរមានករណីយកិច្ចរួមរស់សហការគ្នា ជួយរំលែកទុក្ខធុរៈគ្នាទៅវិញទៅមក និងចូលរួមគ្នាក្នុងការដោះស្រាយបញ្ហាក្នុងគ្រួសារទាំងអស់គ្នាផងដែរ។ ក្រៅពីមានករណីយកិច្ចរវាងសហព័ទ្ធនោះមានទំនាក់ទំនងសហព័ទ្ធ និងញាតិផងដែរ ក្រោយពីការរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធម្ខាងបានក្លាយទៅជាសមាជិករបស់គ្រួសារម្ខាងទៀត។ គោលបំណងនៃអាពាហ៍ពិពាហ៍នោះដែលចង់ពង្រីកសមាជិកគ្រួសារឱ្យកាន់តែធំជាងមុនបន្តទៀត ទោះបីសហព័ទ្ធម្ខាងមិនមែនជាញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀតក៏ដោយ ប៉ុន្តែសហព័ទ្ធនោះមានករណីយកិច្ច គោរពញាតិ និងគោរពសិទ្ធិរបស់សមាជិកក្នុងគ្រួសារនោះផងដែរ មិនត្រឹមតែប៉ុណ្ណោះត្រូវសង្គ្រោះគ្នាទៅវិញទៅមក។ ហើយសមាជិកម្នាក់ៗក្នុងគ្រួសារត្រូវបង្ការកុំឱ្យមានអំពើហឹង្សាក្នុងគ្រួសារ និងត្រូវធ្វើយ៉ាងណាកុំឱ្យមានការកើតឡើងនូវការរំលោភសិទ្ធិមនុស្ស។

ឧទាហរណ៍ លោក បញ្ញា និងអ្នកស្រី កញ្ញា បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ក្រោយពេលរៀបអាពាហ៍ពិពាហ៍នោះ គាត់បានដាក់ទ្រព្យរួមគ្នា ហើយគាត់បានទទួលកូនម្នាក់ឈ្មោះ មករា ជាចំណងដៃនៃ

---

[69] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦៥។

[70] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦៦។

អាពាហ៍ពិពាហ៍ពួកគាត់ទាំងពីរនាក់។ នៅពេលដែលគ្រួសាររបស់ពួកគាត់មានបញ្ហា ពួកទាំងពីរនាក់ បានរួមគ្នាសង្គ្រោះគ្នាទៅវិញទៅមក និងយិតយោងគ្រួសារឡើងវិញ។

### ២.៥.១.៣. សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និងសិទ្ធិចូលរួមក្នុងសង្គម

ប្តី ប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សង្គម រៀងៗខ្លួនបាន។[71] ទោះបីជាអាពាហ៍ពិពាហ៍ ជាចំណងភ្ជាប់កាតព្វកិច្ចជាមួយគ្នារវាងប្តីប្រពន្ធ និងជាចំណងចងភ្ជាប់គ្នាគ្រប់សកម្មភាពរវាងគ្នានឹងគ្នាទៅវិញទៅមកក៏ដោយ ក៏ក្រមរដ្ឋប្បវេណីបានផ្តល់សេរីភាពដល់ប្តីប្រពន្ធក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សាសនា សង្គមរៀងៗខ្លួន។ ប្រពន្ធមានសេរីភាពធ្វើការងារដែលខ្លួនពេញចិត្តនឹងធ្វើ ហើយប្តីវិញក៏ដូចគ្នា។ ប្រពន្ធមានសិទ្ធិស្រឡាញ់នឹងគាំទ្រគណបក្សនយោបាយណាដែលខ្លួនពេញចិត្ត ហើយប្តីមានសិទ្ធិស្រឡាញ់គណបក្សណាដែលខ្លួនពេញចិត្ត។ ប្តីប្រពន្ធក៏មានសិទ្ធិក្នុងការគោរពជំនឿសាសនារៀងៗខ្លួន ការចេញពីសាសនាណាមួយទៅប្រតិបត្តិសាសនាណាមួយទៀត ដែលខ្លួនពេញចិត្តក៏បាន។

ឧទាហរណ៍ ប្តីមិនចង់ឱ្យភរិយាទៅធ្វើការងារ ដោយចង់ឱ្យភរិយានៅផ្ទះមើលថែកូន ឬករណីខ្លះប្តីមិនចង់ឱ្យភរិយាធ្វើជាអ្នកសិល្បៈ ជាតារាភាពយន្ត ជាអ្នកចម្រៀង ភាគច្រើនភរិយាបានយល់ព្រមលះបង់ ដោយលើកហេតុផលថា ដើម្បីសុភមង្គលគ្រួសារ។

### ២.៥.១.៤. ទទួលបាននីតិភាពតាមរយៈអាពាហ៍ពិពាហ៍

ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវបានចាត់ទុកថាបានដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នេះ។[៧២] ក្នុងករណីនេះ អនីតិជនត្រូវបានចាត់ទុកជាអ្នកមានសមត្ថភាពគតិយុត្ត ដែលជននោះមានសិទ្ធិ និងកាតព្វកិច្ចតាមផ្លូវច្បាប់ផងដែរ។ បើក្រឡេកមើលច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលបាននិរាករណ៍វិញ អាចរៀបអាពាហ៍ពិពាហ៍បាន បុរសចាប់ពីអាយុ ២០ ឆ្នាំឡើង នារីចាប់ពីអាយុ ១៨ ឆ្នាំឡើង ក្នុងករណីច្បាប់នេះបានមោឃភាពអោយបុរស នារីនោះមានអាយុពេញវ័យក្នុងការរៀបអាពាហ៍ពិពាហ៍បាត់ទៅវិញ ដែលមានសមត្ថភាពគតិយុត្តមានសិទ្ធិ និងកាតព្វកិច្ចហើយ។ ប្រសិនបើយើងគិតទៅលើក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ វិញ ត្រូវបានប្រើប្រាស់នូវគោលការណ៍សន្មតថាដល់នីតិភាពតាមរយៈអាពាហ៍ពិពាហ៍វិញ ដោយសារគេមើលលក្ខខណ្ឌរបស់ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ក្នុងការរៀបអាពាហ៍ពិពាហ៍បាននោះ បុរស នារី ត្រូវបានចែងថា បុរស នារី ដែលមិនទាន់ដល់នីតិភាពមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ក៏ប៉ុន្តែក្នុងករណីភាគីម្ខាងជាអនីតិជនអាយុចាប់ពី១៦ឆ្នាំ ហើយភាគីម្ខាងទៀតដល់នីតិភាពអាចរៀបអាពាហ៍ពិពាហ៍បានដោយមានការអនុញ្ញាតពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាល។[73] នៅពេលដែលអនីតិជននោះ បានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ អនីតិជននោះត្រូវ

---

[71] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦៧។

[72] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦៨។

[73] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៤៨។

បានចាត់ទុកថាដល់នីតិភាព។[74] អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ។ ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ ខាងលើនេះ ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាព មិនត្រូវរលត់ឡើយ។[75]

ឧទាហរណ៍ លោក លីវ មានអាយុ ២០ ឆ្នាំ និងកញ្ញា លីវយី មានអាយុ ១៦ ឆ្នាំ ពួកគេត្រូវបានឪពុកម្តាយ អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍តាមច្បាប់។ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ជាមួយលោក លីវ មក។ កញ្ញា លីវយី មានអាយុដែលច្បាប់កំណត់ដើម្បីឱ្យប្រជាពលរដ្ឋមានសិទ្ធិស៊ីវិល ឬសិទ្ធិនយោបាយ។ មានន័យថាកញ្ញា លីវយី មានសិទ្ធិក្នុងការប្រកបអាជីវកម្ម និងគ្រប់គ្រងជំនួញប្រកបដោយបុគ្គលភាពគតិយុត្តដែលជាមនុស្សមានសិទ្ធិ និងករណីយកិច្ច។ គាត់អាចមានសិទ្ធិពេញលេញក្នុងការបង្កើតកិច្ចសន្យាជាមួយអ្នកដទៃដោយសេរី។ ដែលកញ្ញា លីវយី មិនចាំបាច់មានការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលជាមុនសិនក្នុងការបង្កើតកិច្ចសន្យានោះ ហើយកិច្ចសន្យានោះមានអានុភាពក្នុងការអនុវត្តស្របតាមច្បាប់កំណត់ផងដែរ។

### ២.៥.១.៥. សិទ្ធិអំណាចមេបាលើកូន

តាមបញ្ញត្តិក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ចែងថា សិទ្ធិអំណាចមេបា គឺជាអំណាចរបស់បុគ្គលដែលមានសិទ្ធិ និងករណីយកិច្ច ត្រូវចិញ្ចឹមបីបាច់ថែរក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។[76] ម្តាយឪពុកដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា។ ប៉ុន្តែបើឪពុក ឬ ម្តាយណាម្ខាង ពុំអាចប្រើប្រាស់អំណាចមេបាបានទេ ឪពុកឬម្តាយម្ខាងត្រូវប្រើអំណាចមេបានោះ។[77] នៅពេលគូភាគីបានបង្កើតអាពាហ៍ពិពាហ៍រួចរាល់ហើយនោះ គិតគូរពីការសហការគ្នាក្នុងការចិញ្ចឹមបីបាច់កូនដែលបានកើតមកក្នុងនោះផងដែរ ពួកគេបានគិតគូរពីសិទ្ធិអំណាចមេបា ដែលជាសិទ្ធិចម្បងក្នុងគ្រួសារ។ ឪពុកម្តាយ មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អក្នុងសង្គមជាតិផងដែរ។ កូនមានករណីយកិច្ចចិញ្ចឹមនិងបីបាច់ថ្នាក់ថ្នមថែរក្សាមាតាបិតាដែលចាស់ជរា។ ឪពុកម្តាយដែលបានបង្កើតកូនហើយ មិនអាចបោះបង់កូន ឬ ទុកកូនចោល ឬ បង្កើតកូនដើម្បីយកកូនធ្វើអាជីវកម្ម ឬ កេងប្រវ័ញ្ចលើកម្លាំងពលកម្មកូនបានទេ ប្រសិនបើឪពុកម្តាយធ្វើទង្វើបែបនេះពួកគេនឹងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។[78] កូនមានករណីយកិច្ចចិញ្ចឹមនិងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ។[79] ក្នុងករណីបុរស ឬស្ត្រីណាម្ខាងមានកូនជាមួយប្តី ឬប្រពន្ធនៃអាពាហ៍ពិពាហ៍មុន ដើម្បីក្លាយជាម្តាយ ឬឪពុកចិញ្ចឹមលើកូននោះត្រូវតែធ្វើការស្នុំពីភាគីម្ខាងដែលមានកូន

[74] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា២២។
[75] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ២៣ កថាខណ្ឌទី២ និងកថាខណ្ឌទី៣។
[76] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១០៣៤។
[77] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៣៦។
[78] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មាត្រា៤៧ កថាខណ្ឌទី១។
[79] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មាត្រា៤៧ កថាខណ្ឌទី២។

ប្រសិនបើនៅពេលដែលបុរស ស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីនោះ ភាគីដែលមិនមែនជាឪពុកម្តាយអាចធ្វើការសុំកូនពីសហព័ទ្ធបានដើម្បីក្លាយជាឪពុក ឬម្តាយចិញ្ចឹមលើកូននោះបាន។ ហេតុដូច្នេះពេលដែលរៀបអាពាហ៍ពិពាហ៍ កូនរបស់សហព័ន្ធនឹងក្លាយជាកូនចិញ្ចឹមរបស់ប្តី ប្រពន្ធថ្មីនោះ ហើយឪពុក ឬម្តាយចិញ្ចឹមត្រូវមានអំណាចមេបាលើកូនសុំនោះ។[80]

ឧទាហរណ៍ លោក តេងសីវ និងលោកស្រី ទាវឆាន មានកូនស្រីចំនួន ៥ (ប្រាំ) នាក់ ដែលកូនរបស់ពួកគេរស់នៅក្នុងបន្ទុករបស់អ្នកទាំងពីរនាក់ទាំងអស់។ ក្នុងន័យនេះ មានន័យថាលោក តេងសីវ និងលោកស្រី ទាវឆាន មានសិទ្ធិអំណាចមេបាលើកូនរបស់ពួកគេទាំងអស់ ដែលអ្នកទាំងពីរនាក់មានសិទ្ធិចិញ្ចឹមបីបាច់ ថែរក្សាកូនៗទាំងអស់ដែលជាបន្ទុករបស់ពួកគេ។

### ២.៥.២. អានុភាពផ្នែកបេតិកភណ្ឌ

បេតិកភណ្ឌរបស់មនុស្សម្នាក់ គឺជាការប្រមូលផ្តុំនៃសិទ្ធិហើយនឹងកាតព្វកិច្ចរបស់បុគ្គលនោះ ជាលក្ខណៈសេដ្ឋកិច្ច (ដែលអាចគិតជាប្រាក់កាសបាន)។ ពាក្យថា សិទ្ធិសំដៅលើសកម្មទ្រព្យ រីឯពាក្យថាកាតព្វកិច្ចសំដៅលើអកម្មទ្រព្យ។ នៅពេលដែលអាពាហ៍ពិពាហ៍កំពុងមានសុពលភាពទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធអាចក្លាយទៅជាទ្រព្យរួម ឬទ្រព្យដោយឡែកទៅតាមសាវតានៃទ្រព្យនោះ ប៉ុន្តែក្នុងករណីខ្លះប្តីប្រពន្ធអាចធ្វើកិច្ចសន្យាបែងចែកទ្រព្យសម្បត្តិថាទ្រព្យណាជាទ្រព្យប្តី ហើយទ្រព្យសម្បត្តិណាទៀតនោះជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។ ប្តីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និង ស្ថានភាពផ្សេងៗទៀត។[81] ប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬក្រោយអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែកិច្ចសន្យានេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និង ភាគបម្រុងបានឡើយ។ បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនោះ ត្រូវអនុលោមតាមបញ្ញត្តិនៃកថាភាគទី២ (ប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់បានកំណត់)។[82] កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ។ ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យា ផ្សេងពីប្រពន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ។[83] ហេតុដូច្នេះហើយទើបប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធចែកចេញជាពីរ គឺ ប្រព័ន្ធទ្រព្យសម្បត្តិប្តី ប្រពន្ធដែលកំណត់ដោយច្បាប់ និងប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ ដូច្នេះសិទ្ធិបេតិកភណ្ឌ គឺជាសិទ្ធិរបស់បុគ្គលដែលទាក់ទងទៅលើទ្រព្យសម្បត្តិ កេរមត៌ក បំណុល និងសិទ្ធិគ្រប់បែបយ៉ាងដែលអាចលក់បាន ផ្ទេរ រឹបអូស គិតជាប្រាក់បាន និងមានអាជ្ញាយុកាលកំណត់ហើយដែលបុគ្គលម្នាក់ត្រូវតែមានសិទ្ធិទាំងអស់នេះ បូករួមជាសាកលភាពគតិយុត្ត។

[80] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៣៥។

[81] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៧១។

[82] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦៩។

[83] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៧០។

### ២.៥.២.១. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា

ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា គឺជាកិច្ចសន្យាដែលកើតមាននៅក្រោយពេលដែលបុរស ស្រីទាំងពីរនាក់បានក្លាយជាប្តីប្រពន្ធស្របច្បាប់ ពួកគេទាំងពីរអាចជ្រើសប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់ពួកគេដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ (ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និង ប្រព័ន្ធទ្រព្យសម្បត្តិតាមកំណត់ច្បាប់) ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិដែលប្តីប្រពន្ធដែលរកបានក្នុងពេលរៀបអាពាហ៍ពិពាហ៍ព្រមទាំងដោះស្រាយនិងបញ្ចៀសជម្លោះដែលកើតមានឡើងដោយសារទ្រព្យសម្បត្តិដែលបានរកនោះ បណ្តាលមកពីការគ្រប់គ្រងមិនបានល្អ។ ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍បាន ប៉ុន្តែកិច្ចសន្យានេះមិនអាចផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងបានឡើយ។[84]

ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិនៅពេលដែលមានការលែងលះគ្នា។ ការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើជាការព្រមព្រៀងគ្នា ហើយត្រូវបំពេញបែបបទ និងទាមទារឱ្យមានការចុះបញ្ជីនៅក្រសួងយុត្តិធម៌។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ទើបធ្វើឱ្យកិច្ចសន្យានោះមានសុពលភាព។[85] ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធជាការព្រមព្រៀងរបស់ប្តីប្រពន្ធ ទៅលើសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលលើទ្រព្យសម្បត្តិសហព័ទ្ធណាម្ខាង ព្រមទាំងបំណុលដែលមានខ្លឹមសារផ្ទុយអំពីប្រព័ន្ធទ្រព្យសម្បត្តិរួមដែលកំណត់ដោយច្បាប់។ ក្នុងករណីមិនបានធ្វើកិច្ចសន្យាចំពោះទ្រព្យសម្បត្តិប្តីប្រពន្ធទេនោះ ទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធនឹងកំណត់តាមប្រព័ន្ធទ្រព្យសម្បត្តិតាមកំណត់ដោយច្បាប់។[86]

ប្រព័ន្ធទ្រព្យសម្បត្តិ ត្រូវបានធ្វើឡើងដើម្បីទប់ស្កាត់វិវាទអំពីទំនាក់ទំនងសិទ្ធិ និងករណីយកិច្ចរបស់ប្តីប្រពន្ធ។ នៅក្នុងទំនាក់ទំនងជាក់ស្តែងរបស់ប្តីប្រពន្ធមានលក្ខណៈច្រើនបែបហើយប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះ បានផ្តល់លទ្ធភាពឱ្យប្តីប្រពន្ធនូវ ជម្រើសដែលមានលក្ខណៈបត់បែនសមស្របទៅតាមភាពចាំបាច់របស់ប្តីប្រពន្ធជាក់លាក់។ ដូច្នេះកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ក៏មានអានុភាពសម្របសម្រួលការពិភាក្សាអំពីទ្រព្យសម្បត្តិប្តីប្រពន្ធនាពេលអនាគតផងដែរ។ នៅក្នុងច្បាប់បានទទួលស្គាល់ការធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ឬមុនពេលរៀបអាពាហ៍ពិពាហ៍ ឬអាចកែប្រែកិច្ចសន្យានៅក្រោយអាពាហ៍ពិពាហ៍ក៏ត្រូវបានទទួលស្គាល់ផងដែរ។ ប៉ុន្តែដើម្បីការពារតតិយជន ច្បាប់ក៏បានហាមឃាត់ការធ្វើកិច្ចសន្យា និងការកែប្រែណាដែលប៉ះពាល់ដល់សិទ្ធិរបស់តតិយជនផងដែរ។

ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ដែលបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ត្រូវបានតាក់តែងឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ទើបសញ្ញាណនៃការកំណត់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

---

[84] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦៩ កថាខណ្ឌទី១។

[85] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៧០។

[86] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៩។

តាមកិច្ចសន្យា ត្រូវបានដាក់បញ្ចូលក្នុងក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧ របស់ប្រទេសកម្ពុជា មានចែងនៅត្រង់មាត្រា ៩៦៩ ដល់មាត្រា ៩៧០។

បើផ្អែកតាមតែបញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រឹមតែ ២ មាត្រា មិនមានភាពគ្រប់គ្រាន់សម្រាប់ក្នុងការអនុវត្តឡើយ ពីព្រោះថាបើយោងតាមទាំង ២ មាត្រានេះ មិនបានបង្ហាញអំពីបែបបទ នីតិវិធី និងទម្រង់នៃការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យាឡើយ។ ចំពោះការកំណត់អំពីបែបបទ នីតិវិធី និងទម្រង់នៃការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា គឺត្រូវបានបញ្ញត្តិនៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌នោះ គឺប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នាថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣។[87] ក្រោមការចង្អុលបង្ហាញនៅក្នុង ជំពូកទី៤ ស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចាប់ពីមាត្រា ២៦ ដល់មាត្រា ៣២ នៃច្បាប់ ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១។ ជាតួយ៉ាងដើម្បីជ្រើសរើសការគ្រប់គ្រងទ្រព្យសម្បត្តិតាមប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ។

**២.៥.២.២. នីតិវិធីនៃការចុះបញ្ជី**

ក. ស្ថាប័នមានសមត្ថកិច្ច

នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ បច្ចុប្បន្ន (នាយកដ្ឋានកិច្ចការច្បាប់រដ្ឋប្បវេណី និងអន្តរវិស័យ នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីរបស់ក្រសួងយុត្តិធម៌) មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ មន្ត្រីដែលទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (មន្ត្រីចុះបញ្ជី) ត្រូវនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី។[88]

ខ. ការដាក់ពាក្យសុំ

១- រាល់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើឡើងជាលាយលក្ខណ៍ អក្សរ។ ពាក្យសុំច្បាប់ដើម ត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ដោយភ្ជាប់មក ជាមួយនូវច្បាប់ថតចម្លងនៃច្បាប់ដើមនោះ។

២- ជាគោលការណ៍ ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវធ្វើឡើងរួមគ្នា។ លើកលែងតែករណីដូចខាងក្រោម អាចដាក់ពាក្យសុំតែ ម្នាក់ឯងបាន៖

ក. ការផ្លាស់ប្តូរ ឬ ការកែតម្រូវតែ ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ប្តីប្រពន្ធ ឬ បុគ្គល ដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។

[87] លោកជំទាវ ចាន់ សុទ្ធាវី រដ្ឋលេខាធិការប្រចាំការក្រសួងយុត្តិធម៌ (កម្មវិធីផ្សព្វផ្សាយច្បាប់ជាមួយទីភ្នាក់ងារជប៉ុន)។

[88] ប្រកាសលេខ ៨១ ឆ្នាំ២០១៣ ប្រការ ៤។

ខ. ការចុះបញ្ជី ដោយផ្អែកលើសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចស្ថាពរ ប្ដីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដូចមានចែងនៅក្នុងមាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ខ, គ, ឃ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី។

៣- រាល់ពាក្យសុំចុះបញ្ជីខាងលើ អ្នកតំណាងក៏អាចកាន់យកមកដាក់នៅ ចំពោះមុខមន្ត្រីចុះបញ្ជី ជំនួសប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ។

៤- បុគ្គល ឬ អ្នកតំណាង ដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវយកពាក្យសុំនោះ មកដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ដោយផ្ទាល់។[89]

គ. ទម្រង់ពាក្យសុំចុះបញ្ជី

១- ទម្រង់នៃពាក្យសុំចុះបញ្ជី ត្រូវសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ពាក្យសុំចុះបញ្ជី ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើ មាន) ហើយត្រូវគោរពចូលមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ។

២- ក្រៅពីនេះ ត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីទាក់ទង នឹងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យ សម្បត្តិប្ដីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ។[90]

ឃ. ឯកសារភ្ជាប់ជាមួយពាក្យសុំ

១- នៅពេលដាក់ពាក្យសុំចុះបញ្ជី អ្នកដាក់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្ដី ប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យា ទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ ត្រូវផ្ដល់ឯកសារចាំបាច់មួយចំនួនទៅឱ្យ នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនោះ។

២- ចំពោះពាក្យសុំចុះបញ្ជី ដែលអ្នកតំណាងយកមកដាក់ ដូចមានចែងក្នុងប្រការ ១៥ កថាខណ្ឌ ទី៣ ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិតំណាងផងដែរ។[91] ជាមួយនិងការប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់៖

១- ចំពោះឯកសារដែលភ្ជាប់ជាមួយនឹងពាក្យសុំ អ្នកដាក់ពាក្យសុំអាចទាមទារឱ្យប្រគល់វិញនៅ ពេលដាក់ពាក្យសុំ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ចំពោះលិខិតប្រគល់សិទ្ធិតំណាង។

[89] ប្រកាសលេខ ៨១ ឆ្នាំ២០១៣ ប្រការ ១៥។

[90] ប្រកាសលេខ ៨១ ឆ្នាំ២០១៣ ប្រការ ១៦។

[91] ប្រកាសលេខ ៨១ ឆ្នាំ២០១៣ ប្រការ ១៧។

២- ដើម្បីទាមទារឱ្យប្រគល់ឯកសារភ្ជាប់ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនឹងពាក្យសុំនោះ នូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ថា ការសរសេរនៅក្នុងឯកសារនោះគ្មានភាពខុសពីច្បាប់ដើម។

៣- ក្នុងករណីដែលប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់ មន្ត្រីចុះបញ្ជីត្រូវឱ្យអ្នកទទួលការប្រគល់ សរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នូវការណ៍ ដែលខ្លួនបានទទួលការប្រគល់ឯកសារ នោះ និងចុះហត្ថលេខា។[92]

ង. មូលហេតុនៃការចុះបញ្ជី

អនុលោមតាមប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានការចែង អំពី កម្មវត្ថុនៃការចុះបញ្ជីអំពីចំនួន ៧ យ៉ាងផ្សេងៗដូចជា៖

១. សំណើសុំចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ

២. សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ

៣. សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរឈ្មោះ ឬអាសយដ្ឋាន

៤. សំណើសុំចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ

៥. សំណើសុំចុះបញ្ជីអំពីការលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ

៦. សំណើសុំចុះបញ្ជីអំពីកាលបរិច្ឆេទរៀបអាពាហ៍ពិពាហ៍

៧. សំណើសុំចេញលិខិតបញ្ជាក់។

ទាំងអស់នេះ បានសេចក្តីថាការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺជាអាចធ្វើការផ្លាស់ប្តូរ កែប្រែ និងលុបចោលបាន។ បន្ទាប់ពីបញ្ជាក់អំពីកម្មវត្ថុនៃពាក្យសុំ មានការតម្រូវឱ្យបង្ហាញពី គោលបំណង មូលហេតុនិងខ្លឹមសារនៃកម្មវត្ថុនោ។ ជាពិសេសជាងនេះទៅទៀត អ្នកដាក់ពាក្យសុំចុះបញ្ជី អាចជាសហព័ទ្ធក៏បាន និងអាចអ្នកតំណាងក៏បាន។

ច. ការចេញលិខិតបញ្ជាក់

១- នៅពេលបានទទួលពាក្យសុំឱ្យចេញលិខិតបញ្ជាក់ មន្ត្រីចុះបញ្ជីត្រូវថតចម្លងចេញពីសន្លឹក ចុះបញ្ជីក្នុងក្របខណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទៅឱ្យអ្នកដាក់ពាក្យសុំ ដោយត្រូវសរសេរនៅ លើឯកសារថតចម្លងថា៖

- បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- កាលបរិច្ឆេទ (ថ្ងៃទី.........ខែ.............ឆ្នាំ..........)
- ហត្ថលេខាបំព្រួញរបស់មន្ត្រីចុះបញ្ជី និង ហត្ថលេខា និង ប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏អាចឱ្យរដ្ឋលេខាធិការទទួលបន្ទុកកិច្ចការរដ្ឋប្បវេណី ចុះហត្ថលេខាជំនួសបានដែរ។

[92] ប្រកាសលេខ ៨១ ឆ្នាំ២០១៣ ប្រការ ១៨។

២- ក្រោយពីបានទទួលពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ក្រសួងយុត្តិធម៌ត្រូវចេញលិខិតបញ្ជាក់ ឱ្យអ្នកដាក់ពាក្យសុំនោះ ដោយពុំមានការយឺតយ៉ាវ យ៉ាងយូរបំផុតមិនឱ្យលើសពីរយៈពេល ៣ ថ្ងៃ។[93] ជាមួយរបៀបនៃការដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់៖

១- ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

២- ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ត្រូវដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌។

៣- ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

- គោលបំណងនៃពាក្យសុំ ៖ ការសុំឱ្យចេញលិខិតបញ្ជាក់
- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់
- ឈ្មោះរបស់អ្នកតំណាងនីតិបុគ្គល ក្នុងករណីដែលអ្នកដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់
- ជានីតិបុគ្គល
- ចំណុចដែលត្រូវធ្វើការបញ្ជាក់
- ចំនួនលិខិតបញ្ជាក់
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬ ស្នាមម្រាមដៃ។

៤- អ្នកដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ត្រូវបង់សោហ៊ុយសេវា ដូចបានកំណត់តាមបទប្បញ្ញត្តិ ឬ ប្រកាសរួម របស់ក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[94]

### ២.៥.២.៣. អានុភាពនៃការចុះបញ្ជី

ចំពោះប្ដីប្រពន្ធបាន និងបំរុងបង្កើតនូវចំណងអាពាហ៍ពិពាហ៍ ហើយបានទៅចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ក្នុងគោលបំណងកំណត់ និងបែងចែករវាងទ្រព្យរួម និងទ្រព្យដោយឡែកគឺនាំឱ្យ មានភាពងាយស្រួលចំពោះសហព័ទ្ធនៅក្នុងការប្រើប្រាស់សិទ្ធិលើទ្រព្យដែលខ្លួនមាន លើសពីនេះទៅទៀតនៅពេលដែលសហព័ទ្ធឈានដល់ការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ហើយមានជម្លោះដែលទាក់ទងទៅនឹងបញ្ហាទ្រព្យ នោះកិច្ចសន្យាដែលទាក់ទងនឹងការចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធនឹងក្លាយជាកម្មវត្ថុដ៏សំខាន់នៅក្នុងការបែងចែកទ្រព្យ។ យ៉ាងណាមិញនៅក្នុងប្រទេសកម្ពុជាយើងវិញ នៅមានប្រជាពលរដ្ឋមួយចំនួន ដែលឱ្យតម្លៃទៅលើការរៀបអាពាហ៍ពិពាហ៍ ការប្រារព្ធពិធីតាមបែបទំនៀមទំលាប់ប្រពៃណី ក៏ប៉ុន្តែពួកគាត់បែរជាមិនសូវមានការយកចិត្តទុកដាក់ទៅលើការចុះសំបុត្រអាពាហ៍ពិពាហ៍ទៅតាមនីតិវិធី និងការកំណត់របស់ច្បាប់ទៅវិញ។ ទាំងនេះបញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋកម្ពុជាមួយចំនួនពុំទាន់មានការយល់ដឹងច្បាស់លាស់អំពីបញ្ហា ដែលទាក់ទងទៅនឹងបទបញ្ញត្តិច្បាប់នៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ព្រមទាំងអានុភាពគតិយុត្តក្រោយពីទទួលបានការចុះ

[93] ប្រកាសលេខ ៨១ ឆ្នាំ២០១៣ ប្រការ ៥៩។

[94] ប្រកាសលេខ ៨១ ឆ្នាំ២០១៣ ប្រការ ៥៨។

បញ្ជីទ្រព្យសម្បត្តិ។ អានុភាពកិច្ចសន្យាប្ដីប្រពន្ធមានលក្ខណៈទូលាយ និងមានអានុភាពទាំងចំពោះភាគីនៃកិច្ចសន្យាពោលគឺ ប្ដី និងប្រពន្ធ ព្រមទាំងមានអានុភាពសម្រាប់តាំងចំពោះតតិយជនផងដែរ។

ក. អានុភាពចំពោះគូភាគី

ការចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធ អាចធ្វើឡើងនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ឬក្រោយអាពាហ៍ពិពាហ៍ក៏បាន គ្រាន់តែការចុះនោះតម្រូវឱ្យគោរពតាមនីតិវិធីច្បាប់ឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីធានាបាននូវអានុភាពនៃកិច្ចសន្យានោះ និងស្របទៅតាមគោលការណ៍គតិយុត្ត។ ការចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធនេះនឹងបង្កើតនូវអានុភាពចំពោះភាគីនៃកិច្ចសន្យាដែលបានចុះបញ្ជីនោះ ហើយត្រូវបានកំណត់ដ៏ជាក់លាក់មួយអំពីទំហំ នៃទ្រព្យដែលសហព័ទ្ធទាំងសងខាងមាន ព្រមទាំងបង្កើនឱ្យមានភាពច្បាស់លាស់ចំពោះសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យ និងកាតព្វកិច្ចដែលភាគីនីមួយៗត្រូវបំពេញ ឬការអនុវត្ត។ ក្រៅពីការបង្កើតនាំឱ្យមានអានុភាពដល់សហព័ទ្ធដែលជាភាគីនៃកិច្ចសន្យា(ក. អានុភាពចំពោះគូភាគី) ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ក៏បង្កើតនូវអានុភាពចំពោះតតិយជន(ខ. អានុភាពចំពោះតតិយជន) ផងដែរ។ អានុភាពចំពោះភាគី ត្រង់នេះបានបង្ហាញឱ្យឃើញពីភាពច្បាស់លាស់ ចំពោះសិទ្ធិ និងកាតព្វកិច្ចដែលភាគី ជាប្ដី និងប្រពន្ធត្រូវបំពេញ។ ចំពោះទ្រព្យសម្បត្តិដោយឡែកដែលរបស់ប្ដី ឬប្រពន្ធតែម្ខាងមិនអាចរឹបអូសបាន ឬលក់ដោយគ្មានការបង្ហាញឆន្ទៈរបស់កម្មសិទ្ធិទេ គឺមិនអាចធ្វើបានទេ លើកលែងតែក្នុងករណីដែលមានការអនុញ្ញាតដោយមានបទបញ្ញត្តិច្បាប់បានបញ្ញត្តិជាមុនទៅករណីមួយចំនួន។

ឧទាហរណ៍ នៅពេលដែលប្ដីបានជំពាក់បំណុលគេ ហើយពុំមានលទ្ធភាពនៅក្នុងការសងទើបត្រូវបានម្ចាស់បំណុលរឹបអូសយកទ្រព្យរបស់ខ្លួនជំនួស ប៉ុន្តែរឹបអូសអាចធ្វើបាន ត្រូវគោរពនូវគោលការណ៍ដែលបានកំណត់នៅក្នុងខ្លឹមសារនៃបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដី ប្រពន្ធចំពោះទំហំទ្រព្យ។ មានន័យថា គេអាចរឹបអូសត្រឹមទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ម្ចាស់បំណុលនោះ មិនអាចបំពានរឹបអូសនូវទ្រព្យរបស់ម្ចាស់កម្មសិទ្ធិដទៃឡើយ។

ខ. អានុភាពចំពោះតតិយជន

ចំពោះតតិយជនដែលមានផលប្រយោជន៍ ឬមានបំណងចង់បញ្ជាក់នូវទំហំទ្រព្យសម្បត្តិរបស់ប្ដី ឬប្រពន្ធពោលគឺ មានបំណងចង់ដឹងអំពីការកំណត់នូវទ្រព្យសម្បត្តិរបស់ភាគីណាម្ខាងនៃកិច្ចសន្យា ឱ្យបានច្បាស់លាស់ដើម្បីជាមូលដ្ឋាននៅក្នុងការសម្រេច ធ្វើកិច្ចគតិយុត្តណាមួយជាមួយភាគីប្ដី ឬប្រពន្ធជៀសវាងការខូចបង់ទ្រព្យរបស់ខ្លួននោះ តតិយជននោះអាចស្នើសុំចេញនូវលិខិតបញ្ជាក់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនេះបាន។

គួរបញ្ជាក់ផងដែរថា តតិយជនដែលអាចទាមទារឱ្យមានការចេញនូវលិខិតបញ្ជាក់នោះ អាចជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានផលប្រយោជន៍ចំពោះទ្រព្យ ហើយចំពោះការសុំចេញលិខិតបញ្ជាក់នេះត្រូវតែគោរពតាមគោលការណ៍ និងលក្ខខណ្ឌដែលច្បាប់បានកំណត់ ជាពិសេសការបញ្ជាក់ពីគោលបំណង ឬកម្មវត្ថុនៃការសុំនោះជាដើម។

### ២.៥.២.៤. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយច្បាប់

ប្រទេសកម្ពុជាជាប្រទេសនីតិរដ្ឋដោយយកច្បាប់ជាចម្បងក្នុងករណីដែលប្រទេសមានច្បាប់ហើយនោះគេត្រូវយកមកអនុវត្តនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃផងដែរ។ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកំណត់ដោយច្បាប់ គឺជាប្រពន្ធទ្រព្យសម្បត្តិមួយប្រភេទដែលប្តីប្រពន្ធពុំចាំបាច់មានព្រមព្រៀងគ្នាអ្វីនោះឡើយ ដោយប្រព័ន្ធទ្រព្យសម្បត្តិនេះត្រូវបានសន្មតថា ទ្រព្យប្រភេទណាជាទ្រព្យដោយឡែក និងទ្រព្យណាទៀតនោះជាទ្រព្យរួមរបស់ប្តីប្រពន្ធនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍។ ហេតុដូច្នេះហើយទើបទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយច្បាប់បែងចែកជាពីរគឺ ទ្រព្យសម្បត្តិប្តីប្រពន្ធដោយឡែក និង ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។ ការសន្មតទ្រព្យដោយឡែក និងទ្រព្យរួមរបស់ប្តីប្រពន្ធនេះដើម្បីបង្ការវិវាទទ្រព្យសម្បត្តិប្តីប្រពន្ធ ព្រមទាំងងាយស្រួលក្នុងការបែងចែកទ្រព្យដោយយុត្តិធម៌ផងដែរ។

ក. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដោយឡែក

ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះ គឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់៖

ក. ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍

ខ. ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គ. ទ្រព្យសម្បត្តិ ជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ក្នុងចំណុច ក និង ចំណុច ខ នេះ។[95] ដូច្នេះទ្រព្យសម្បត្តិប្តីប្រពន្ធដែលទទួលបានមុនពេលរៀបអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធណាម្ខាង ដែលជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់គេ។ សហព័ទ្ធម្នាក់ៗ មានសិទ្ធិពេញលេញក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យផ្ទាល់របស់ខ្លួន។[96]

- ទ្រព្យសម្បត្តិដែលទទួលបានមុនពេលរៀបអាពាហ៍ពិពាហ៍

ទ្រព្យសម្បត្តិដែលសហព័ទ្ធណាម្ខាងមានមុនពេលរៀបអាពាហ៍ពិពាហ៍ សំដៅលើទ្រព្យសម្បត្តិទាំងអស់ណាដែលសហព័ទ្ធណាម្ខាងបង្កើតឡើងតាមរយៈ ការប្រកបរបរការងារ ឬការរកស៊ីធ្វើអាជីវកម្មនានា។ ម្យ៉ាងទៀតទ្រព្យសម្បត្តិដែលមានមុនពេលអាពាហ៍ពិពាហ៍ដែលជាទ្រព្យសម្បត្តិដោយឡែកនោះ មិនអាចជាកម្មវត្ថុនៃទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធបានឡើយ។ ពីព្រោះទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិដោយឡែករបស់ប្តីប្រពន្ធមានមុនពេលអាពាហ៍ពិពាហ៍នោះ បានមកពីការងារខិតខំប្រឹងរបស់ភាគីណាម្ខាងនោះទេ គឺពុំមានការចូលរួមពីសំណាក់សហព័ទ្ធណាម្ខាងឡើយ ទ្រព្យសម្បត្តិទាំងអស់នោះអាចជាមានចលនវត្ថុ ឬអចលនវត្ថុជាដើម។

ឧទាហរណ៍ ណារីមានរថយន្ត ១គ្រឿង ផ្ទះ ១ខ្នង និងខ្សែកពេជ្រ ១ខ្សែ ដែលជាអំណោយរបស់ឪពុកម្តាយរបស់នាងមុនពេលរៀបអាពាហ៍ពិពាហ៍។ រីឯសុផល មានប៉ុរី ១ខ្នង ចំការទុរេន ៥ហិកតា និងរថយន្ត ១ គ្រឿង ដែលគាត់បានមកពីការខិតខំប្រឹងប្រែងរកស៊ី និងប្រាក់ខែរបស់គាត់ជាមន្ត្រីរាជការ។ ក្រោយមកណារី និង

[95] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៧២។

[96] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៧៤ ។

សុផល បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដោយស្របច្បាប់។ ដូច្នេះទោះបីជាពួកគេរៀបអាព៌ាពិពាហ៍ស្រប ច្បាប់ក៏ដោយក៏ទ្រព្យសម្បត្តិដោយឡែករបស់ពួកគេ គឺជាទ្រព្យសម្បត្តិរបស់ណារី និងសុផលដដែល។

- ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍

ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ មានសហព័ទ្ធណាម្ខាងបានទទួលទ្រព្យសម្បត្តិតាមរយៈប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទាន ទ្រព្យសម្បត្តិនោះនឹងក្លាយទៅជាទ្រព្យផ្ទាល់ខ្លួនរបស់សហព័ទ្ធណាម្នាក់។ ប្រសិនបើ ការផ្ទេរសិទ្ធិ។ ប្រទានកម្ម ជាកិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃហើយភាគីម្ខាងទៀតយល់ព្រមទទួល។[97] ឧទាហរណ៍ ក្រោយពីរៀបអាពាហ៍ពិពាហ៍រវាងលោក សុផល និងណារី បានប្រហែល ១ខែ លោកតារបស់លោកសុផល(ទាយក) បានធ្វើការប្រគល់ដីមួយប្លង់ឱ្យទៅ ចៅរបស់គាត់(បដិគ្គាហក)។ ក្នុងករណីបែបនេះ ទោះបីជាប្រទានកម្មធ្វើក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ក៏ត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិដោយឡែកដែរ តាមរយៈប្រទានកម្ម។

សន្តតិកម្ម ជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មរតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់ តាម ឆន្ទៈ ឬតាមច្បាប់។[98] ឧទាហរណ៍ លោក សុផល និងអ្នកស្រីណារី ក្រោយបានរៀបអាពាហ៍ពិពាហ៍ប្រហែល ២ឆ្នាំ ឪពុកលោកសុផល បានទទួលមរណភាព (មតកជន) របស់លោកសុផល។ ក្រោយមកគេបានស្រាវជ្រាវ ឃើញថាឪពុករបស់សុផល បានបន្សល់ទុកនូវទ្រព្យមាន ផ្ទះ ១ខ្នង រថយន្ត ១គ្រឿង ដី ៥ហិកតា ចម្ការ ៣កន្លែង និងមាសសុទ្ធ ១០តម្លឹង។ ក្នុងករណីនេះអ្នកស្រី ណារី មិនមែនជាសន្តតិជនរបស់ឪពុកសុផលទេ ប៉ុន្តែលោក សុផល ជាសន្តតិជនរបស់ឪពុករបស់លោក ដែលច្បាប់បានកំណត់ជាសន្តតិជន (អ្នកមានសិទ្ធិទទួលសន្តតិកម្ម ឬមរតក)។ ក្នុងនាមសន្តតិជនលោក សុផល ទទួលបាននូវទ្រព្យសម្បត្តិនូវ ផ្ទះ ១ខ្នង រថយន្ត ១គ្រឿង ដី ៥ហិ កតា ចម្ការ ៣កន្លែង និងមាសសុទ្ធ ១០តម្លឹង ទោះបីទ្រព្យនោះទទួលបានក្នុងពេលអាពាហ៍ពិពាហ៍ក៏ដោយ អ្នក ជាសន្តតិជន ត្រូវទទួលបានទ្រព្យនោះហើយទ្រព្យនោះ ជាទ្រព្យសម្បត្តិដោយឡែករបស់លោកសុផល។

អច្ច័យទាន ជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគនោះ (អច្ច័យទានសកល) ឬប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅមនុស្សម្នាក់ ឬច្រើននាក់ (អច្ច័យទានមានកំណត់)។[99] ឧទារហណ៍ បន្ទាប់ពីលោកសុផល បានរៀប អាពាហ៍ពិពាហ៍ជាមួយអ្នកស្រីណារី បាន ៣ឆ្នាំកន្លងទៅម្តាយរបស់ណារី បានទទួលមរណភាពហើយបន្សល់ ទុកបណ្តាំ (មតកសាសន៍) មួយច្បាប់ដែលបានបញ្ជាក់ខ្លឹមសារថាប្រគល់ ភោជនីយដ្ឋាន ១កន្លែង និងក្រុមហ៊ុន ១កន្លែង ទៅឱ្យអ្នកស្រីណារី។ ក្នុងករណីនេះ ភោជនីយដ្ឋាន និងក្រុមហ៊ុន ១កន្លែង ដែលម្តាយណារី (ម្ចាស់ បណ្តាំ) បានបន្សល់ទុកនោះ បានប្រគល់ឱ្យទៅអ្នកស្រីណារី (ហៅថា អច្ច័យលាភី)។ ទោះបីអ្នកស្រីណារី ទទួល

[97] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ សន្ធានុក្រម លេខរៀង ៩៩។

[98] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ សន្ធានុក្រម លេខរៀង ១៤៣។

[99] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ សន្ធានុក្រម លេខរៀង ១៧៧។

បានភោជនីយដ្ឋាន ១កន្លែង និងក្រុមហ៊ុន ១កន្លែង ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាមួយលោកសុផលក៏ដោយ ក៏ភោជនីយដ្ឋាន ១កន្លែង និងក្រុមហ៊ុន ១កន្លែងនោះត្រូវចាត់ទុកជាទ្រព្យសម្បត្តិដោយឡែកដែរ។

ដូច្នេះសម្រាប់សហព័ទ្ធ ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនដោយសេរីដោយពុំមានការយល់ព្រមពីភាគីម្ខាងទៀតឡើយ។ សហព័ទ្ធនីមួយៗមានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនដោយមានភាពឯករាជ្យ។[100] ហើយប្តីប្រពន្ធអាចអាស្រ័យផលនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់សហព័ទ្ធម្ខាងទៀត និងអាចត្រូវប្រើប្រាស់សម្រាប់អាស្រ័យនៅសម្រាប់ជីវភាពប្រចាំថ្ងៃផងដែរ។

ខ. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធរួម

ទ្រព្យសម្បត្តិរួម ជាទ្រព្យសម្បត្តិដែលរួមគ្នា ហើយសំដៅលើទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ក្រៅពីទ្រព្យសម្បត្តិដោយឡែក។ ទ្រព្យសម្បត្តិរួមជាទ្រព្យ ឬក៏ជាអ្វីៗដែលសហព័ទ្ធទាំងពីរនាក់រកបានជាមួយគ្នា ឬសហព័ទ្ធណាម្នាក់រកបាន នៅក្នុងអំឡុងពេលដែលមានចំណងអាពាហ៍ពិពាហ៍កើតឡើង។ ជាគោលការណ៍គេចាត់ទុកប្រាក់បៀវត្សរបស់សហព័ទ្ធម្នាក់ៗចាត់បញ្ចូលជាទ្រព្យសម្បត្តិរួម មានន័យថារាល់ទ្រព្យសម្បត្តិទាំងឡាយដែលទទួលបានមកពីផលឧស្សាហកម្មផ្ទាល់ខ្លួន។ ប្រព័ន្ធទ្រព្យសម្បត្តិរួម គឺជាប្រព័ន្ធដែលទទួលស្គាល់អំពីអត្ថិភាពនៃទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធតាមរយៈអាពាហ៍ពិពាហ៍ក្នុងទំហំមួយដែលបានកំណត់ ហើយនៅពេលដែលអាពាហ៍ពិពាហ៍រលាយនឹងត្រូវយកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមកធ្វើការបែងចែកលើទ្រព្យសម្បត្តិនោះ។ ប្រព័ន្ធដែលយកប្រាក់ចំណូលប្តីប្រពន្ធរកបានមកធ្វើជាទ្រព្យសម្បត្តិរួម ជាទ្រព្យសម្បត្តិដែលទទួលបានក្នុងទំហំនៃអំឡុងពេលអាពាហ៍ពិពាហ៍។ ប្រព័ន្ធនេះអាចសម្រេចនូវការវាយតម្លៃអំពីភាពស្មើគ្នានិងភាពតែមួយនៃផ្នែកសេដ្ឋកិច្ចរបស់ប្តីប្រពន្ធ។

- សិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរួមប្តីប្រពន្ធ

ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរួម។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន។ សហព័ទ្ធ មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព។ សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀត ឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួមបាន។ បើការពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនបានសម្រេច ឬបើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន។[101]

[100] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៧៤។

[101] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៧៥។

ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ បើគ្មានការយល់ព្រមពីប្ដីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធមិនអាចយកទៅលក់ ឬធ្វើការចាត់ចែងផ្សេងទៀតបានឡើយ។ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើក៏ដោយ បើមានស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និងដើម្បីរក្សាជីវភាពរស់នៅ នោះប្ដីប្រពន្ធណាម្ខាង អាចលក់ ឬធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួមបានដោយទទួលការអនុញ្ញាតពីតុលាការ។ ក្នុងករណីដែលប្ដី ឬ ប្រពន្ធណាម្ខាង បានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និង គ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្ដល់ការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និងគ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្ដល់ការយល់ព្រម អាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាន នៅក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុ និងនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេង។[102]

- ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ច

ប្ដីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្ដីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូន ជាអាទិ៍។ កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្ដី ឬ ប្រពន្ធ ទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬកាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀតដែលប្ដី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរពីប្រពន្ធ ឬប្ដីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម។[103]

នៅពេលបុរស និងស្ត្រីបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា គេត្រូវទទួលបានសិទ្ធិនឹងការទទួលខុសត្រូវខ្លះចំពោះគ្នាទៅវិញទៅមកចំពោះកូន និងចំពោះសាច់ញាតិរបស់សហព័ទ្ធ។ សិទ្ធិ និងការទទួលខុសត្រូវទាំងអស់នេះ មានមែកធាងមកពីច្បាប់អន្តរជាតិ ក៏ដូចជាមកពីរដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងបទប្បញ្ញត្តិនានារបស់ប្រទេសកម្ពុជា។ ផ្នែកនេះនឹងធ្វើការពិភាក្សាអំពីសិទ្ធិ និងការទទួលខុសត្រូវជាមូលដ្ឋានខ្លះៗរបស់សហព័ទ្ធដែលឋិតនៅក្រោមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន។

កាលពីអតីតកាលនៅក្នុងប្រទេសជាច្រើន ច្បាប់បានចែងពីសិទ្ធិ និងករណីយកិច្ចផ្សេងៗសម្រាប់ប្ដីនិងប្រពន្ធ។ នៅទូទាំងពិភពលោកសិទ្ធិតាមផ្លូវច្បាប់របស់ប្រពន្ធមានភាពមិនស្មើគ្នានិងសិទ្ធិតាមផ្លូវច្បាប់របស់ប្ដីប្រពន្ធទេ។ នៅក្នុងអតីតកាលកន្លងមកថ្មីៗនេះច្បាប់របស់ប្រទេសកម្ពុជា មិនបានផ្ដល់ឱ្យស្ត្រីមានសិទ្ធិស្មើគ្នាតាមផ្លូវតាមច្បាប់នៅពេលមានចំណងអាពាហ៍ពិពាហ៍ទេ។

[102] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៧៦។

[103] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៧៥។

ឧទាហរណ៍ ក្រមរដ្ឋប្បវេណីសង្គមចាស់របស់ប្រទេសកម្ពុជាបានកំណត់ថាស្ត្រីដែលរៀបអាពាហ៍ពិពាហ៍មានសិទ្ធិរៀបអាពាហ៍ពិពាហ៍បានតែប្តីមួយ ប៉ុន្តែប្តីអាចមានសិទ្ធិយកប្រពន្ធច្រើននាក់ដោយស្របច្បាប់។ ម្យ៉ាងទៀតស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ហើយពុំមានសិទ្ធិចុះកិច្ចសន្យា ឬធ្វើបណ្តឹងដោយពុំមានការអនុញ្ញាតរបស់ប្តីបានឡើយ។ ជាច្រើនទសវត្សន៍កន្លងមកនេះ មានប្រទេសជាច្រើនបានសរសេរច្បាប់របស់ខ្លួនឡើងវិញដោយមានការកែលម្អជាច្រើន ដើម្បីផ្តល់ឱ្យស្ត្រីមានសិទ្ធិអំណាចស្មើនឹងបុរស នៅក្នុងចំណងអាពាហ៍ពិពាហ៍។ កម្ពុជាជាប្រទេសមួយក្នុងចំណោម ប្រទេសនានាដែលបានបញ្ចូលគោលការណ៍ស្តីពីសមភាពរបស់បុរសនារីនៅក្នុងច្បាប់។ ដូច្នេះច្បាប់របស់ប្រទេសកម្ពុជាបច្ចុប្បន្នចែងថា ប្តីប្រពន្ធមានសិទ្ធិស្មើគ្នាក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។

យ៉ាងហោចណាស់នៅក្នុងប្រទេសកម្ពុជាក៏មានច្បាប់ចំនួនបី ដែលចែងពីគោលការណ៍សមភាពរវាងប្តីនិងប្រពន្ធ។ ទី១ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទឆ្នាំ ១៩៧៩ ត្រង់មាត្រា ១៦ ចំណុច ឃ ចែងថា បុរស និងនារីត្រូវមានសិទ្ធិ និងការទទួលខុសត្រូវដូចគ្នា នៅពេលមានចំណងអាពាហ៍ពិពាហ៍ និងនៅពេលរំលាយចំណងអាពាហ៍ពិពាហ៍ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ។ ទី២ រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាចែងថា បុរស និងស្ត្រីមានសិទ្ធិដូចគ្នាក្នុងគ្រប់វិស័យទាំងអស់ជាពិសេសការរៀបអាពាហ៍ពិពាហ៍ និងគ្រួសារ។ ទី៣ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បុរសនិងនារី ដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ។

ការខ្វះខាតខ្វះចន្លោះរវាងច្បាប់ជាលាយលក្ខណ៍អក្សរ និងការអនុវត្តជាក់ស្តែង មានប្រជាជាតិជាច្រើនបានរកឃើញថា ជាការពិបាកណាស់សម្រាប់ឱ្យមនុស្សប្រតិបត្តិស្មើគ្នា ដែលរដ្ឋធម្មនុញ្ញ និងច្បាប់របស់ជាតិបានគោលការណ៍នៃសកម្មភាពនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ជាការសំខាន់ណាស់ដែលត្រូវមានច្បាប់សរសេរជាលាយលក្ខណ៍អក្សរ ហើយត្រូវទទួលស្គាល់សមភាព ជាគោលដៅក្នុងចំណោមគោលដៅសំខាន់ៗនានារបស់សង្គម។ កាលណាច្បាប់ទទួលស្គាល់សមភាពជាគោលដៅមួយហើយ ប្រជាពលរដ្ឋអាចប្រើប្រាស់ដើម្បីជួយឱ្យគោលបំណងនេះក្លាយទៅជាការពិត។

- ការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍

ប្តីប្រពន្ធត្រូវមានចំណែកបន្ទុកសោហ៊ុយ ដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត។[104] មានន័យថាប្តីប្រពន្ធ ត្រូវមានករណីយកិច្ចទទួលខុសត្រូវនូវសោហ៊ុយចំណាយ ដើម្បីថែទាំជីវភាពរួមនៃអាពាហ៍ពិពាហ៍ ដោយតម្រូវឱ្យប្តីប្រពន្ធចែករំលែកនូវការទទួល

[104] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៧១។

ខុសត្រូវសោហ៊ុយជីវភាពរួមទៅតាមទ្រព្យសម្បត្តិ ប្រាក់ចំណូល ឋានៈ ក្នុងសង្គម និងមុខរបររបស់ប្តីប្រពន្ធជាដើម។ ការទទួលខុសត្រូវនូវសោហ៊ុយចំណាយដើម្បីជីវភាពរួមនៃអាពាហ៍ពិពាហ៍ មិនសំដៅទៅលើត្រឹមតែការចំណាយសម្រាប់សម្លៀកបំពាក់ ម្ហូបអាហារ ការស្នាក់នៅ ថ្លៃព្យាបាលប៉ុណ្ណោះទេគឺរាប់បញ្ចូលទាំងការចំណាយលើការសិក្សា និងការថែទាំកូនផង។ មិនត្រឹមតែក្នុងអំឡុងពេលដែលមានអាពាហ៍ពិពាហ៍នោះទេ សូម្បីតែពួកគេរស់នៅបែកគ្នាក៏ដោយ ក៏ប្តីប្រពន្ធត្រូវបន្តនូវករណីយកិច្ចទទួលបន្ទុកចំណែកនេះផងដែរ។ ទោះពីប្តីប្រពន្ធរស់នៅបែកគ្នា ក៏ប្តីប្រពន្ធត្រូវតែមានអាហារកាតព្វកិច្ចរវាងសហព័ទ្ធផងដែរ។ មានន័យថា សហព័ទ្ធម្ខាងអាចទាមទាររួមទាំងសោហ៊ុយសម្រាប់ជីវភាពរស់នៅរបស់កូនដែលរស់នៅជាមួយខ្លួន ពីសហព័ទ្ធម្ខាងទៀតបានដែរ។

ក្នុងករណីដែលសហព័ទ្ធណាមួយ មិនអនុវត្តកាតព្វកិច្ចនៃសោហ៊ុយចំណាយក្នុងពេលអាពាហ៍ពិពាហ៍នោះ សហព័ទ្ធណាម្ខាងទៀតអាចដាក់ពាក្យសុំទៅតុលាការឱ្យសម្រេចអំពីសោហ៊ុយចំណាយនេះបាន ក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង។

### ២.៥.២.៥. សិទ្ធិគ្រប់គ្រង និងចាត់ចែងលើទ្រព្យសម្បត្តិប្តីប្រពន្ធ

នៅក្នុងការចាត់ចែងទ្រព្យសម្បត្តិប្តីប្រពន្ធ ចាំបាច់ត្រូវមានការយល់ព្រមពីរភាគីទាំងសងខាងទើបអាចយកទ្រព្យសម្បត្តិនោះមកធ្វើការបែងចែកបាន បើគ្មានការយល់ព្រមពីភាគីប្តីប្រពន្ធទាំងសងខាងទេទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនអាចយកទៅលក់ និងចាត់ចែងផ្សេងទៀតបានឡើយ។ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ៩៧៦ នៃក្រមរដ្ឋប្បវេណីក៏ដោយបើមានស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងការអាពាហ៍ពិពាហ៍ និងដើម្បីរក្សាជីវភាពរស់នៅប្តីប្រពន្ធណាម្ខាង អាចលក់ ឬធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួមបានដោយទទួលការអនុញ្ញាតពីតុលាការ។ ក្នុងករណីណាមួយដែលប្តី ឬប្រពន្ធណាម្ខាង បានលក់ ឬធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត និងគ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធមិនបានផ្តល់ការយល់ព្រម អាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះទៅតុលាការបាននៅក្នុងអំឡុងពេល ២(ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ ទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុ និងនៅក្នុងអំឡុង ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេង។[105]

### ២.៥.២.៦. ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

ប្តីប្រពន្ធ ត្រូវមានចំណែកលើបន្ទុកសោហ៊ុយដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍ដោយពិចារណាលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត។ ចំពោះបន្ទុកនៃសោហ៊ុយចំណាយដើម្បីថែទាំជីវភាពរួមនៃអាពាហ៍ពិពាហ៍ ដោយតម្រូវឱ្យប្តីប្រពន្ធចែករំលែក សោហ៊ុយទៅតាមទ្រព្យសម្បត្តិ ប្រាក់ចំណូល ឋានៈក្នុងសង្គម និងមុខរបរ ជាដើមរបស់ប្តីប្រពន្ធ។ សោហ៊ុយនៃអាពាហ៍ពិពាហ៍នោះ មិនបានសំដៅលើត្រឹមតែសោហ៊ុយ

[105] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៧៣។

ចាំបាច់ដែលចំណាយលើការស្លៀកពាក់ ម្ហូបអាហារ និងការស្នាក់នៅតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានរាប់បញ្ចូលទាំងសោហ៊ុយផ្សេងទៀតផងដែរ។[106]

មាត្រានេះបានឆ្លុះបញ្ចាំងនូវផ្នែកសេដ្ឋកិច្ចដែលស្តីពីករណីយកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមករបស់ប្តីប្រពន្ធដែលជាការបង្កើតចំណុចសំខាន់នៃអាពាហ៍ពិពាហ៍ផងដែរ។ ខ្លឹមសារលម្អិតនៃសោហ៊ុយអាពាហ៍ពិពាហ៍រួមមាន សោហ៊ុយសម្រាប់ការស្លៀកពាក់ ម្ហូបអាហារ និងការស្នាក់នៅ ថ្លៃសម្រាលកូន ថ្លៃព្យាបាល ថ្លៃសិក្សា ថ្លៃមើលថែទាំកូន និងថ្លៃសម្រាប់ការកម្សាន្តដែលសមរម្យជាអាទិ៍។ ទោះបីជាបុគ្គលនោះបានក្លាយជានីតិជនហើយក៏ដោយ ប៉ុន្តែប្រសិនបើបុគ្គលនោះនៅជានិស្សិត ឬត្រូវការការព្យាបាលនៅមន្ទីរពេទ្យ ឬការថែទាំពីឪពុកម្តាយដោយសារតែភាពទន់ខ្សោយ (ជំងឺ) ហើយមិនអាចរស់នៅដោយឯករាជ្យបាន។

ឧទាហរណ៍ ជាចុងក្រោយ លោក សុខា មិនអាចលក់ផ្ទះនៅផ្សារដើមថ្កូវបាន ហើយលោកស្រីពៅ និងសារ៉ុធរស់នៅលើផ្ទះនោះទៀត។ លោក សុខា កំពុងរស់នៅផ្ទះរបស់លោក រស្មី នៅខណ្ឌជ្រោយចង្វា។ លោក សីហា គិតថាលែងចង់លែងលះជាមួយលោកស្រីពៅ ប៉ុន្តែលោកស្រីពៅបានគិតពីសារ៉ុធ ហើយក៏ស្នាក់ស្ទើរចំពោះការលែងលះនោះ។ ដោយសារតែក្រុមហ៊ុនរបស់លោកស្រីកំពុងក្ស័យធន បច្ចុប្បន្ននាងកំពុងធ្វើការងារនៅភោជនីយដ្ឋាន។ ប្រាក់ខែជារៀងរាល់ខែរបស់លោកស្រីពៅមានចំនួន ២៥០$ ក្នុងមួយខែ លោកស្រីពៅត្រូវការប្រាក់ចំនួន ៣០០$ ក្នុងមួយខែដើម្បីប្រើប្រាស់សម្រាប់ថ្លៃជីវភាពដូចជា ថ្លៃម្ហូបអាហារ ថ្លៃទឹកភ្លើង ហ្គាស និងសម្លៀកបំពាក់។ ជារៀងរាល់នាងត្រូវការប្រាក់ចំនួន ៥០$ សម្រាប់ថ្លៃសាលាកូនរៀន។ ពោលទោះបីជាលោកស្រីពៅមានប្រាក់ខែចំនួន ២៥០$ ក៏ដោយលោកស្រីពៅនៅខ្វះចំនួន ១០០$ ទៀតដើម្បីជីវភាពប្រចាំថ្ងៃ។ បច្ចុប្បន្នលោក សុខា កំពុងធ្វើការងារនៅធនាគារមួយ មានប្រាក់ខែចំនួន ៤០០$ ក្នុងមួយខែ។ តើលោកស្រីពៅអាចទាមទារចំពោះលោក សុខា ឱ្យជួយផ្គត់ផ្គង់ថ្លៃសាលា និងថ្លៃជីវភាពបានដែរឬទេ? តើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍មានអ្វីខ្លះ? មានទីមួយ ថ្លៃម្ហូបអាហារ ថ្លៃទឹកភ្លើង ថ្លៃហ្គាស ថ្លៃសេវាទូរសព្ទ ទីពីរ ថ្លៃសម្លៀកបំពាក់ ទីបី ថ្លៃព្យាបាល ទីបួន ថ្លៃសិក្សាកូន និងផ្សេងៗទៀត។ នៅពេលដែលអ្នកទាំងបី រស់នៅជាមួយលោក សុខា និងស្រីពៅ ទទួលបន្ទុកចំពោះសោហ៊ុយអាពាហ៍ពិពាហ៍។ ក្នុងអំឡុងពេលរស់នៅជាមួយគ្នាចំណែកនៃការទទួលបន្ទុកលើសោហ៊ុយអាពាហ៍ពិពាហ៍នឹងមិនមានបញ្ហាកើតឡើងឡើយ។ ចំណែកនៃការទទួលបន្ទុកម្នាក់ៗទៅលើការផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃមានដូចជា លោក សុខា មានការទទួលបន្ទុកចំនួន ២៥០$ (សម្រាប់ចំណាយលើសម្លៀកបំពាក់ ម្ហូបអាហារ និងផ្សេងៗ)។ ចំណែកលោកស្រីពៅ មានការទទួលបន្ទុកចំនួន ២៥០$ (សម្រាប់សម្លៀកបំពាក់ ម្ហូបអាហារ ថ្លៃហ្គាស ថ្លៃទឹកភ្លើង និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ)។ រីឯសារ៉ុធ មានការទទួលបន្ទុកចំនួន ៧០$ (៥០$ សម្រាប់ថ្លៃសាលារៀន និង២០$ ទៀតសម្រាប់ចំណាយផ្សេងៗ)។ ពោល គឺមានភាពចាំបាច់នៃចំនួនទឹកប្រាក់ សម្រាប់ជីវភាពរបស់មនុស្សម្នាក់ៗ។ បន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍ មានអានុភាពនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ដូច្នេះហើយក្រោយការលែងលះ បញ្ញត្តិនៃ

[106] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៧១។

បន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍មិនត្រូវបានយកមកអនុវត្តឡើយ។ ក្នុងការងារអនុវត្តជាក់ស្តែង បន្ទុកសោហ៊ុយនៃអាពាហ៍ពិពាហ៍ក្លាយជាបញ្ហា គឺក្នុងអំឡុងពេលក្រោយការរស់នៅបែកគ្នា និងមុនពេលការលែងលះ។

ប្រសិនបើករណីបានធ្វើការលែងលះគ្នាតើលោកស្រី ពៅ និងសារុធ អាចទាមទារចំពោះលោកសុខា ឱ្យជួយផ្គត់ផ្គង់ថ្លៃជីវភាពជាអាទិ៍ដោយផ្អែកលើសិទ្ធិបែបណា? លោកស្រីពៅ អាចទាមទារពីលោកសុខា បានចំពោះករណីដើម្បីយកមកផ្គត់ផ្គង់ជីវភាពរបស់សារុធជាអាទិ៍ ដោយផ្អែកលើបញ្ញត្តិស្តីពីសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន តាមបញ្ញត្តិក្រមរដ្ឋប្បវេណី មាត្រា ១០៤០ កថាខណ្ឌទី១ បានចែងថា ឪពុក ឬម្តាយដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។ លោកស្រីពៅ អាចទាមទារចំពោះលោកសុខា ឱ្យផ្គត់ផ្គង់ជីវភាពរបស់ខ្លួន ដោយផ្អែកតាមមាត្រា ៧៦ ច្បាប់ ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ (អាហារកិច្ច)។ ច្បាប់ ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ មាត្រា ៧៦ កថាខណ្ឌទី១ ក្នុងករណីលែងលះគ្នាភាគីដែលគ្មានកំហុសហើយខ្វះខាតអាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន។[107]

### ២.៥.២.៧. ការទទួលខុសត្រូវលើបំណុល និងកាតព្វកិច្ចផ្សេងៗទៀត

ប្តីប្រពន្ធ ត្រូវទទួលខុសត្រូវដោយសាមគ្គី ចំពោះកាតព្វកិច្ចទាំងឡាយ ដូចជាសោហ៊ុយសម្រាប់ការចំណាយជីវភាពប្រចាំថ្ងៃរបស់គ្រួសារ សោហ៊ុយសម្រាប់ការសិក្សាអប់រំរបស់កូន សោហ៊ុយសម្រាប់ការព្យាបាលជំងឺ និងក្នុងករណីពិធីរវល់ណាមួយចាំបាច់ណាមួយ ដូចជា ចូលក្នុងបុណ្យទាន ពិធីមង្គលការជាដើម។ ប្តីប្រពន្ធ ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចទាំងឡាយ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នាតាមរយៈលិខិតលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុល ឬជាមួយកូនបំណុល ឬជាប់បំណុលទាំងឡាយដែលភាគីតែម្ខាងបានធ្វើជាលាយលក្ខណ៍អក្សរ ហើយមានការយល់ព្រមពីភាគីម្ខាងទៀត។ សោហ៊ុយចំណាយសម្រាប់ការថែរក្សាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ។ រាល់ការចំណាយទាំងអស់នៅក្នុងផ្នែកនេះ ជាបន្ទុករបស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។ ក្នុងករណីដែលភាគីម្ខាងបានជាប់បំណុលគេដោយគ្មានការយល់ព្រមពីភាគីម្ខាងទៀត ដើម្បីប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួនរបស់ភាគីតែម្ខាងនោះភាគីដែលបានជំពាក់បំណុលគេនោះត្រូវទទួលខុសត្រូវតែម្នាក់ឯង។ ប៉ុន្តែក្នុងករណីដែលភាគីតែម្ខាងបាន ជំពាក់បំណុលគេហើយមិនមានការដឹងឮពីភាគីម្ខាងទៀត ហើយយកបំណុលនោះមកប្រើប្រាស់ក្នុងជីវភាពគ្រួសាររួមសហព័ទ្ធម្ខាងទៀតដែលមិនបានដឹងនោះក៏ចូលរួមទទួលខុសត្រូវផងដែរ។

ក. បំណុលរួមរបស់ប្តីប្រពន្ធ

តាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិអំពីសិទ្ធិរបស់សហព័ទ្ធ (ប្តីប្រពន្ធ) ទាក់ទងនឹងការប្រើប្រាស់ គ្រប់គ្រងទ្រព្យសម្បត្តិរួម នៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ និងសិទ្ធិបែងចែកទ្រព្យសម្បត្តិរួមនៅពេលលែងលះ។ ទន្ទឹមនឹងនោះ ច្បាប់ក៏បានបញ្ញត្តអំពីបំណុល ឬកាតព្វកិច្ចផ្សេងទៀតរបស់ប្តីប្រពន្ធ ដែល

[107] ច្បាប់ ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ៧៦។

កើតមានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ដោយកំណត់ឱ្យប្តីប្រពន្ធត្រូវទទួលខុសត្រូវរួមគ្នា (កាតព្វកិច្ចសាមគ្គី) ចំពោះបំណុលរួមផងដែរ។ បំណុលរួម គឺជាសោហ៊ុយចំណាយរបស់ប្តីប្រពន្ធ មានដូចខាងក្រោម៖

១៖ សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូនជាអាទិ៍ (មាត្រា ៩៧៥ ចំណុច «ក» នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ ប្តីបានចាកចេញពីផ្ទះទៅរស់នៅជាមួយស្រីកំណាន់ ហើយក៏មិនបានផ្តល់ប្រាក់ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារដែរ ប្រពន្ធត្រូវទទួលខុសត្រូវចំពោះការចំណាយនៅក្នុងគ្រួសារ ជាពិសេសថ្លៃឈ្នួលផ្ទះជារៀងរាល់ខែ។ ដោយសារជីវភាពជួបបញ្ហា ប្រពន្ធបានខ្ចីប្រាក់ពីបងស្រីរបស់ខ្លួនចំនួន ២.០០០ដុល្លារ ប្រាក់នោះត្រូវបានចំណាយសម្រាប់ថ្លៃឈ្នួលផ្ទះក្នុងមួយខែ ចំនួន ៣០០ ដុល្លារ រយៈពេល ៣ ខែ ស្មើនឹងចំនួន ៩០០ ដុល្លារ ហើយបានទិញម៉ូតូមួយគ្រឿងសម្រាប់ជិះទៅធ្វើការ និងជូនកូនទៅសាលារៀន (ម៉ូតូចាស់បានខូច) ក្នុងតម្លៃ ៥០០ ដុល្លារ និងប្រាក់ចំនួន ៦០០ ដុល្លារទៀត សម្រាប់ការចំណាយថ្លៃទឹកភ្លើង អាហារហូបចុកប្រចាំថ្ងៃ។ បំណុលចំនួន ២.០០០ ដុល្លារ ដែលប្រពន្ធជាអ្នកខ្ចីពីបងស្រី ត្រូវបានរាប់បញ្ចូលជាសោហ៊ុយសម្រាប់កិច្ចការគ្រួសារ ដែលច្បាប់កំណត់ថា ជាបំណុលរួម ហើយប្តីប្រពន្ធត្រូវទទួលខុសត្រូវរួមគ្នា ទោះបីជាប្រពន្ធជាអ្នកខ្ចីតែម្នាក់ឯងក៏ដោយ។ ក្នុងករណីនេះ ប្តីមិនអាចបដិសេធថា ខ្លួនមិនដឹងពីរឿងនេះ ខ្លួនមិនមែនជាអ្នកខ្ចី សូមទាមទារពីប្រពន្ធរបស់ខ្លួនដែលជាអ្នកខ្ចីនោះទេ។

២៖ បំណុលដែលប្តីប្រពន្ធទាំងសងខាង បានព្រមព្រៀងតាមលិខិតជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬបំណុលដែលប្តី ឬប្រពន្ធតែម្ខាង បានខ្ចីពីម្ចាស់បំណុលដោយមានការយល់ព្រមតាមលិខិតជាលាយលក្ខណ៍អក្សរពីប្តី ឬប្រពន្ធម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ (មាត្រា ៩៧៥ ចំណុច «ខ» នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ ប្តី និងប្រពន្ធ បានចុះកិច្ចសន្យាទិញផ្ទះ ក្នុងតម្លៃ ១០០.០០០ ដុល្លារ ដោយប្រើប្រាស់លុយរួម (ទ្រព្យរួម) ចំនួន ៨០.០០០ ដុល្លារ និងប្រាក់ចំនួន ២០.០០០ ដុល្លារទៀត ប្តីប្រពន្ធនោះបានចុះកិច្ចសន្យាខ្ចីប្រាក់ (លិខិតលាយលក្ខណ៍អក្សរ) ជាមួយធនាគារ។ ក្នុងករណីនេះ បំណុលដែលប្តីប្រពន្ធជំពាក់ធនាគារចំនួន ២០.០០០ ដុល្លារ គឺជាបំណុលរួម ដែលប្តីប្រពន្ធទាំងសងខាង បានព្រមព្រៀងគ្នាបង្កើត ហេតុនេះប្តីប្រពន្ធត្រូវទទួលខុសត្រូវចំពោះបំណុលរបស់ធនាគារដោយរួមគ្នា។

៣៖ សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម (មាត្រា ៩៧៥ ចំណុច «គ» នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ ផ្ទះដែលជាទ្រព្យរួមរបស់ប្តីប្រពន្ធ ត្រូវបានរងការខូចខាតដោយសារទឹកលិចនៅរដូវវស្សា មានភាពចាំបាច់ត្រូវជួសជុល ហើយប្រពន្ធ (ម្ចាស់ការ) បានឱ្យជាង (អ្នកម៉ៅការ) ជួសជុល ដោយចំណាយប្រាក់អស់ ៧.០០០ ដុល្លារ។ ប៉ុន្តែក្រោយបញ្ចប់ការជួសជុល ម្ចាស់ការបង់ប្រាក់ឱ្យអ្នកម៉ៅការ មិនគ្រប់ចំនួនទេ នៅខ្វះចំនួន ២.០០០ ដុល្លារទៀត។ ក្នុងករណីនេះ កាតព្វកិច្ចចំនួន ២.០០០ ដុល្លារ គឺជាសោហ៊ុយដើម្បីថែរក្សាទ្រព្យសម្បត្តិរួម ហេតុនេះជាបំណុលរួមដែលប្តីប្រពន្ធត្រូវទទួលខុសត្រូវរួមគ្នា។

ចំពោះបំណុល ឬ កាតព្វកិច្ចផ្សេងទៀត ដែលប្ដី ឬប្រពន្ធតែម្ខាង ជាអ្នកបង្កើត ដែលមិនពាក់ព័ន្ធនឹងសោហ៊ុយដើម្បីរក្សាជីវភាពរួមជាអាទិ៍ ឬការគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិរួម មិនមែនជាបំណុលរួមទេ ហើយមិនអាចទាមទារឱ្យប្ដីប្រពន្ធទទួលខុសត្រូវរួមគ្នានោះទេ ពោលគឺត្រូវទទួលខុសត្រូវរៀងៗខ្លួន (អ្នកណា ជាអ្នកបង្កើតកាតព្វកិច្ច/បំណុល អ្នកនោះជាអ្នកទទួលខុសត្រូវ)។

ឧទាហរណ៍៖ ប្ដីកំពុងមានស្នេហាលួចលាក់ជាមួយស្រីកំណាន់របស់ខ្លួន ហើយដោយសារចង់យកចិត្តយកថ្លើមស្រីកំណាន់ ប្ដីបានខ្ចីប្រាក់ពីមិត្តភក្តិរបស់ខ្លួនចំនួន ៣.០០០ ដុល្លារ ដើម្បីទិញចិញ្ចៀនពេជ្រមួយវង់ឱ្យស្រីកំណាន់។ បំណុលចំនួន ៣.០០០ ដុល្លារ ជាបំណុល ដែលកើតពីអំពើសាវារបស់ប្ដី ហើយប្ដីចុះកិច្ចសន្យាតែម្នាក់ឯង ហេតុនេះ បំណុលនោះមិនមែនជាបំណុលរួមទេ នាំឱ្យប្ដីត្រូវទទួលខុសត្រូវតែម្នាក់ឯង។

ខ. ការទទួលខុសត្រូវរួមគ្នាចំពោះបំណុលរួម

ប្ដីប្រពន្ធត្រូវទទួលខុសត្រូវដោយរួមគ្នាចំពោះបំណុលរួម ហៅថា កាតព្វកិច្ចដោយសាមគ្គីភាព (មាត្រា ៩៧៥ និងមាត្រា ៩២១ នៃក្រមរដ្ឋប្បវេណី)។ ការទទួលខុសត្រូវដោយរួមគ្នា ឬសាមគ្គីភាព មានន័យថា ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលណាម្នាក់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគ ឬឱ្យកូនបំណុលទាំងអស់អនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគដោយព្រមគ្នា ឬដោយបន្តបន្ទាប់។

ឧទាហរណ៍៖ ប្ដី និងប្រពន្ធ បានខ្ចីលុយពីធនាគារចំនួន ១០០.០០០ ដុល្លារ ដើម្បីទិញផ្ទះ ផ្អែកតាមច្បាប់ បំណុលចំនួន ១០០.០០០ ដុល្លារ ជាបំណុលរួម។ ក្នុងករណីនេះ ម្ចាស់បំណុល ក អាចទាមទារប្រាក់ ១០០.០០០ ដុល្លារ ពីប្ដីតែម្នាក់ ឬពីប្រពន្ធតែម្នាក់ ឬ ខ ទាមទារប្រាក់ ១០០.០០០ ដុល្លារ ពីប្ដី និងប្រពន្ធ ឬ គ ទាមទារប្រាក់ ១០០.០០០ ដុល្លារ ពីប្រពន្ធចំនួន ៥០.០០០ ដុល្លារ និងពីប្ដីចំនួន ៥០.០០០ ដុល្លារ។

ប្រសិនបើ ម្ចាស់បំណុលជ្រើសរើសប្ដឹងទាមទារបំណុលចំនួន ១០០.០០០ ដុល្លារពីប្ដីតែម្នាក់ ក្នុងករណីនេះ ប្ដីត្រូវទទួលខុសត្រូវ ដោយមិនអាចបដិសេធថា «ខ្ញុំទទួលខុសត្រូវតែ ៥០.០០០ ដុល្លារតែប៉ុណ្ណោះ ចំណែកឯ ៥០.០០០ ដុល្លារទៀត សូមទាមទារពីប្រពន្ធរបស់ខ្ញុំ» បានឡើយ ពីព្រោះប្ដីប្រពន្ធមានករណីយកិច្ចដោយសាមគ្គីភាពចំពោះបំណុលចំនួន ១០០.០០០ ដុល្លារ ហេតុនេះ ប្ដីប្រពន្ធត្រូវទទួលខុសត្រូវដោយរួមគ្នា ដោយមិនអាចបែងចែកបន្ទុកនៃការទទួលខុសត្រូវបានទេ។ ម្យ៉ាងវិញទៀត នៅពេលដែលប្ដីបានសងប្រាក់ ១០០.០០០ ដុល្លារទៅម្ចាស់បំណុល នាំឱ្យកាតព្វកិច្ចរបស់ប្រពន្ធក៏ត្រូវរលត់ដែរចំពោះបំណុល ១០០.០០០ ដុល្លារ៕

# ជំពូកទី៣
# ការបញ្ចប់អាពាហ៍ពិពាហ៍

# ជំពូកទី៣
# ការបញ្ចប់អាពាហ៍ពិពាហ៍

ការបញ្ចប់អាពាហ៍ពិពាហ៍ ជាការរំលាយចំណងទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងសហព័ទ្ធនឹងគ្នា ការកាត់ផ្ដាច់ចំណងនៃទំនាក់ទំនងជាប្ដីប្រពន្ធដែលខ្លួនធ្លាប់ជាសហព័ទ្ធ។ ក្នុងការកំណត់ជាល័ក្ខខ័ណ្ឌមួយដែលអាចបញ្ចប់តាមផ្លូវច្បាប់ដោយមានវិធី ៥ យ៉ាង រួមមាន មោឃភាពអាពាហ៍ពិពាហ៍ ការលុបចោលអាពាហ៍ពិពាហ៍ ការអវត្តមាន និងការប្រកាសអំពីការបាត់ខ្លួន មរណភាពរបស់សហព័ទ្ធណាមួយ និងការលែងលះ។ ក្នុងនោះយើងខ្ញុំបានបញ្ជាក់យ៉ាងលម្អិតអំពីការបញ្ចប់អាពាហ៍ពិពាហ៍តាមកថាខណ្ឌនីមួយៗដូចខាងក្រោម។ អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបានលុះត្រាតែគោរពតាមលក្ខខណ្ឌដែលមានការព្រមព្រៀងរបស់គូភាគី និងលក្ខខណ្ឌដែលច្បាប់បានកំណត់ទុកជាមុនសិន ប្រសិនបើមានការប្រព្រឹត្តផ្ទុយផ្លូវច្បាប់នោះ ច្បាប់មិនទទួលស្គាល់ និងមិនមានអានុភាពតាមច្បាប់ជាធរមានឡើយ។

នៅក្នុងល័ក្ខខ័ណ្ឌបើទោះបីជាមនុស្សពីរនាក់បានរៀបអាពាហ៍ពិពាហ៍នឹងគ្នា និងបានធ្វើការចុះបញ្ជីអាពាហ៍ពិពាហ៍រួចនៅសាលាឃុំ សង្កាត់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានក៏ដោយ ប្រសិនបើអាពាហ៍ពិពាហ៍នោះមិនបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា នឹងនាំឱ្យអាពាហ៍ពិពាហ៍ នោះមានការបញ្ចប់តាមនីតិវិធីច្បាប់ផងដែរ។ ដូច្នេះយើងគួរគប្បីស្វែងយល់ជាមុននឹងធ្វើការសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍អំពីលក្ខខណ្ឌបង្កើត និងលក្ខខណ្ឌបញ្ចប់អាពាហ៍ពិពាហ៍ ជាមុនសិនទើបអាពាហ៍ពិពាហ៍នោះមានអានុភាពតាមច្បាប់កំណត់។ ក្នុងករណីដែលអាពាហ៍ពិពាហ៍ត្រូវបានរំលាយករណីយកិច្ចរួមរស់នៅជាមួយគ្នាសហការគ្នា និងមានករណីយកិច្ចសង្គ្រោះគ្នាទៅវិញទៅមកត្រូវបានរលត់ បើទោះបីជាសហព័ទ្ធណាម្ខាងដែលបានលែងលះអះអាងថា ជីវភាពរស់នៅមានការលំបាកក៏ដោយក៏បុគ្គលម្ខាងទៀត ដែលជាអតីតសហព័ទ្ធមិនមានករណីយកិច្ចសង្គ្រោះដែរ។ ម្យ៉ាងវិញទៀតករណីយកិច្ចស្មោះត្រង់ ក៏ត្រូវរលត់ទៅតាមនោះដោយឯកឯងដោយគេអាចរៀបអាពាហ៍ពិពាហ៍ជាថ្មីម្តងទៀតបាន។

## ៣.១. មោឃភាពនៃអាពាហ៍ពិពាហ៍

មោឃភាពនៃអាពាហ៍ពិពាហ៍ គឺជាការផ្ដាច់ចំណងអាពាហ៍ពិពាហ៍ ដែលមិនស្របច្បាប់ដែលត្រូវបានបង្កើតដោយភាគីនៃចំណងអាពាហ៍ពិពាហ៍។[108] មោឃភាព មានន័យថា ភាពពុំមានអានុភាពតាមផ្លូវច្បាប់នៃសកម្មភាពគតិយុត្ត។ ឬម្យ៉ាងទៀត ជាទណ្ឌកម្មដែលប្រកាសដោយចៅក្រមលុបបំបាត់ជាប្រតិសកម្មនូវលិខិតគតិយុត្តដែលមិនបានបំពេញលក្ខខណ្ឌដែលច្បាប់កំណត់ ឬសកម្មភាពណាមួយដែលផ្ទុយពីនីតិវិធីច្បាប់។[109] មោឃភាពនៃអាពាហ៍ពិពាហ៍នេះ គឺជាការប្តឹងដែលធ្វើឡើងដោយភាគីណាមួយ ឬញាតិសន្តានរបស់ភាគី ឬតំណាងអយ្យការដែលយល់ឃើញថា អាពាហ៍ពិពាហ៍នោះមានលក្ខណៈប៉ះពាល់ដល់ច្បាប់ហាមឃាត់ហើយ

[108] សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ រៀបរៀងដោយសាស្ត្រាចារ្យមេធាវី ហេង បូរ៉ា ទំព័រទី៣៥។

[109] វចនានុក្រម សម្ដេចសង្ឃរាជ ជួន ណាត រៀបចំដោយរាជបណ្ឌិតសភាកម្ពុជា ២០២២។

បានធ្វើបណ្តឹងទៅតុលាការដើម្បីសុំមោឃអាពាហ៍ពិពាហ៍នោះចោល។ បណ្តឹងមោឃភាពនោះមានតែតុលាការទេ ទើបមានឆន្ទានុសិទ្ធិសម្រេចលើបណ្តឹងនេះ។ អត្ថបទគតិយុត្តនេះ ក៏បានសម្រួល និងបន្ធូរបន្ថយផងដែរ ប្រសិនបើគ្រាន់តែមានវិការៈតែបន្តិចបន្តួចលើនីតិវិធី នោះអានុភាពនៃអាពាហ៍ពិពាហ៍ អាចសម្រេចទៅបានដោយមិនមានទណ្ឌកម្មព្រហ្មទណ្ឌឡើយ។

### ៣.១.១. មូលហេតុនៃមោឃភាពអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍មានអានុភាពលុះត្រាតែត្រូវបានទទួលស្គាល់ដោយច្បាប់។ ចំពោះអាពាហ៍ពិពាហ៍ដែលកើតឡើងដោយសារការភាន់ច្រឡំលើមនុស្ស និងដោយការបង្ខំ អាពាហ៍ពិពាហ៍នោះត្រូវចាត់ទុកជាមោឃៈ។[110] អាពាហ៍ពិពាហ៍ដែលស្របច្បាប់ពុំអាចមោឃភាពបានទេ វៀរលែងតែអាពាហ៍ពិពាហ៍នោះសាមីខ្លួនបានប្រព្រឹត្តខុស នាំឱ្យអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកជាមោឃភាពដោយសារតែមានមូលហេតុដូចក្នុងករណីខាងក្រោមៈ

#### ៣.១.១.១. ការភាន់ច្រឡំលើមនុស្ស

ការរៀបអាពាហ៍ពិពាហ៍ដោយសារការគ្មានឆន្ទៈ រវាងភាគីដោយសារភាន់ច្រឡំលើមនុស្ស ដែលនាំឱ្យអាពាហ៍ពិពាហ៍នឹងត្រូវជាមោឃភាពបាន។ ការភាន់ច្រឡំអាចជាការច្រឡំចំពោះបុគ្គលដែលមានឋានៈតួនាទី ឬចំពោះបុគ្គលដែលមានមុខមាត់ស្រដៀងគ្នា។ ក្នុងករណីនេះភាគីដែលមានបំណងនឹងរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលណាម្នាក់ ដោយសារការភាន់ច្រឡំទៅលើមនុស្សដែលខ្លួនត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយនោះ តែបែរជាខ្លួនត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយដូចជា កូនភ្លោះដែលមានមុខមាត់ដូចគ្នា ឬភាន់ច្រឡំលើមនុស្សដែលមានឈ្មោះដូចគ្នាជាដើម។ ការភាន់ច្រឡំលើមនុស្សដែលជាកម្មវត្ថុសំខាន់នៃអាពាហ៍ពិពាហ៍បែបនេះ ភាគីអាចស្នើសុំមោឃភាពកិច្ចសន្យាអាពាហ៍ពិពាហ៍នោះបាន។

ប៉ុន្តែក្នុងករណីការភាន់ច្រឡំលើមនុស្សដែលតែជាការកាន់ច្រឡំលើអត្តចរិក ឬអាកប្បកិរិយាមនុស្សនោះ ដោយគិតថាមនុស្សនោះចិត្តល្អ តែក្រោយមកពេលរៀបអាពាហ៍ពិពាហ៍រួចហើយបែរជាចិត្តមិនល្អវិញ ភាគីដែលភាន់ច្រឡំបែបនេះមិនអាចសុំមោឃភាពនៃអាពាហ៍ពិពាហ៍បានទេ។

#### ៣.១.១.២. ការបង្ខិតបង្ខំ

ប្រសិនបើភាគីម្ខាងទៀតបានបង្ខិតបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយភាគីម្ខាងទៀតដោយឪពុកម្តាយ ឬអាណាព្យាបាល ឬតតិយជន ភាគីនោះអាចដាក់ពាក្យសុំមោឃភាពអាពាហ៍ពិពាហ៍នោះបាន។ អាពាហ៍ពិពាហ៍មួយដែលអាចយកជាបានការលុះត្រាតែអាពាហ៍ពិពាហ៍នោះកើតឡើងដោយ ភាគីទាំងពីរមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍និងគ្រួសារ។[111] ភាគី ដែលគ្មានសេរីភាពក្នុងការជ្រើសរើសគូស្រករត្រូវបានចាត់ទុកថា បានប្រព្រឹត្តផ្ទុយពីបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ភាគីណាម្ខាងអាចស្នើសុំមោឃភាពនៃអាពាហ៍ពិពាហ៍នោះបាន។

[110] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥៨ ចំណុច ក។

[111] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មាត្រា ៤៥ ចំណុច ៣។

#### ៣.១.១.៣. ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

ប្រសិនបើភាគីដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ដោយមិនបានដាក់ពាក្យសុំច្បាប់ដើម្បីរៀបអាពាហ៍ពិពាហ៍ទៅឃុំ សង្កាត់នៃលំនៅឋានខាងនារីនោះទេ គេអាចប្ដឹងសុំមោឃភាពអាពាហ៍ពិពាហ៍នោះចោលបាន។ ប៉ុន្តែទោះបីជាយ៉ាងណា ច្បាប់មិនបានកំណត់ច្បាស់ថា អ្នកណាមានសិទ្ធិប្ដឹងសុំមោឃអាពាហ៍ពិពាហ៍ដែលមិនបានដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍នោះទេ។

#### ៣.១.១.៤. ភាគីមិនបានជូនដំណឹងជាសាធារណៈ

ប្រសិនបើគូស្រករទាំងពីរបានទទួលការអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ដោយមន្ត្រីអត្រានុកូលដ្ឋានហើយ ប៉ុន្តែគូភាគីទាំងពីរមិនបានបិទបណ្ណប្រកាសអាពាហ៍ពិពាហ៍តាមការកំណត់របស់មន្ត្រីអត្រានុកូលដ្ឋាននោះ គេអាចប្ដឹងសុំមោឃភាពអាពាហ៍ពិពាហ៍នោះបាន។

#### ៣.១.១.៥. ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍

ភាគីដែលរៀបអាពាហ៍ពិពាហ៍ នឹងត្រូវចាត់ទុកជាការត្រឹមត្រូវតាមលក្ខខណ្ឌច្បាប់បាន លុះត្រាតែបុរស និងនារី បានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅឋានរបស់នារី។ ដោយមានការព្រមព្រៀងគ្នា ដោយការបង្ខិតបង្ខំពីឪពុកម្ដាយ អាណាព្យាបាល មេឃុំ ចៅសង្កាត់ ឬស្មៀនឃុំជាអាទិ៍។

#### ៣.១.១.៦. ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍

ក្នុងករណីដែលគូភាគីទាំងពីរនាក់បានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍រួចហើយ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅឋាននារី ប៉ុន្តែពួកគេមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ដែលនឹងត្រូវចុះនៅក្នុងសៀវភៅអាពាហ៍ពិពាហ៍របស់មន្ត្រីអត្រានុកូលដ្ឋាន គេអាចស្នើសុំប្ដឹងមោឃភាពអាពាហ៍ពិពាហ៍នោះបាន។ ការចុះបញ្ជីអាពាហ៍ពិពាហ៍នោះត្រូវមានសាក្សីពីរនាក់ជានីតិជន២នាក់ផងដែរ។ ប៉ុន្តែបើ ភាគីទាំងពីរមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងឃុំ សង្កាត់ខាងលំនៅឋានខាងនារីត្រឹមត្រូវនោះទេ គេអាចស្នើសុំមោឃភាពអាពាហ៍ពិពាហ៍នោះបានទេ។

### ៣.១.២. អ្នកមានសិទ្ធិប្ដឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍

អ្នកដែលច្បាប់បានទទួលស្គាល់អំពីសិទ្ធិដែលអាចដាក់ពាក្យប្ដឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទៅតុលាការបាន រួមមាន៖

- សហព័ទ្ធ
- ព្រះរាជអាជ្ញា និង
- ជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងរឿងក្ដីនោះ
- សិទ្ធិវន្តអាចប្ដឹងជំនួសបាន ក្នុងករណីដែលជនដាក់ពាក្យបណ្ដឹងនោះបានមរណភាព។

ស្ថាប័នតុលាការ ជាអ្នកមានសិទ្ធិអំណាចក្នុងការសម្រេចអំពីមោឃភាពនៃអាពាហ៍ពិពាហ៍ ជាអ្នកសម្រេចបែងចែកកូន និងបែងចែកទ្រព្យសម្បត្តិ។

#### ៣.១.៣. អានុភាពនៃមោឃភាព

ប្រសិនបើអាពាហ៍ពិពាហ៍មោឃភាព អាពាហ៍ពិពាហ៍នោះមិនមានអានុភាពទាល់តែសោះ ចាប់តាំងពីពេលបង្កើតមក។ ដូច្នេះបណ្តឹងនៅតុលាការ គឺគ្រាន់តែជាបណ្តឹងទាមទារឱ្យបញ្ជាក់ពីមោឃភាពអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ មិនមែនជាបណ្តឹងទាមទារមោឃភាព ឡើយ។ មួយវិញទៀតបណ្តឹងទាមទារឱ្យបញ្ជាក់ពីមោឃភាពនៃអាពាហ៍ពិពាហ៍ ត្រូវតែធ្វើឡើងដោយអនុលោមតាមនីតិវិធីដែលមានចែងក្នុង ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដោយសារតុលាការសម្រេចចេញជា **សាលក្រម**។ យ៉ាងណាមិញសម្រាប់បណ្តឹងប្រភេទនេះ ក្រមរដ្ឋប្បវេណីមិនបានកម្រិតពីបុគ្គលដែលអាចប្តឹងបាន និងអំឡុងពេលអាជ្ញាយុកាល (រយៈពេលមួយដែលកំណត់ដោយច្បាប់) ឡើយ។ ហេតុដូច្នេះ អាចមានការបកស្រាយថា គ្រប់ជនដែលមានប្រយោជន៍សុទ្ធតែអាចប្តឹងបានទាំងអស់ ដោយពុំមានកម្រិតអំឡុងពេលអាជ្ញាយុកាលឡើយ។[112]

### ៣.២. ការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ គឺជាមធ្យោបាយមួយនាំឱ្យចំណងអាពាហ៍ពិពាហ៍ដែលមិនបំពេញលក្ខខណ្ឌច្បាប់មួយ។ ការលុបចោលអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងលើគ្រប់អាពាហ៍ពិពាហ៍ដែលផ្ទុយនឹងបទប្បញ្ញត្តិដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ អ្នកដែលមានសិទ្ធិប្តឹងសុំលុបចោលអាពាហ៍ពិពាហ៍មានដូចជា ភាគីនីមួយៗ ញាតិសន្តានរបស់ភាគីនីមួយៗ ឬតំណាងអយ្យការ។ ប៉ុន្តែនៅក្រោយពេលដែលភាគីណាម្ខាងបានទទួលមរណភាពហើយតំណាងអយ្យការពុំអាចទាមទារលុបចោលអាពាហ៍ពិពាហ៍នោះបានឡើយ។[113]

#### ៣.២.១. មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍

មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ ត្រូវធ្វើ ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ៩៦០ (ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ ជាអាទិ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬ ការគំរាម) ខាងក្រោមនេះ។[114] ការលុបចោលអាពាហ៍ពិពាហ៍នោះរួមមាន ៣.២.១.១. ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ ៣.២.១.២. ការលុបចោលអាពាហ៍ពិពាហ៍ដែលភាគីមិនទាន់គ្រប់អាយុ ៣.២.១.៣. ការលុបចោលអាពាហ៍ពិពាហ៍ធ្វើនៅក្នុងអំឡុងពេលហាមឃាត់អាពាហ៍ពិពាហ៍ថ្មី ៣.២.១.៤. ការលុបចោលអាពាហ៍ពិពាហ៍ដោយសារការឆបោក ឬការគំរាមកំហែងជាដើម។

##### ៣.២.១.១. ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់

១- អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិចាប់ពីមាត្រា ៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា ៩៥២ (ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ) នៃក្រមនេះ ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ ឬតំណាងអយ្យការ អាចទាមទារទៅតុលាការឱ្យលុបចោលបាន។

---

112 នុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅនីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ ឆ្នាំ២០២២ ទំព័រទី៣៣៤។

113 ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥៩។

114 ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦០។

ប៉ុន្តែនៅក្រោយពេលដែលភាគីណាម្ខាងបានទទួលមរណភាពហើយ តំណាងអយ្យការពុំអាចទាមទារឱ្យលុប ចោលអាពាហ៍ពិពាហ៍នោះបានឡើយ។

២- ចំពោះអាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៤៩ (ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព) ឬមាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ សហព័ទ្ធរបស់ភាគី ឬសហព័ទ្ធមុននោះ ក៏អាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ។[115]

### ៣.២.១.២. ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនគ្រប់អាយុ

បុរស និង នារីដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជន ដែលមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បានដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់អនីតិជននោះ។[116] មានន័យថា ការរៀបអាពាហ៍ពិពាហ៍រវាងបុរសក្រោម ១៨ ឆ្នាំ និងនារីក្រោម ១៦ ឆ្នាំអាចលុបចោលបាន ដោយសារមានភាពផ្ទុយនឹងផលប្រយោជន៍សាធារណៈ ពួកគេអាចសុំប្តឹងលុបចោលអាពាហ៍ពិពាហ៍នោះបាន។ ប៉ុន្តែករណីដែលជនមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍បានដល់នីតិភាពដោយសារការរៀបអាពាហ៍ពិពាហ៍ សិទ្ធិទាមទារលុបចោលនោះត្រូវរលត់។ ទោះបីជាជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានរៀបអាពាហ៍ពិពាហ៍រួចហើយក៏ដោយជននោះក៏នៅតែមានសិទ្ធិទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ នៅក្នុងអំឡុងពេលសុពលភាព ៣ខែ ចាប់ពីពេលជននោះបានគ្រប់អាយុ លើកលែងតែក្នុងអំឡុងពេលជននោះបានធ្វើសច្ចានុម័ត (ការសុខចិត្តយល់ព្រមទទួលស្គាល់ដែលមានអានុភាពប្រតិសកម្ម) លើអាពាហ៍ពិពាហ៍នោះ។

### ៣.២.១.៣. ការលុបចោលក្នុងអំឡុងពេលហាមឃាត់អាពាហ៍ពិពាហ៍ថ្មី

បុគ្គលដែលមានប្តី ឬប្រពន្ធរួចហើយ ចំណងអាពាហ៍ពិពាហ៍មុនមិនទាន់បានរលាយ នៅមានសុពលភាពអនុវត្តនៅឡើយ (មិនទាន់បានលែងលះគ្នាដាច់) ហើយបានរៀបអាពាហ៍ពិពាហ៍ថ្មីជាមួយប្តី ឬប្រពន្ធថ្មីមួយទៀត គេអាចស្នើសុំលុបចោលអាពាហ៍ពិពាហ៍ថ្មីបាន។ អ្នកដែលមានសិទ្ធិទាមទារឱ្យលុបចោលមានដូចជាភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ តំណាងអយ្យការអាចទាមទារទៅតុលាការឱ្យលុបចោលបាន។

ប្រសិនមានសហព័ទ្ធណាមួយ បានរៀបអាពាហ៍ពិពាហ៍រួចទៅហើយ ហើយអាពាហ៍ពិពាហ៍នោះមិនទាន់បានរំលាយជាផ្លូវការអាពាហ៍ពិពាហ៍ក្រោយ អាចទុកជាមោឃភាព។ ប៉ុន្តែអាពាហ៍ពិពាហ៍ក្រោយអាចទៅជាពេញលក្ខណៈច្បាប់បាន បើអាពាហ៍ពិពាហ៍មុនត្រូវរំលាយមុន។ សហព័ទ្ធរបស់ភាគី ឬសហព័ទ្ធមុននោះ ក៏អាចប្តឹងទាមទារទៅតុលាការសុំលុបចោលអាពាហ៍ពិពាហ៍។[117] អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិក្រមរដ្ឋប្បវេណី មាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) ពុំអាចទាមទារឱ្យលុបចោល

[115] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦០។

[116] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៤៨។

[117] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦០ ចំណុចទី២។

បានឡើយ ប្រសិនបើរយៈពេល ១២០ (មួយរយម្ភៃ) ថ្ងៃ បានកន្លងផុតគិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ឬ ប្រសិនបើនារីមានផ្ទៃពោះ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត។[118]

### ៣.២.១.៤. ការលុបចោលអាពាហ៍ពិពាហ៍ដោយសារការឆបោក ឬការគំរាមកំហែង

១- បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ ដោយសារការឆបោក ឬការគំរាម អាចទាមទារទៅតុលាការ ឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន។

២- សិទ្ធិលុបចោលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវរលត់បើភាគីបានរកឃើញការឆបោក ឬ បើអំឡុងពេល ៣ (បី) ខែ បានកន្លងផុតក្រោយពីបានរួចខ្លួនផុតពីការគំរាម ឬ បើបានធ្វើសច្ចានុមតិ។[119]

ក. ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆោក

បុរស និងស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា ដោយសារការឆបោករបស់ភាគីម្ខាងទៀត ឬតតិយជន ដោយគ្រប់មធ្យោបាយធ្វើឱ្យភាគីម្ខាងទៀតធ្លាក់ទៅក្នុងការភាន់ច្រឡំ ភាគីដែលបានបង្ហាញឆន្ទៈដោយការឆបោកនោះ អាចស្នើសុំទៅតុលាការដើម្បីលុបចោលអាពាហ៍ពិពាហ៍នោះបាន។ សិទ្ធិនៃការស្នើសុំលុបចោលអាពាហ៍ពិពាហ៍នោះ មានរយៈពេល ៣ខែ ចាប់តាំងក្រោយថ្ងៃដែលភាគីបានរកឃើញការឆបោកនោះ។ បើផុតរយៈពេល ៣ខែនោះ ភាគីមិនបានស្នើទៅតុលាការ ត្រូវចាត់ទុកថា បានធ្វើសច្ចានុមតិ។

ខ. ការលុបចោលអាពាហ៍ពិពាហ៍ដោយការគំរាមកំហែង

បុរស និងស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាដោយការ គំរាមរបស់ភាគីម្ខាងទៀត ឬរបស់តតិយជនតាមគ្រប់មធ្យោបាយធ្វើឱ្យភាគីម្ខាងទៀតមានការភិតភ័យ បានសុខចិត្តទទួលយកការរៀបអាពាហ៍ពិពាហ៍ដោយខុសពីឆន្ទៈរបស់ខ្លួន ភាគីដែលបានបង្ហាញឆន្ទៈដោយការគំរាមកំហែងនោះ អាចស្នើសុំទៅតុលាការ ដើម្បីលុបចោលអាពាហ៍ពិពាហ៍បាន។

សិទ្ធិស្នើសុំលុបចោលអាពាហ៍ពិពាហ៍នោះ មានរយៈពេល៣ ខែ ចាប់តាំងក្រោយថ្ងៃដែលភាគីបានគេចចេញពីការគំរាមនោះ។

### ៣.២.២. ការរំលត់សិទ្ធិលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ ខុសប្លែកពីមោឃភាពអាពាហ៍ពិពាហ៍ ម្យ៉ាងទៀតសម្រាប់ការលុបចោលក្រមរដ្ឋប្បវេណីបានកំណត់នូវករណីដែលនាំឱ្យសិទ្ធិក្នុងការប្ដឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ត្រូវរលត់តាមបញ្ញត្តិ (មាត្រា ៩៦១ ដល់មាត្រា ៩៦៣ នៃក្រមរដ្ឋប្បវេណី)៖

- ប្រសិនបើជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយនោះ អាពាហ៍ពិពាហ៍នោះមិនត្រូវបានលុបចោលបានទេ ប៉ុន្តែមិនទាន់បានគ្រប់អាយុការអាចទាមទារ

[118] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦២។

[119] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦៣។

ឱ្យលុបចោលអាពាហ៍ពិពាហ៍ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលជននោះបានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍។ ផ្ទុយទៅវិញជននោះ មិនអាចលុបចោលអាពាហ៍ពិពាហ៍បានទេ ប្រសិនបើធ្វើសច្ចានុមតិ (សច្ចានុមតិ គឺជាសកម្មភាពដែលបុគ្គលមានសិទ្ធិលុបចោល បានបង្ហាញជាស្ថាពរថាខ្លួនបានមិនលុបចោលសិទ្ធិលុបចោលនោះទេ)។

- ប្រសិនបើ អាពាហ៍ពិពាហ៍បានធ្វើឡើងដោយមិនបានគោរពតាមអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ ក៏ប៉ុន្តែរយៈពេល ១២០ (មួយរយម្ភៃ) ថ្ងៃ បានកន្លងផុត ដោយគិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល ឬប្រសិននារីមានផ្ទៃពោះ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ថ្មី សិទ្ធិទាមទារលុបចោលអាពាហ៍ពិពាហ៍នេះ នឹងត្រូវរលត់ (មាត្រា ៩៦២ នៃក្រមរដ្ឋប្បវេណី)។
- ប្រសិនបើ អាពាហ៍ពិពាហ៍បានធ្វើឡើងដោយការឆបោក ឬការគំរាម សិទ្ធិទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍ត្រូវរលត់ ប្រសិនបើកំឡុងពេល ៣ (បី) ខែ បានកន្លងផុត ដោយគិតពីពេលបានរួចខ្លួនពីការគំរាម ឬគិតពីពេលបានរកឃើញការឆបោក (មាត្រា ៩៦៣ កថាខណ្ឌទី២)។

### ៣.២.៣. អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍ ត្រូវបានកំណត់ក្នុងបញ្ញត្តិក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦៤ ដូចខាងក្រោម៖

១- ការលុបចោលអាពាហ៍ពិពាហ៍ ពុំមានអានុភាពទៅលើអតីតកាលឡើយ។

២- ភាគីដែលមិនបានដឹងអំពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ ប្រសិនបើបានទទួលទ្រព្យសម្បត្តិ ដោយការរៀបអាពាហ៍ពិពាហ៍ ត្រូវសងទ្រព្យសម្បត្តិនោះ ត្រឹមកម្រិតនៃផលប្រយោជន៍ដែលបានទទួល។

៣- ភាគីដែលបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍ត្រូវសងផលប្រយោជន៍ទាំងអស់ដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍នោះ។ ប្រសិនបើភាគីម្ខាងទៀតសុចរិតវិញ ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនោះ។

៤- បញ្ញត្តិនៃមាត្រា ៩៨៨ (ការសន្មតបិតុភាព) នៃក្រមនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះកូនដែលមានកំណើតរវាងភាគីនៃអាពាហ៍ពិពាហ៍ដែលអាចលុបចោលបាន។

៥- បញ្ញត្តិនៃមាត្រា ៩៨០ (ការបែងចែកទ្រព្យសម្បត្តិ) នៃក្រមនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីនៃការរំលាយអាពាហាហ៍ពិពាហ៍ដែលអាចលុបចោលបាន។[120]

ការលុបចោលអាពាហ៍ពិពាហ៍ មានអានុភាពគតិយុត្ត ប៉ុន្តែពុំមានអានុភាពប្រតិសកម្មទៅលើអតីតកាលឡើយ គ្រាន់តែមានអានុភាពទៅលើអនាគតកាលប៉ុណ្ណោះ មានន័យថា គេមិនអាចធ្វើអ្វីឱ្យមានលក្ខណៈដូច

[120] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៦៤។

កាលពីមិនទាន់រៀបអាពាហ៍ពិពាហ៍ឡើយ។ ក្រោយពេលអាពាហ៍ពិពាហ៍ត្រូវបានលុបចោល មានអានុភាពដល់ការកំណត់បិតុភាពរបស់ទារកផងដែរ។

តាមបញ្ញត្តិក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៨៨ ការសន្និតបិតុភាព ដូចខាងក្រោម៖

១- ទារក នៅក្នុងគភ៌ប្រពន្ធដែលមានក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្និតថាជាកូនរបស់ប្តី។

២- កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ ត្រូវបានបង្កើត ឬក្នុងអំឡុងពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្និតថាមានគភ៌នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ។

៣- ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ បានបង្កើតកូន ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ និងទី២ ខាងលើនេះទេ ត្រូវសន្និតថា កូននោះជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ។[121] មានន័យថា ទារកនៅក្នុងគភ៌របស់ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ត្រូវសន្និតថា ជាកូនរបស់ប្តីនោះ។ ក្រោយពេលអាពាហ៍ពិពាហ៍ត្រូវបានលុបចោល ប្រសិនបើក្នុងករណីកូនដែលបានកើតនៅក្នុងអំឡុងពេលក្រោយ ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីថ្ងៃអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬក្នុងអំឡុងពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ ច្បាប់បានសន្និតថា ស្ត្រីនោះមានគភ៌ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍មុន។ ក្នុងករណីដែលកូនមិនអាចកំណត់ឪពុកបានតាមខាងលើទេ កូននោះត្រូវសន្និតថា ជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ។ នៅក្រោយពេលអាពាហ៍ពិពាហ៍ការលុបចោល ទ្រព្យសម្បត្តិរបស់ភាគីទាំងពីរត្រូវយកមកធ្វើការបែងចែកគ្នាផងដែរ។ ប្រសិនបើភាគីទាំងពីរមិនអាចធ្វើការបែងចែកទ្រព្យសម្បត្តិគ្នាបាននោះ តុលាការអាចមានសិទ្ធិបែងចែកទ្រព្យសម្បត្តិជំនួសបាន។

### ៣.៣. ការអវត្តមាន និងការប្រកាសអំពីការបាត់ខ្លួន

អវត្តមាន សំដៅដល់បុគ្គលណាម្នាក់ដែលបានចេញពីលំនៅឋាន ឬទីសំណាក់ហើយដែលគ្មានលទ្ធភាពនឹងត្រឡប់មកវិញដោយងាយស្រួលនោះ។ ការប្រកាសអំពីការបាត់ខ្លួន គឺជាស្ថានភាពដែលចាត់ទុកថាបុគ្គលនោះបានទទួលមរណភាពទៅលើទំនាក់ទំនងគតិយុត្តជុំវិញលំនៅដ្ឋានដើម តាមរយៈនីតិវិធីដែលបានកំណត់ក្នុងករណីដែលពុំមានដំណឹងច្បាស់លាស់ថាបុគ្គលនោះថានៅរស់ ឬស្លាប់ក្នុងអំឡុងពេលកំណត់។ ក្នុងករណីដែលពុំមានដំណឹងរយៈពេលយូរថា បុគ្គលនោះនៅរស់ ឬស្លាប់ ទ្រព្យសម្បត្តិដែលបន្សល់ទុកនោះ ទោះដល់ពេលណាក៏ដោយក៏មិនអាចធ្វើសន្តតិកម្មបានទេ តែចាំបាច់ត្រូវមានអ្នកគ្រប់គ្រងបន្ត ហើយសហព័ទ្ធក៏មិនអាចរៀបអាពាហ៍ពិពាហ៍ម្តងទៀតបានទេ។ ដូច្នេះក្រមរដ្ឋប្បវេណីកំណត់នូវប្រព័ន្ធនៃការប្រកាសអំពីការអវត្តមាន ឬ

[121] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៨៨។

ការបាត់ខ្លួននេះឡើង ដើម្បីដើម្បីអាចធ្វើសន្តតិកម្មនូវទ្រព្យសម្បត្តិ និងសហព័ទ្ធម្ខាងទៀតអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបាន។

### ៣.៣.១. លក្ខខណ្ឌនៃការប្រកាសពីការអវត្តមាន និងការប្រកាសបាត់ខ្លួន

ប្រសិនបើគេពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល៥ឆ្នាំ តុលាការអាចប្រកាស បានថា បុគ្គលនោះបានបាត់ខ្លួន តាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្ដាយ ឬអ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ ក្នុងការប្រកាសអំពីការបាត់ខ្លួន។[122]

បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលបុគ្គលដែលចូលទៅក្នុងតំបន់ មានសង្គ្រាម បុគ្គលដែលមានវត្តមានក្នុងនាវាដែលលិច រញ្ជួយដី អគ្គិភ័យ ស៊ូណាមី ការរអិលផ្ទាំងទឹកកកពីភ្នំជាដើមដែលអាចនាំឱ្យ មានគ្រោះថ្នាក់ដល់ជីវិត ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នក អវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ១ ឆ្នាំ ក្រោយ ចប់សង្គ្រាម ឬក្រោយព្រឹត្តិការណ៍ផ្សេងទៀតទាំងនោះ។ នៅក្នុងករណីមួយចំនួនទៀត ប្រសិនបើបុគ្គលនោះបានបាត់ខ្លួនពីលំនៅឋានក្នុងរយៈពេលដ៏យូរ ឬគ្មានដំណឹងអ្វីសោះពីបុគ្គលនោះ, មិនដឹងថាបុគ្គលនោះបានជួបគ្រោះថ្នាក់ស្លាប់ ឬក៏យ៉ាងណានោះទេ ស្ថានភាពបែបនេះគឺធ្វើឱ្យពិបាកក្នុងការសន្និដ្ឋានថា បុគ្គលនោះប្រាកដជាទទួលបានមរណភាព ឬក៏នៅរស់នោះទេ វាពិតជាបញ្ហាចោទសម្រាប់បុគ្គលមានផលប្រយោជន៍តាមផ្លូវច្បាប់។[123]

### ៣.៣.២. នីតិវិធីនៃការប្រកាសពីការអវត្តមាន និងការប្រកាសបាត់ខ្លួន

ក្នុងនោះដែលការប្រកាសបាត់ខ្លួនត្រូវធ្វើឡើងដោយឆ្លងកាត់នីតិវិធី នៃការដាស់តឿនជាសាធារណៈគឺដើម្បីផ្តល់ឱកាស និងអនុញ្ញាតឱ្យបុគ្គលដែលដឹងដំណឹងពីការស្លាប់ ឬរស់ របស់បុគ្គលដែលត្រូវប្រកាសបាត់ខ្លួនរាយការណ៍មកបុគ្គលដែលពាក់ព័ន្ធ នេះបើយោងតាមស្មារតីមាត្រា ៤២ អំពីការដាស់តឿនជាសាធារណៈនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ ការដាស់តឿនជាសាធារណៈដែលបានបញ្ញត្តិក្នុងមាត្រា ៥៤ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង បានចែងដូចខាងក្រោម ត្រូវធ្វើឡើងតាមវិធីផ្សាយជាសាធារណៈ។ ដោយការបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ និងចុះផ្សាយក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌។ តាមរយៈការចុះផ្សាយក្នុងសារព័ត៌មានប្រចាំថ្ងៃ ឬតាមវិធីផ្សេងទៀត បន្ថែមពីលើការកំណត់ក្នុងចំណុច(២)ខាងលើ។ ការផ្សាយជាសាធារណៈត្រូវបញ្ជាក់ពី ឈ្មោះ និងអាសយដ្ឋានអ្នកដាក់ពាក្យសុំ។ ឈ្មោះ និងអាសយដ្ឋានចុងក្រោយ និង ថ្ងៃ ខែ ឆ្នាំ កំណើតរបស់អ្នកអវត្តមាន។ ថ្ងៃចប់អំឡុងពេលនៃការដាស់តឿនជាសាធារណៈ។ អ្នកអវត្តមានត្រូវផ្តល់ដំណឹងពីការរស់នៅរបស់ខ្លួន នៅមុនពេលចប់អំឡុងពេលនៃការដាស់តឿនជាសាធារណៈ បើមិនដូច្នេះទេ អ្នកអវត្តមានត្រូវទទួលយកការប្រកាសបាត់ខ្លួន។ ជនដែលដឹងពីព័ត៌មាននៃការរស់នៅ ឬមរណ

[122] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៤១ កថាខណ្ឌទី១។

[123] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៤១ កថាខណ្ឌទី២។

ភាពរបស់អ្នកអវត្តមាន ត្រូវផ្តល់ព័ត៌មានមុនពេលចប់ អំឡុងពេលនៃការដាស់តឿនជាសាធារណៈ។ អំឡុងពេលនៃការដាស់តឿនជាសាធារណៈ ត្រូវមានរយៈពេលមិនតិចជាង៦(ប្រាំមួយ)ខែ សម្រាប់ល័ក្ខខ័ណ្ឌទី១ និងមានរយៈពេលមិនតិចជាង ២ (ពីរ) ខែ សម្រាប់ល័ក្ខខ័ណ្ឌទី២ នៃបញ្ញត្តិមាត្រា ៤១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

បន្ទាប់ពីមានការដាក់ពាក្យសុំត្រឹមត្រូវ និងមានការដាស់តឿនជាសាធារណៈ រហូតដល់ដីការសម្រេចចូលជាស្ថាពរពេលនោះ អានុភាពនៃការប្រកាសបាត់ខ្លួនមានដូចតទៅ បុគ្គលដែលត្រូវបានប្រកាសបាត់ខ្លួនត្រូវសន្មតថា បានទទួលមរណភាព (មាត្រា៤៣ អំពីអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧)។ ដោយការសន្មតថាបានទទួលមរណភាពនៃបុគ្គលអវត្តមាននោះសន្តតិកម្មត្រូវបានផ្តើម (មាត្រា ១១៤៥ កថាខណ្ឌ១ អំពីមូលហេតុនៃការចាប់ផ្តើមធ្វើសន្តតិកម្ម នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)។ អំណាចមេបាចំពោះអនីតិជនត្រូវបានអនុវត្តដោយសហព័ន្ធម្ខាងទៀត ប្រសិនបើការប្រកាសបាត់ខ្លួន បានធ្វើឱ្យអនីតិជនគ្មានអ្នកអនុវត្តអំណាចមេបានោះ អាណាព្យាបាលចំពោះអនីតិជនត្រូវចាប់ផ្តើម (មាត្រា១០៦៧ អំពីមូលហេតុនៃការចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)។ ចំណងអាពាហ៍ពិពាហ៍ត្រូវបានរលាយដោយសារការប្រកាសបាត់ខ្លួន។ សរុបមកការប្រកាសអំពីការអវត្តមាន និងការបាត់ខ្លួន គឺជាការផ្តល់ផលប្រយោជន៍ជូនទៅ សហព័ន្ធ សន្តតិជន អ្នកមានអំណាចមេបា និងបុគ្គលដែលពាក់ព័ន្ធតាមផ្លូវច្បាប់។

### ៣.៣.៣. អានុភាពនៃការអវត្តមាន និងប្រកាសអំពីការបាត់ខ្លួន

ក្នុងករណីទាំងពីរខាងលើនេះ សហព័ទ្ធរបស់អ្នកអវត្តមានឬ បាត់ខ្លួនអ្នកដែលត្រូវសន្មតថា ជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬអ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាម ផ្លូវច្បាប់ អាចស្នើសុំតុលាការនៃលំនៅដ្ឋានចុងក្រោយរបស់បុគ្គលដែលអវត្តមានឬបាត់ខ្លួន ដើម្បីប្រកាសអំពីការបាត់ខ្លួន។ ក្រោយ ពេលតុលាការប្រកាសអំពីការបាត់ខ្លួន អ្នកដែលបាត់ខ្លួនត្រូវចាត់ ទុកថាបានទទួលមរណភាព ហើយសហព័ទ្ធដែលនៅរស់មាន សិទ្ធិរៀបអាពាហ៍ពិពាហ៍ថ្មីបាន។ អាពាហ៍ពិពាហ៍មុនត្រូវសន្មតថា ត្រូវបានរលាយ នៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ថ្មីនោះ។ការប្រកាសបាត់ខ្លួននឹងបង្កើតអានុភាពគតិយុត្តដ៏សំខាន់ ហេតុដូច្នេះហើយ បានជាក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ចែងនូវបញ្ញត្តិនូវវិធានការ ប្រុងប្រយ័ត្នមួយ គឺការដាស់តឿនជាសាធារណៈ ព្រមទាំងមាន កំណត់នូវអំឡុងពេលដែលត្រូវដាស់តឿននេះ ប្រយោជន៍ឱ្យជន ដែលអវត្តមាន(សាមីខ្លួន) ឬអ្នកដែលបានដឹងដំណឹង ឬបានឃើញ ជនដែលអវត្តមាននោះមករាយការណ៍។ តុលាការដែលមានសមត្ថកិច្ចសម្រាប់ធ្វើការដាស់តឿនជាសាធារណៈ ជាតុលាការនៃលំនៅ ឋានចុងក្រោយរបស់បុគ្គលដែលអវត្តមាន។ ការប្រកាសបាត់ខ្លួន គឺជាបញ្ញត្តិដើម្បីសន្មតថាបុគ្គលនោះទទួលមរណភាពតាមផ្លូវច្បាប់ ដើម្បីឱ្យបុគ្គលដែលពាក់ព័ន្ធទទួលបានផលប្រយោជន៍ស្របច្បាប់។ ក្នុងករណីមានមរណភាពនៃបុគ្គលណាម្នាក់ ដោយសារមូលហេតុជាក់លាក់ណាមួយដែលគេអាចកំណត់បានគឺវាមានភាពងាយស្រួលសម្រាប់បុគ្គលដែលមាន ផលប្រយោជន៍តាមផ្លូវច្បាប់ក្នុងការទទួលបាន ផលប្រយោជន៍ពីបុគ្គលដែលទទួលមរណភាពនោះ។

នៅពេលប្រកាសអំពីការបាត់ខ្លួន អ្នកបាត់ខ្លួនត្រូវចាត់ទុកថាទទួលមរណភាពចំពោះទំនាក់ទំនងបញ្ញាគតិយុត្តជុំវិញលំនៅឋាន ឬទីសំណាក់។ មានន័យថាសន្តតិកម្មអាចចាប់ផ្តើមបានហើយសហព័ទ្ធអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។ ប៉ុន្តែ ត្រូវចាត់ទុកថាបានទទួលមរណភាពចំពោះតែទំនាក់ទំនងគតិយុត្តនៅជុំវិញលំនៅឋានប៉ុណ្ណោះ មិនមែនដកហូតនូវសមត្ថភាពទទួលសិទ្ធិរបស់បុគ្គលនោះទេ ដូច្នេះហើយបើបុគ្គលនោះនៅរស់ហើយរស់នៅកន្លែងផ្សេង បុគ្គលនោះធ្វើលទ្ធកម្មនូវសិទ្ធិ និងកាតព្វកិច្ចបាន។ ឧទាហរណ៍ថា បុគ្គលនោះបានបង្កើតកិច្ចសន្យា ក៏មានសុពលភាពដែរ។ ពេលដែលបង្កើតអានុភាពនៃការប្រកាសអំពីការបាត់ខ្លួនករណីការបាត់ខ្លួនធម្មតាគឺ អំឡុងពេល ៥ឆ្នាំ ហើយករណីការបាត់ខ្លួនពិសេស គឺពេលគ្រោះថ្នាក់នោះកន្លងបានផុតទៅ។

## ៣.៤. មរណភាពរបស់សហព័ទ្ធ

មរណភាព សំដៅដល់ការបាត់បង់ជាអចិន្ត្រៃយ៍រាល់ភស្តុតាងនៃជីវិតនៅក្នុងពេលណាមួយក្រោយកំណើតរស់។[124] មានន័យថាមរណភាពរបស់សហព័ទ្ធ ជាការបាត់បង់ជីវិតរបស់ប្តីប្រពន្ធណាម្ខាង។ មរណភាពរបស់សហព័ទ្ធនោះ ត្រូវបានបញ្ជាក់ច្បាស់លាស់តាមរយៈមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់។ ប្រសិនបើយើងមើលលើទិដ្ឋភាពច្បាប់វិញមរណភាពរបស់សហព័ទ្ធ គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍ស្របច្បាប់មួយរវាងសហព័ទ្ធ ដោយភាគី ម្ខាងដែលនៅរស់បានរៀបអាពាហ៍ពិពាហ៍ថ្មី ឬភាគីដែលនៅរស់មានឆន្ទៈក្នុងការបញ្ចប់ទំនាក់ទំនងញាតិពន្ធ។

### ៣.៤.១. នីតិវិធីនៃការបញ្ជាក់មរណភាព

នៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយ ក្នុងករណីដែលសហព័ទ្ធណាមួយបានទទួលមរណភាព អាពាហ៍ពិពាហ៍នោះត្រូវ បានរំលាយដោយស្វ័យប្រវត្តិ។ ប៉ុន្តែសហព័ទ្ធដែលនៅរស់ត្រូវទៅសាលាឃុំ សង្កាត់ដើម្បីបញ្ជាក់សំបុត្រមរណភាពសម្រាប់សហព័ទ្ធដែលស្លាប់។ ការងារនេះជាកាតព្វកិច្ចរបស់ពលរដ្ឋគ្រប់រូប ហើយក៏មានសារប្រយោជន៍សម្រាប់ការរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត។ ពេលមានអ្នកស្លាប់ សាច់ញាតិ ឬអ្នកជិតខាង ឬអ្នកនៅគ្រួសាររបស់អ្នកស្លាប់ ត្រូវប្តឹងដល់មន្ត្រីអត្រានុកូលដ្ឋាននៃទីកន្លែង រស់នៅជាប់លាប់របស់អ្នកស្លាប់ក្នុងរយៈពេលដែលច្បាប់កំណត់គឺ ១៥ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព តាមអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន។ មន្ត្រីអត្រានុកូលដ្ឋាន ចេញលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះចំពោះអ្នកស្លាប់ក្នុងជម្ងឺធម្មតា ឬ ដោយជរា ឬដោយគ្រោះ ថ្នាក់ធម្មជាតិ។ ករណីពុំបានទៅរាយការណ៍ចុះសៀវភៅមរណភាពនៅមន្ត្រីអត្រានុកូលដ្ឋានទេ ហើយទុកផុតរយៈពេល១៥ថ្ងៃនៅក្នុងឆ្នាំ ក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវប្តឹងសុំសំបុត្រមរណភាពពីមេឃុំ ចៅសង្កាត់ នៃលំនៅដ្ឋានពិតប្រាកដនៃអ្នកស្លាប់ដោយត្រូវបង់ថ្លៃសំបុត្រមរណភាពនេះដល់អាជ្ញាធរឃុំ សង្កាត់សាមីចំនួនពី ១០០០ រៀល ទៅ ៤០០០រៀល។ ក្នុងករណីពុំបានទៅរាយការណ៍អំពីការចុះសៀវភៅមរណភាពនៅមន្ត្រីអត្រានុកូលដ្ឋានទេហើយទុករយៈពេលហួសឆ្នាំក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវទៅសុំសាលក្រមពីតុលាការ

[124] សន្ទានុក្រម ច្បាប់ ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ លេខរៀង ៧។

រាជធានី ខេត្តសាមី។ រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃអ្នកស្លាប់ដើម្បីចុះសៀវភៅមរណភាព។

### ៣.៤.២. អានុភាពក្រោយមរណភាព

ក្រោយពីមរណភាពរបស់សហព័ទ្ធរួចហើយ សន្តតិកម្ម ចាប់ផ្តើមដោយសារមរណភាពរបស់មតកជន នៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ហើយសន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ដែលទ្រព្យរបស់មតកជន នៅពេលចាប់ផ្តើមសន្តតិកម្ម (គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ) និងប្រសិនបើមានសន្តតិជនច្រើននាក់ ត្រូវសមាមាត្រនៃចំណែកមត៌ក។ មត៌កត្រូវចាត់ទុកថាជាកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន នៅពេលមិនទាន់មានការបែងចែកត្រឹមត្រូវតាមច្បាប់ ឬឆន្ទៈ ឬការពិភាក្សា ដែលមានលក្ខណៈអាចទទួលយកបានទាំងអស់គ្នា។

## ៣.៥. ការលែងលះ

### ៣.៥.១. ការលែងលះដោយការព្រមព្រៀង

ការលែងលះដោយមានការព្រមព្រៀងមានន័យថាភាគី(ប្តី និងប្រពន្ធ)នៃអាពាហ៍ពិពាហ៍បានឯកភាពគ្នាដោយស្ម័គ្រចិត្តរំលាយចំណងអាពាហ៍ពិពាហ៍ ហើយភាគីត្រូវដាក់ពាក្យសុំដីកាសម្រេច ដោយភ្ជាប់ជាមួយកិច្ចព្រមព្រៀងលែងលះដោយស្ម័គ្រចិត្ត ទៅសាលាដំបូងរាជធានី ខេត្ត បើតុលាការរកឃើញថាភាគីទាំងពីរមានឆន្ទៈព្រមព្រៀងពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍នោះតុលាការនឹងសម្រេចឱ្យភាគីលែងលះគ្នាតាមរយៈអំណាចដីកាសម្រេច។[125] បុរសនារីបើគ្រាន់តែរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីទំនៀមទម្លាប់ ឬពិធីតាមបែបសាសនាណាមួយ ដោយមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់នារី នោះមិនអាចចាត់ទុកថា មានចំណងអាពាហ៍ពិពាហ៍ តាមផ្លូវច្បាប់ជាប្តីប្រពន្ធឡើយ។ ការរួមរស់ជាប្តីប្រពន្ធដោយមិនមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់បែបនេះត្រូវបានហៅថាអនីតិសង្វាស់អាចនាំឱ្យកូនដែលកើតមកគឺជាកូនរបស់ម្តាយ ប៉ុន្តែអាចមិនមែនជាកូនរបស់ឪពុកឡើយ មានន័យថាបើគ្មានអាពាហ៍ពិពាហ៍ស្របច្បាប់ទេ យើងមិនអាចសន្មត់ថាបុគ្គលណាមួយជាឪពុករបស់ក្មេងឡើយ ប៉ុន្តែគេអាចទទួលស្គាល់ចំណងបុត្តភាពនៅពេលក្រោយបាន។ ក្រៅពីចំណុចនេះក៏អាចនាំឱ្យភាគីម្ខាងលបលួចទៅរួមរស់ ឬរួមសេវនកិច្ចជាមួយបុរសនារីផ្សេងទៀត ហើយភាគីម្ខាងគ្មានសិទ្ធិប្តឹងភាគីម្ខាងទៀតឱ្យទទួលខុសត្រូវក្នុងបទល្មើសព្រហ្មទណ្ឌជាដើម។

នីតិវិធីនៃការលែងលះដោយការព្រមព្រៀងនៅក្នុងពាក្យសុំគូភាគីត្រូវសរសេរចំណុចដែលច្បាប់បានកំណត់ដូចខាងក្រោមនេះៈ

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និង ឈ្មោះ និង អាសយដ្ឋានរបស់ អ្នកតំណាងដែលច្បាប់បានកំណត់។

[125] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មាត្រា ៣ កថាខណ្ឌ២។

ខ-ខ្លឹមសារនៃដីកាសម្រេច ឬសកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ។ ការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ គូភាគីត្រូវសរសេរពាក្យសុំនោះនូវចំណុចដូចបាន រៀបរាប់ខាងលើដែលមានបញ្ញត្តិនៅក្នុង មាត្រា២៦កថាខណ្ឌទី២នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

ចំពោះការដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗដូចខាងលើនៅចំពោះមុខក្រឡាបញ្ជីហើយក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុចុះហត្ថលេខាហើយកំណត់ហេតុនេះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ។ ក្នុងករណីដែលមានឯកសារជាភស្តុតាងអ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយឯកសារដើម ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬត្រូវដាក់ជូនឯកសារទាំងនោះទៅកាន់តុលាការនៅពេលដាក់ពាក្យសុំ។ ចំពោះការទាមទារបន្ទាប់បន្សំរួមមាន ការទាមទារសោហ៊ុយអាពាហ៍ពិពាហ៍ អាហារកិច្ច និងការទាមទារឱ្យបែងចែកទ្រព្យសម្បត្តិការបែងចែកអំពីអ្នកមានអំណាចមេបាការកំណត់អំពីសោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូនអាចធ្វើឡើងនៅក្នុងពាក្យសុំលែងលះ។ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥០០០ (ប្រាំពាន់) រៀល។ ភាគីដែលមានបំណងលែងលះតាមការព្រមព្រៀង ត្រូវដាក់ពាក្យសុំលែងលះទៅតុលាការខាងលំនៅឋានប្តី ឬប្រពន្ធ។

ចំពោះការលែងលះដោយការព្រមព្រៀង ភាគីអាចដាក់ពាក្យសុំទៅតុលាការតែម្តង ឬដាក់ពាក្យសុំទៅសាលាឃុំសង្កាត់សិនក៏បាន។ ទោះបីជាយ៉ាងណាក៏ដោយអាជ្ញាធរថ្នាក់ឃុំ សង្កាត់មិនមានសិទ្ធិអំណាចក្នុងការអនុញ្ញាតឱ្យប្តីប្រពន្ធលែងលះគ្នាបាននោះទេ ពោលគឺឃុំសង្កាត់មានសមត្ថកិច្ចត្រឹមតែការផ្សះផ្សាឱ្យសហព័ទ្ធទាំងសងខាងត្រូវរ៉ូវគ្នាវិញប៉ុណ្ណោះចំណែកឯតុលាការជាអ្នកចេញដីកាសម្រេច។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជានឹងគ្នាបាន ក្នុងអំឡុងពេល ១៥ថ្ងៃ បន្ទាប់ពីទទួលបានពាក្យសុំ។ ហើយការផ្សះផ្សានៅឃុំសង្កាត់អាចទទួលបានលទ្ធផលពីរគឺ ការផ្សះផ្សាបានសម្រេច និង ការផ្សះផ្សាមិនបានសម្រេច។ ការផ្សះផ្សាទទួលបានលទ្ធផលល្អ ដោយភាគីទាំងសងខាងយល់ព្រមសះជានឹងគ្នាវិញព្រមរួមរស់ជាមួយគ្នាជាប្តីប្រពន្ធវិញនោះសមត្ថកិច្ចរបស់ឃុំសង្កាត់ត្រូវធ្វើកំណត់ហេតុអំពី លទ្ធផលសះជានេះនៅក្នុងសៀវភៅកំណត់ហេតុផ្សះផ្សារបស់ឃុំសង្កាត់។ នេះមានន័យថាការផ្សះផ្សារបស់ក្រុមប្រឹក្សាឃុំសង្កាត់បានសម្រេច។ ចំពោះពាក្យសុំលែងដែលគូភាគីទាំងពីរព្រមព្រៀងលែងលះនោះ ត្រូវបានបញ្ចប់នៅថ្នាក់ឃុំសង្កាត់ហើយមិនចាំបាច់បញ្ជូនទៅតុលាការបន្តទៀតទេ។ ផ្ទុយទៅវិញបើសហព័ទ្ធទាំងសងខាងនៅតែប្រកាន់ជំហរព្រមព្រៀងលែងលះគ្នានោះនីតិវិធីបន្ទាប់របស់ក្រុមប្រឹក្សាឃុំសង្កាត់ គឺបញ្ជូនពាក្យបណ្តឹងលែងលះទៅសាលាដំបូងតាមរាជធានី ខេត្តជាបន្ទាន់។ នៅពេលពាក្យសុំបានទៅដល់ដៃតុលាការ ពេលនោះរដ្ឋបាលតុលាការនឹងមានការបែងចែកទៅចៅក្រមទទួលតាមលំដាប់វេនដែលបានកំណត់ជាមុនដោយដីកាសម្រេចប្រចាំឆ្នាំ។ បន្ទាប់មកចៅក្រមទទួលបន្ទុកនឹងរៀបចំកំណត់កាលបរិច្ឆេទធ្វើនីតិវិធីសាកសួរគឺអាចធ្វើនៅក្នុងបន្ទប់ផ្ទាល់ខ្លួនរបស់ចៅក្រមបាន។

ដោយមិនចាំបាច់ធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ទេ ព្រោះរឿងនេះមិនមានវិវាទដែលចៅក្រមត្រូវចាំបាច់ទាញហេតុផលដើម្បីកំណត់ចំណុចវិវាទនោះទេ មានន័យថាគូភាគីបានព្រមព្រៀងគ្នាគ្រប់ចំណុចរួច

ហើយ។ នៅពេលដឹកនាំនីតិវិធី ទោះបីរឿងក្តីនៃការលែងលះដោយការព្រមព្រៀងជាការសម្តែងឆន្ទៈរបស់ភាគីក៏ដោយ ក៏ចៅក្រមតែងតែព្យាយាមផ្សះផ្សាភាគីឱ្យត្រូវគ្នាវិញ បើគាត់ពិនិត្យឃើញថាការលែងលះអាចបង្កជាផលអវិជ្ជមានខ្លាំងចំពោះកូន ហើយភាគីនៅមានមនោសញ្ចេតនាខ្លះជាមួយគ្នានៅឡើយ។ ការផ្សះផ្សា គឺជាការផ្សះផ្សាដើម្បីដកពាក្យសុំលែងលះ។ នៅក្នុងនីតិវិធីសាកសួរក្រៅពីការផ្តល់ផលិកាដល់ភាគីបញ្ជាក់ឱ្យភាគីកាន់តែច្បាស់នូវឆន្ទៈព្រមព្រៀងរបស់ខ្លួនលើគ្រប់បញ្ហាដែលបានទាមទារតុលាការអាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ឬធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិទៀតផង។ នៅក្នុងការដឹកនាំនីតិវិធីនេះតុលាការមិនឈរលើគោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគីដូចការអនុវត្តក្នុងនីតិវិធីបណ្តឹងធម្មតាឡើយ ពោលគឺតុលាការអាចលើកយកអង្គហេតុដែលភាគីមិនបានអះអាងមកធ្វើជាមូលដ្ឋាននៃដីកាសម្រេច។ លើសពីនេះទៀតក្នុងករណីដែលយល់ឃើញថាសមរម្យតុលាការអាចអនុញ្ញាតឱ្យជនពាក់ព័ន្ធផលប្រយោជន៍ចូលរួមក្នុងនីតិវិធី ឬចូលរួមជាអ្នកអង្កេតការបាន។ ម្យ៉ាងទៀតច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងក៏បានអនុញ្ញាតឱ្យតំណាងអយ្យការចូលរួមក្នុងនីតិវិធីតាមរយៈការជូនដំណឹងរបស់តុលាការ ឬចូលរួមដោយឯកឯងប្រសិនបើរឿងក្តីមានការពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ។

បន្ទាប់ពីតុលាការធ្វើនីតិវិធីវិនិច្ឆ័យទទួលបាននូវមូលដ្ឋាននៃការពិចារណារួចរាល់ តុលាការនឹងរៀបចំសេចក្តីសម្រេចរបស់ខ្លួនឆ្លើយតបទៅនឹងការទាមទាររបស់ដាក់ពាក្យសុំ។ ជាទូទៅប្រសិនបើពិនិត្យឃើញថាលក្ខខណ្ឌនៃរឿងក្តីមិនបានបំពេញទេតុលាការនឹងសម្រេចលើកចោលនូវពាក្យសុំ។ ផ្ទុយមកវិញបើរឿងក្តីមានគ្រប់លក្ខខណ្ឌត្រឹមត្រូវតាមច្បាប់ តុលាការនឹងសម្រេចក្តីតាមការទាមទាររបស់អ្នកដាក់ពាក្យសុំ។ សេចក្តីសម្រេចដែលធ្វើឡើងដើម្បីសម្រេចទៅលើអង្គសេចក្តីនៃរឿងលែងលះដោយការព្រមព្រៀង ត្រូវធ្វើឡើងដោយដីកាសម្រេចជាលាយលក្ខណ៍អក្សរមិនមែនធ្វើតាមសាលក្រមទេ។ ក្រោយពេលចេញដីកាសម្រេចក្នុងករណីដែលផុតរយៈពេលប្តឹងឧបាស្រ័យរបស់អ្នកខូចប្រយោជន៍ នោះការចូលជាស្ថាពរនៃដីកាសម្រេចនឹងត្រូវកើតមានឡើងនូវអានុភាព។

### **៣.៥.២. ការលែងលះតាមបណ្តឹងទាមទារ**

ប្រសិនបើភាគីមិនមានឆន្ទៈព្រមព្រៀងគ្នាលែងលះទេនៅពេលដែលមានបណ្តឹងចូលមកតុលាការត្រូវតែស្វែងរកមូល ហេតុដែលនាំឱ្យភាគីលែងលះតាមផ្លូវច្បាប់។ការលែងលះដែលមានមូលហេតុដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណីគឺ ជាការលែងលះដោយមិនមានការព្រមព្រៀងមានន័យថា ភាគីម្ខាង(ប្តីឬប្រពន្ធ) នៃអាពាហ៍ពិពាហ៍មិនមានឆន្ទៈក្នុងការលែងលះប៉ុន្តែភាគីម្ខាងទៀតទទូចឱ្យមានការលែងលះដោយមិនអាចរួមរស់នៅជាមួយគ្នាបានទៀត។ ម្យ៉ាងទៀត ដោយសារទ្រាំមិនបាននិងភាគីម្ខាងទៀត (ប្តីឬប្រពន្ធ) បានធ្វើអំពើពុំគប្បីមិនសមរម្យណាមួយមិនអាចនឹង អធ្យាស្រ័យបានហើយការប្រព្រឹត្តនោះជាឥទ្ធិពលខ្លាំងទៅដល់ភាគីម្ខាងនៃជនរងគ្រោះមាន កូន សាច់ញាតិនាំអោយ បាត់បង់នូវសេចក្តីថ្លៃថ្នូរនៅក្នុងគ្រួសារហើយក៏ជាមូលហេតុនៃការលែងលះដែលមានបញ្ញានៅក្នុងក្រមរដ្ឋប្បវេណី មាត្រា ៩៧៨ គាត់ថាខណ្ឌទី ១ ផងដែរ។ភាពមិនសុខចិត្តនៃភាគីជនរងគ្រោះដែលទទួលរងអំពើនោះក៏បានសម្រេច ចិត្តដាក់ពាក្យបណ្តឹងលែងលះដើម្បីឱ្យតុលាការធ្វើការវិនិច្ឆ័យ

ហើយចេញសាលក្រមលែងលះឆ្លើយតបនឹងអ្វីដែលភា គឺនៃជនរងគ្រោះដែលជាដើមបណ្តឹងបានទាមទារនៅក្នុងពាក្យបណ្តឹង។

នៅពេលដែលមានភាគីណាម្ខាង (ប្តីប្រពន្ធ) បានដាក់ពាក្យបណ្តឹងលែងលះទៅក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យដោះស្រាយមុនដាក់ទៅតុលាការ មន្ត្រីត្រូវសាកល្បងធ្វើការផ្សះផ្សាក្នុងរយៈពេល ១៥ថ្ងៃក្រោយពីទទួលពាក្យបណ្តឹង។ ប៉ុន្តែបើភាគីទាំងពីរមិនព្រមបន្តការរួមរស់នៅជាមួយគ្នាទេ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចាត់ទុកថាមានពាក្យបណ្តឹងសុំលែងលះត្រូវបញ្ជូនទៅតុលាការជាបន្ទាន់។ បើទោះបីជាក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ពុំបានចែងពីការផ្សះផ្សាជាច្រើនដងមុននិងបញ្ជូនរឿងទៅតុលាការ។ ចំពោះការលែងលះរបស់សហព័ទ្ធអាចធ្វើទៅបានលុះត្រាតែធ្វើទៅតាមផ្លូវតុលាការ ពោលពាក្យបណ្តឹងលែងលះគ្នាអាចដាក់ទៅតុលាការដែលមានសមត្ថកិច្ច ឬមុនពេលលែងលះភាគីត្រូវដាក់សុំលែងលះទៅក្រុមប្រឹក្សាឃុំ សង្កាត់ខាងលំនៅឋាន ឬទីសំណាក់របស់ភាគីនៃទំនាក់ទំនង នឹងបណ្តឹងនោះឬលំនៅឋាននាពេលដែលភាគីទទួលមរណភាព។ ក្រោយពីពេលបានទទួលបណ្តឹងសុំលែងលះបើយល់ឃើញថាការចាំបាច់ តុលាការអាចចាត់វិធានការបណ្តោះអាសន្នបានដូចជាការបំបែកលំនៅឋានប្តីប្រពន្ធការឱ្យមើលថែរក្សាកូន ថែរក្សាទ្រព្យសម្បត្តិការផ្តល់អាហារកាតព្វកិច្ច។

មូលហេតុនៃការលែងលះមានបីធំៗ មូលហេតុក្នុងគ្រួសារ មូលហេតុក្នុងសង្គម មូលហេតុតាមច្បាប់។ មូលហេតុក្នុងគ្រួសាររួមមាន ភាពមិនស្មោះត្រង់ ខ្វះភាពប្តេជ្ញា ការប្រចណ្ឌ រៀបការនៅក្មេងពេក រៀបការដោយមិនពេញចិត្ត អំពើហិង្សា បញ្ហាសេដ្ឋកិច្ច។ មូលហេតុក្នុងសង្គមរួមមាន ការផ្សព្វផ្សាយគ្រឿងស្រវឹង ការបើករាត្រីកម្សាន្ត គ្រឿងញៀន ពិធីបុណ្យ ឬពិធីផ្សេងៗ ការសេពគប់មិត្ត។ មូលហេតុតាមច្បាប់រួមមាន ការប្រព្រឹត្តអំពើផិតក្បត់ មិនដឹងថាស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំ រស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេល១ឆ្នាំ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការស្រាវជ្រាវប្រធានបទខាងលើនេះ យើងខ្ញុំអាចធ្វើការសន្និដ្ឋានថា ជាកិច្ចការមួយដើម្បីមានភាពស្របច្បាប់នោះ បុរស និងនារី ត្រូវគោរពលក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍មានគោលការណ៍ស្ម័គ្រចិត្ត ភេទរបស់ភាគី អាយុភាគី ភាគីជាអនីតិជន និងជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងការហាមឃាត់នូវការរៀបអាពាហ៍ពិពាហ៍មួយចំនួនដែលមិនស្របច្បាប់នោះ ការហាមឃាត់មិនទ្វេពន្ធភាព អំឡុងពេលនៃការហាមឃាត់ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត និងការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ និងការគោរពនីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ រួមមាន ទីកន្លែងដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការប្រកាសជាសាធារណៈ ការចុះបញ្ជីអាពាហ៍ពិពាហ៍ ការផ្តល់សំបុត្រអាពាហ៍ពិពាហ៍ដោយមន្ត្រីអត្រានុកូលដ្ឋាន ការប្តឹងជំទាស់នៃអាពាហ៍ពិពាហ៍ រួមមាន ការកំណត់អំពី ជនដែលអាចធ្វើការបណ្តឹងជំទាស់អាពាហ៍ពិពាហ៍ មូលហេតុនៃការប្តឹងជំទាស់គ្រោងរៀបអាពាហ៍ពិពាហ៍ និងការសម្រេចលើការប្តឹងជំទាស់របស់អ្នកមានផលប្រយោជន៍ និងបន្ទាប់មកលើកពីអានុភាពនៃអាពាហ៍ពិពាហ៍ រួមមាន អានុភាពក្រៅបេតិកភណ្ឌ រួមមាន សិទ្ធិប្រើប្រាស់នាមត្រកូល ទទួលបាននីតិភាពតាមអាពាហ៍ពិពាហ៍ សិទ្ធិអំណាចមេបា និងករណីយកិច្ចថែទាំជួយសង្គ្រោះគ្នា។ និងអានុភាពក្នុងបេតិកភណ្ឌ រួមមាន ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមការកំណត់របស់ច្បាប់។

ការរួមរស់នៅជាមួយគ្នាដោយមិនចុះបញ្ជីអាពាហ៍ពិពាហ៍ (ការរស់នៅជាមួយគ្នាបែបអនីតិសង្វាស) ការរួមរស់នៅជាមួយគ្នាដូចប្តីប្រពន្ធ ទំនាក់ទំនងប្រភេទនេះមិនត្រូវបានច្បាប់ទទួលស្គាល់ថាជាប្តីប្រពន្ធស្របច្បាប់នោះឡើយ។ គុណវិបត្តិនោះរួមមាន ទំនាក់ទំនងញាតិនៅក្នុងរង្វង់គ្រួសាររបស់ភាគីទាំងពីរ មិនត្រូវបានបង្កើតនោះទេ ប្រាក់ចំណូលដែលបានមកក្នុងអំឡុងពេលអនីតិសង្វាសនោះ មិនត្រូវបានកំណត់ជាទ្រព្យសម្បត្តិរួមនោះឡើយ ប្តី ឬប្រពន្ធក្នុងករណីភាគីម្ខាងមរណភាពភាគីម្ខាងទៀតមិនអាចក្លាយជាសន្តតិកម្មតាមច្បាប់សម្រាប់ទទួលបានមត៌កនោះទេ លើកលែងមានបណ្តាំមត៌ក នៅក្នុងអំឡុងពេលអនីតិសង្វាស ភាគីម្ខាងទៀតអាចរកដៃគូថ្មីបាន ដោយពុំចាំបាច់ដាក់ពាក្យបណ្តឹងលែងលះតាមផ្លូវតុលាការ ភាគីម្ខាងទៀតមិនអាចប្តឹងទៅភាគីម្ខាងទៀតពី បទអំពើផិត ឬសាហាយស្មន់ឡើយ អនីតិសង្វាសពុំមានអភ័យឯកសិទ្ធិគ្រួសារ ដូចប្តីប្រពន្ធស្របច្បាប់នោះឡើយ អំពើលួចទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធស្របច្បាប់ មិនអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌ។

សរុបមក អនីតិសង្វាស គឺជាការរួមរស់ជាមួយគ្នាដែលមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ (អេតាស៊ីវិល) នៅចំពោះមុខមន្ត្រី និងគោរពបែបបទនីតិវិធីរបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ផងដែរ។ ថ្វីដ្បិតតែនៅពេលដែលបែកបាក់គ្នាភាគីនៃអនីតិសង្វាសមិនមានភាពស្មុគស្មាញដូចទៅនឹងប្តីប្រពន្ធបានចុះបញ្ជីអាពាហ៍ពិពាហ៍ស្របច្បាប់ក៏ដោយ ប៉ុន្តែអនីតិសង្វាសនេះក៏មិនត្រូវបានច្បាប់ការពារ និងទទួលបានអត្ថប្រយោជន៍ ដូចទៅនឹងប្តីប្រពន្ធដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍ស្របច្បាប់នោះដែរ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងធ្វើការចងក្រងសារណាទៅលើប្រធានបទស្តីពី អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា ដែលបានបង្ហាញខាងលើរួចមកយើងខ្ញុំបាទបានមើលឃើញនូវការខ្វះខាតច្បាប់ និងលិខិតណែនាំឱ្យមានការឯកភាពគ្នា ដោយបច្ចុប្បន្នការរៀបចំអាពាហ៍ពិពាហ៍យើងអនុវត្តតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣។ ដោយមើលឃើញនូវបញ្ហាខ្វះចន្លោះគឺច្បាប់ថ្មី តែឯកសារធ្វើអត្រានុកូលដ្ឋានវិញ នៅអនុវត្តតាមអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០១២ ដដែលធ្វើដូច្នេះមានឱ្យការអនុវត្តមានភាពស្មុគស្មាញ។ ហេតុដូច្នេះហើយដើម្បីរួមចំណែកក្នុងការកែទម្រង់ប្រព័ន្ធច្បាប់ និងវិស័យយុត្តិធម៌ឱ្យកាន់តែប្រសើរឡើងនោះ យើងខ្ញុំសូមសំណូមពរ និងបញ្ចេញមតិយោបល់ផ្ទាល់ខ្លួនមួយចំនួនដែលយល់ថាគួរធ្វើការរិះគន់ដើម្បីស្ថាបនា និងកែលម្អឱ្យកាន់តែប្រសើរឡើង ដើម្បីជាផលប្រយោជន៍ទាំងអស់គ្នា ដូចខាងក្រោម៖

ក្រសួងមហាផ្ទៃ គួររៀបចំធ្វើលិខិតណែនាំ ឬសារាចរណែនាំថ្មី បើកវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តថ្មី ដែលទើបចេញ និងកំពុងជាធរមាន ដើម្បីឱ្យការអនុវត្តនោះមានឯកភាពគ្នាចាប់តាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ។ ក្រសួងគួរដាក់ចេញយុទ្ធនាការដែលមានគោលនយោបាយត្រឹមត្រូវ និងការតាមដាននៃវឌ្ឍនភាពការងារ ធ្វើឱ្យដូចជាភ្លៀងរលឹម ដើម្បីការអនុវត្តនោះមានប្រសិទ្ធភាព តម្លាភាព ត្រឹមត្រូវតាមច្បាប់ និងចីរភាព។

ក្រសួងយុត្តិធម៌ គួរមានផែនសកម្មភាពចាត់មន្ត្រីជំនាញបច្ចេកទេសច្បាប់ និងអាជ្ញាធរដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគួរ ចុះផ្សព្វផ្សាយច្បាប់ និងនីតិវិធីរបស់ច្បាប់ថ្មីៗ ដើម្បីជានាការអនុវត្តនោះមិនមានបញ្ហាចោទឡើង ដែលនាំឱ្យមានការប្តឹងផ្តល់គ្នាឡើងដល់តុលាការ គួរដោះស្រាយតាមនយោបាយឈ្នះ-ឈ្នះ។

ស្ថាប័នតុលាការ គួរតែព្យាយាមសម្របសម្រួលផ្សះផ្សាគូភាគីវិវាទជាអាទិភាព មុននឹងឈានដល់ការកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍ដែលធ្វើឱ្យគ្រួសារញាតិបែកបាក់គ្នា កូនព្រាត់ឪពុកម្តាយ យាយតាព្រាត់ចៅ ប្តីប្រពន្ធចែកផ្លូវគ្នា ទ្រព្យសម្បត្តិត្រូវបានបែកខ្ចាត់ខ្ចាយ និងសេដ្ឋកិច្ចគ្រួសារធ្លាក់ខ្លួនក្រីក្រ។

មន្ត្រីអត្រានុកូលដ្ឋាន ដែលជាមន្ត្រីជួរមុខដែលស្ថិតជិតប្រជាជននោះ គួរតែខិតខំផ្សះផ្សាគូភាគីឱ្យអស់ចិត្តអស់ចង់ មុននឹងបន្តសំណុំរឿងបន្តឡើងមកតុលាការសាលាដំបូងរាជធានី ខេត្តនោះ។ គួរសម្របសម្រួលគូភាគីជាមុន ដើម្បីចូលរួមបង្កើនធនធានមនុស្សនៅក្នុងឃុំ សង្កាត់ របស់ខ្លួន និងសេដ្ឋកិច្ចមូលដ្ឋានខ្លួនផងដែរ។

សហព័ទ្ធ ឬប្តីប្រពន្ធនានា ដែលស្ថិតនៅក្នុងមូលដ្ឋានត្រូវតែនាំគ្នាចុះបញ្ជីអាពាហ៍ពិពាហ៍ដើម្បីឱ្យចំណងអាពាហ៍ពិពាហ៍នោះមានភាពរឹងមាំ និងទទួលបានផលប្រយោជន៍នានា ដែលច្បាប់ប្រទេសកម្ពុជាទទួលស្គាល់។ ប្រជាពលរដ្ឋគួរ យល់ឱ្យបានច្បាស់ពីផលវិបាកនៃការលែងលះ ដែលនាំឱ្យគ្រួសារបែកបាក់គ្នា សេដ្ឋកិច្ចគ្រួសារមានភាពអន់ថយ។ ហេតុនេះដើម្បីបង្កើតបាននូវគ្រួសារមួយមានសេចក្តីសុខ និងសុភមង្គលរបស់សង្គមជាតិនោះ សហព័ទ្ធត្រូវតែចុះបញ្ជីអាពាហ៍ពិពាហ៍ជាកាតព្វកិច្ចទើបគ្រួសារមានភាពស្របច្បាប់។

# គន្ថនិទ្ទេស

# គន្ថនិទ្ទេស


**រដ្ឋធម្មនុញ្ញ**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

**ក្រមរដ្ឋប្បវេណី**

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

**ច្បាប់**

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១។

ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦។

ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣។

**អនុក្រឹត្យ**

អនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០។

**សេចក្តីណែនាំ**

សេចក្តីណែនាំ ស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត ឆ្នាំ២០០៧។

សេចក្តីណែនាំ ស្តីពីបែបបទ នីតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ឆ្នាំ២០២៤។

សេចក្តីណែនាំស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ស្របតាម ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៤។

**សៀវភៅរបស់អ្នកនិពន្ធ**

ក្រសួងអប់រំ យុវជន និងកីឡា សៀវភៅសិក្សាសង្គមថ្នាក់ទី៩ ពិធីរៀបមង្គលការ ឆ្នាំ១៩៩៩។

លោកស្រី ប៉ូយ ធីតា សៀវភៅនីតិរដ្ឋប្បវេណី ឆ្នាំ២០២៤។

លោក រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត សៀវភៅនីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ ឆ្នាំ២០២២។

លោកបណ្ឌិត ឥន យឿន សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍ ឆ្នាំ២០១៣។